# សង្គ្រោះខ្លួនយើង

សៀវភៅណែនាំមូលដ្ឋានសម្រាប់
សកម្មជនសុខភាព និងសុវត្ថិភាព

industriall
global union

# មាតិកា


| | |
|---|---|
| សេចក្តីផ្តើម | 3 |
| គណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម | 4 |
| ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ | 6 |
| ការស៊ើបអង្កេតឧប្បត្តិហេតុ | 10 |
| ប្រព័ន្ធនិងកម្មវិធីសុវត្ថិភាព | 16 |
| ការដោះស្រាយបញ្ហាជាមូលដ្ឋាន | 18 |
| របៀបវាស់វែង និងវាយតម្លៃប្រព័ន្ធសុខភាពនិងសុវត្ថិភាព | 20 |
| ស្តង់ដារសម្រាប់សវនកម្មសុវត្ថិភាព | 24 |
| គោលនយោបាយ និងនីតិវិធីសម្រាប់កែតម្រូវកំហុស | 25 |
| និយមន័យខ្លះ | 27 |

# ➤ សេចក្តីផ្តើម

សកម្មជនសុខភាព និងសុវត្ថិភាព ជាអ្នកធ្វើឱ្យមានភាពខុសគ្នារវាងទីកន្លែងធ្វើការដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព ។ មិនថា យើង ៖

- **រៀបចំសកម្មភាពសុខភាព និងសុវត្ថិភាពរបស់សហជីព**
- **ធានាប្រសិទ្ធភាពរបស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម (JHSC)**
- **ស្នើឱ្យមានគោលដៅសម្រាប់ការចរចាអនុសញ្ញារួម និងភាសា**
- **ធានាថា សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ គឺជាចំណុចកណ្តាលនៃការយកចិត្តទុកដាក់របស់សហជីព**
- **តាមដានមើលលក្ខខណ្ឌនៅកន្លែងធ្វើការជារៀងរាល់ថ្ងៃ នោះទេ**

... ការការយកចិត្តទុកដាក់ និងការតាំងចិត្តរបស់យើង ជួយធានាថា បងប្អូនប្រុសស្រីរបស់យើង វិលត្រឡប់ពីកន្លែងធ្វើការទៅផ្ទះវិញ ដោយគ្មានគ្រោះថ្នាក់ ឬជំងឺ ។
ជាការពិត ការសង្គ្រោះខ្លួនយើងគឺជាអាស្រ័យលើយើងទាំងអស់គ្នា ។
យើងទាមទារសិទ្ធិជាមូលដ្ឋានគ្រឹះរបស់កម្មករចំនួនបីទាក់ទងនឹងសុខភាព និងសុវត្ថិភាព ៖

1. **សិទ្ធិក្នុងការដឹង - ពេញលេញ - អំពីគ្រោះថ្នាក់នៅកន្លែងធ្វើការ និងទទួលការបណ្តុះបណ្តាល និងការអប់រំ**
2. **សិទ្ធិក្នុងការបដិសេធ ឬបិទចោលការងារដែលគ្មានសុវត្ថិភាព**
3. **សិទ្ធិក្នុងការចូលរួមក្នុងការសម្រេចចិត្តអំពីសុខភាព និងសុវត្ថិភាព តាមរយៈគណៈកម្មាធិការរួម**

សិទ្ធិក្នុងការចូលរួមបង្កើតមូលដ្ឋានកណ្តាលនៃកម្មវិធីសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការប្រកបដោយប្រសិទ្ធភាព ។ តាមវិធីជាច្រើន សិទ្ធិពីរផ្សេងទៀតផ្តើមចេញពីសិទ្ធិមួយនេះ ។

ទោះបីជាគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម (JHSCs) ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់នៅក្នុងប្រទេសជាច្រើនក្តី ហើយដាក់ដូចជាមិនសូវត្រូវបានគេយកចិត្តទុកដាក់ក្នុងពេលបច្ចុប្បន្ននេះក៏ដោយ ជាការសំខាន់ដែលត្រូវចងចាំថា គណៈកម្មាធិការទាំងនេះកាលពីដំបូងឡើយគឺជាលទ្ធផលនៃការចរចាអនុសញ្ញារួម ។ ក្រដាសព័ត៌មានអំពីសុវត្ថិភាពនៃសម្ភារៈគ្រោះថ្នាក់ ត្រូវបានដាក់បញ្ចូលទៅក្នុងខចែងស្តីពីសិទ្ធិត្រូវដឹង ដែលត្រូវបានចរចាកាលពីទសវត្ស៍រ៍ឆ្នាំ ១៩៧០ ។ សិទ្ធិក្នុងការបដិសេធការងារដែលមិនមានសុវត្ថិភាព ដែលមានតាំងពីយូរមកហើយនោះ បានក្លាយជាការពិតនៅពេលដែលសហជីពចាប់ផ្តើមទាមទារសិទ្ធិនេះ ។ សិទ្ធិកើតឡើងដោយសារការធ្វើសកម្មភាព ។

IndustriALL ធ្វើការដើម្បីស្តង់ដារសុខភាព និងសុវត្ថិភាពសកលកាន់តែប្រសើរ តាមរយៈស្ថាប័ននានាដូចជា អង្គការអន្តរជាតិខាងការងារ (ILO), និងកិច្ចព្រមព្រៀងសកលជាមួយនិយោជកអន្តរជាតិ - តាមរបៀបដូចគ្នាដែលសមាជិករបស់យើងធ្វើការដើម្បីសម្រេចបានបទប្បញ្ញត្តិជាតិនិងថ្នាក់តំបន់កាន់តែប្រសើរ, និងកិច្ចព្រមព្រៀងរួមជាមួយនិយោជកនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

ផ្អែកលើលិខិតូឧបករណ៍នានា ដូចជា គោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស, ស្តង់ដារពិភពលោកអាចមានផលជះយ៉ាងខ្លាំង ជាពិសេសនៅក្នុងប្រទេសណាដែលច្បាប់ជាតិមានភាពទន់ខ្សោយ ។

គ្មានវិធីសាស្រ្តណាមួយគ្រប់គ្រាន់នោះទេ ។ យើងត្រូវប្រើប្រាស់ឧបករណ៍ទាំងអស់នៅក្នុងប្រអប់របស់យើង ។ វិធីសាស្រ្ត នៅកន្លែងធ្វើការរួម កិច្ចសន្ទនាសង្គម សកម្មភាពនយោបាយ បទប្បញ្ញត្តិល្អៗ ការអនុវត្តច្បាប់ល្អ ការចរចាអនុសញ្ញារួម និងកូដកម្ម គឺជាការចាំបាច់ទាំងអស់ ។ វាមិនមែនជាសំណួរនៃវិធីសាស្រ្តមួយដែលល្អជាងវិធីមួយទៀតឡើយ ។ ប្រសិនបើគ្មានការមូលមតិគ្នានៅកន្លែងធ្វើការលើតម្រូវការសម្រាប់ឧត្តមភាពសុខភាព និងសុវត្ថិភាពការងារទេនោះ នឹងមិនមាននិយតកម្ម និងការអនុវត្តច្បាប់គ្រប់គ្រាន់ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរនោះឡើយ ។ បើគ្មានច្បាប់ទេ គេគ្មានមធ្យោបាយធ្វើការជាមួយនិយោជកទាំងឡាយដែលមិនមានឆន្ទៈដើម្បីធ្វើឱ្យវិធីសាស្រ្តរួម ទទួលបានជោគជ័យឡើយ ។

# គណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម

គេមិនអាចមើលស្រាលសារៈសំខាន់នៃគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួមបានទេ។ គណៈកម្មាធិការនេះ ផ្តល់សិទ្ធិដល់កម្មករក្នុងការចូលរួមក្នុងការសម្រេចចិត្តទាក់ទងនឹងសុខភាព និងសុវត្ថិភាពការងារ ។ ពួកគេជួយឱ្យសម្រេចបាន "ការទទួលខុសត្រូវផ្ទៃក្នុង" ដែលមានន័យថា និយោជក និងកម្មករមានសមត្ថភាព និងការទទួលខុសត្រូវរួមគ្នា ដើម្បីកំណត់ និងដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពការងារដោយមិនចាំបាច់ពឹងផ្អែកលើស្ថាប័នខាងក្រៅ ។

គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម គឺជាសមិទ្ធផលនៃសកម្មភាពសុខភាព និងសុវត្ថិភាពសហជីព និងការចរចាជាសមូហភាព ។

សិទ្ធិរបស់កម្មករក្នុងការដឹង ការបដិសេធ និងការចូលរួម ត្រូវបានធានាដោយច្បាប់នៅក្នុងប្រទេសជាច្រើន ពីព្រោះប្រសិនបើគ្មានការការពារពីច្បាប់ទេ ពួកគេអាចទទួលរងការគំរាមកំហែង ។ ឧទាហរណ៍ សិទ្ធិក្នុងការបដិសេធការងារដែលគ្មានសុវត្ថិភាពក្រោមច្បាប់ស្តីពីសុខភាពនិងសុវត្ថិភាពការងារ គឺជាការមិនចាំបាច់ក្នុងន័យម្យ៉ាង ពីព្រោះ នៅក្រោមប្រព័ន្ធច្បាប់ភាគច្រើនបំផុត គេយល់ថាមានសិទ្ធិមួយរួចស្រេចទៅហើយដើម្បីការពារជីវិតផ្ទាល់ខ្លួនរបស់អ្នក ។ ទោះជាយ៉ាងណាក៏ដោយការអនុវត្តសិទ្ធិនេះនៅកន្លែងធ្វើការ ត្រូវប្រឈមមុខនឹងហានិភ័យនៃការដាក់វិន័យ ឬការបណ្តេញចេញពីការងារ ។ ដូច្នេះហើយបានជាច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារ ជាទូទៅ ដាក់បញ្ចូលនីតិវិធីមួយទាក់ទងនឹងការអនុវត្តសិទ្ធិរបស់អ្នកដើម្បីបដិសេធការងារដែលគ្មានសុវត្ថិភាព ។ ច្បាប់មានគោលដៅការពារអ្នក ពីការសងសឹកពីសំណាក់និយោជករបស់អ្នក ប្រសិនបើអ្នកអនុវត្តតាមនីតិវិធីនេះ ។

គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ត្រូវបានបង្កើតឡើងដោយសារតែសហជីពបានទាមទារថា អ្នកដែលមានចំណេះដឹងច្រើនបំផុតអំពីមុខសញ្ញាគ្រោះថ្នាក់ និងអ្នកដែលប្រឈមមុខនឹងហានិភ័យដោយផ្ទាល់បំផុត - ពោលគឺកម្មករ - ត្រូវមានសំឡេងនៅក្នុងលក្ខខណ្ឌសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ។ គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ជាអ្នកផ្តល់អត្ថន័យដល់សិទ្ធិរបស់កម្មករក្នុងការចូលរួមក្នុងសុខភាព និងសុវត្ថិភាពការងារ ។ យើងចង់ឱ្យសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការត្រូវបានធ្វើឡើង "ជាមួយ" យើង មិនមែន "ចំពោះ" យើងទេ ។ ហើយមនុស្សតែមួយគត់ដែលមានសិទ្ធិអំណាចខាងសីលធម៌ដើម្បីវាយតម្លៃហានិភ័យ គឺជាអ្នកដែលប្រឈមមុខនឹងហានិភ័យផ្ទាល់ ។

## តើគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម គួរធ្វើអ្វីខ្លះ

កិច្ចការចម្បងរបស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម (ក៏ដូចជាសមាជិករបស់គណៈកម្មាធិការ) គឺដើម្បីកែលម្អការប្រតិបត្តិសុខភាពសុវត្ថិភាព និងបរិស្ថាន - ទាំងបរិយាកាសនៅកន្លែងធ្វើការ និងបរិស្ថានខាងក្រៅ ដោយសារវារងផលប៉ះពាល់ពីប្រតិបត្តិការរបស់ក្រុមហ៊ុន ។ ឧបករណ៍ដែលមានសម្រាប់ប្រើប្រាស់ គឺកិច្ចសន្ទនា និងអនុសាសន៍និងភាពជឿជាក់ ។ តួនាទីចម្បងរបស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម គឺដើម្បីពិភាក្សា បង្កើត ផ្តល់អនុសាសន៍ ជួយអនុវត្ត និងតាមដានមើលការអនុវត្តគោលនយោបាយ កម្មវិធី និងនីតិវិធីសុខភាពនិងសុវត្ថិភាពសមស្រប និងដឹកនាំដោយធ្វើជាគំរូ ។

ទោះយ៉ាងណាក៏ដោយ កម្មករដែលជាសមាជិកនៃគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម គឺជាគណៈកម្មាធិការរបស់សហជីពនៅមូលដ្ឋាន ។ នៅកន្លែងធ្វើការដែលមានសហជីព គឺជាមធ្យោបាយតែមួយគត់ដែលអ្នកអាចមានប្រសិទ្ធភាព ។ សហជីពធ្វើឱ្យការងារកាន់តែមានសុវត្ថិភាព!

## តើគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួមមិនគួរធ្វើអ្វីខ្លះ

- **គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម មិនមែនជាកម្លាំងនគរបាលសុវត្ថិភាពនៅកន្លែងធ្វើការទេ ។**
- **គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម មិនមែនជាគណៈកម្មការរៀបចំផែនការ និងថវិការបស់ក្រុមហ៊ុនទេ ។ ការកែតម្រូវមុខសញ្ញាគ្រោះថ្នាក់សុខភាព និងសុវត្ថិភាពជួនកាលអាចត្រូវចំណាយច្រើន ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម មិនមានតួនាទីក្នុងការផ្តល់អាទិភាពដល់វិធានការសុខភាព និងសុវត្ថិភាពក្នុងចំណោមអាទិភាពហិរញ្ញវត្ថុផ្សេងៗទៀតរបស់ក្រុមហ៊ុននោះទេ ។**

## តួនាទីគ្រប់គ្រង

នៅកន្លែងធ្វើការ អ្នកគ្រប់គ្រងមានសិទ្ធិអំណាចផ្លូវការ និងទំនួលខុសត្រូវចំពោះសុខភាព និងសុវត្ថិភាពការងារ ។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិអំណាច និងទំនួលខុសត្រូវនេះ មានការផ្លាស់ប្តូរដោយសារតែពួកគេមានទំនួលខុសត្រូវផ្អែកច្បាប់ ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ។ អ្នកគ្រប់គ្រងមិនត្រូវបានតម្រូវឱ្យទទួលយករាល់អនុសាសន៍របស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមនោះទេ ប៉ុន្តែពួកគេមានកាតព្វកិច្ចឆ្លើយតប ។ អ្នកគ្រប់គ្រងណាដែលមិនអើពើចំពោះមតិយោបល់របស់គណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម អាចមានន័យថារំលោភដោយផ្ទាល់ទៅលើច្បាប់ និងបទប្បញ្ញត្តិស្តីពីសុខភាព និងសុវត្ថិភាពការងារ ហើយក៏អាចនឹងធ្លាក់នៅក្នុងការធ្វើតេស្តនៃ "កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ (due diligence)" (ដែលត្រូវបានកំណត់ថា ជាការចាត់វិធានការប្រុងប្រយ័ត្នគ្រប់ជំហានដែលមានលក្ខណៈសមហេតុផល ឬអាចធ្វើទៅបានក្នុងគ្រប់កាលៈទេសៈ) ប្រសិនបើគ្រោះថ្នាក់ណាមួយកើតឡើង ។

សិទ្ធិ ទំនួលខុសត្រូវ និងតួនាទីរបស់គណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម ត្រូវបានអនុវត្តរួមគ្នាដោយសហជីព និងដោយអ្នកគ្រប់គ្រង ។ សមាជិកនៃគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម មិនគួរធ្វើសកម្មភាពឯកតោភាគីឡើយ លើកលែងតែក្នុងករណីដើម្បីកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ភ្លាមៗ ។ ល្អបំផុត មិនគួរមានគោលនយោបាយ ឬកម្មវិធីក្នុងវិស័យសុខភាពនិងសុវត្ថិភាពការងារនៅកន្លែងធ្វើការឡើយ លើកលែងតែកម្មវិធីឬគោលនយោបាយណាដែលមានការឯកភាពពីគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ។

ច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារ ក៏តម្រូវឱ្យនិយោជកមានទំនួលខុសត្រូវក្នុងការអនុវត្តបទបញ្ជាផ្ទៃក្នុង និងស្តង់ដារ ផងដែរ ។ ផ្នែក

សុវត្ថិភាពរោងចក្រ និងអ្នកត្រួតពិនិត្យជួរទីមួយមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តកិច្ចការនេះ ។ "ការអនុវត្ត" គួរតែត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ហើយមិនសុទ្ធតែមានន័យថាជាវិធានការវិន័យនោះទេ ។ ការដាក់វិន័យ និងការដកហូតតួនាទីដើម្បីសម្រេចបានលទ្ធផលសុខភាព និងសុវត្ថិភាព ជាធម្មតា គឺមិនអាចសម្រេចបានលទ្ធផលដែលចង់បាននោះទេ។ ផ្ទុយទៅវិញ វាធ្វើឱ្យអ្នកគ្រប់គ្រងមិនអាចដឹងអំពីបញ្ហា និងមិនដែលរកឃើញមូលហេតុពិតប្រាកដនៃគ្រោះថ្នាក់នោះឡើយ ។ វារុញបញ្ហាសុខភាព និងសុវត្ថិភាពទៅក្នុងសៃរៀនមួយផ្សេងទៀត ៖ ទំនាក់ទំនងការងារ បណ្ដឹងសាទុក្ខ និងអាជ្ញាកណ្ដាល ជាជាងការកែលម្អលក្ខខណ្ឌសុខភាព និងសុវត្ថិភាព ។

បុគ្គលិក និងអ្នកគ្រប់គ្រងម្នាក់ៗ អាចប្រព្រឹត្តដោយសុវត្ថិភាព ឬគ្មានសុវត្ថិភាព ប៉ុន្តែការប្រតិបត្តិសុខភាព និងសុវត្ថិភាពរបស់អង្គការ/ស្ថាប័ន (ជាពិសេសនៅក្នុងអង្គការធំៗ) គឺមានភាពពាក់ព័ន្ធនឹងលទ្ធផលរួមនៃគុណតម្លៃ និងសកម្មភាពរបស់អង្គភាពទាំងមូល ("វប្បធម៌សុវត្ថិភាពសាជីវកម្ម") ច្រើនជាងសកម្មភាពបុគ្គល ។

ការរឹតបន្តឹងវិន័យ និងការគំរាមកំហែងដល់បុគ្គល មិនមែនជាមធ្យោបាយដ៏ល្អបំផុតដើម្បីសម្រេចបានការអនុវត្តកាន់តែប្រសើរឡើងនោះឡើយ ។ ប៉ុន្តែការអប់រំ និងកិច្ចសហប្រតិបត្តិការគឺជាវិធីដែលប្រសើរជាង ។ វិធានការបង្ការល្អ តម្រូវឱ្យមានប្រព័ន្ធទទួលខុសត្រូវផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ។ ការធ្វើឱ្យប្រសើរឡើងនៃការប្រតិបត្តិសុខភាព សុវត្ថិភាព និងបរិស្ថាន ជាធម្មតា តម្រូវឱ្យមានការផ្លាស់ប្ដូរទៅលើស្ថាប័ន មិនមែនការផ្លាស់ប្ដូរចំពោះបុគ្គលនោះទេ ។

## រចនាសម្ព័ន្ធនៃគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម

### ប្រព័ន្ធទំនួលខុសត្រូវផ្ទៃក្នុង

| សុខភាព និងសុវត្ថិភាព | ទំនួលខុសត្រូវ |
|---|---|
| **អ្នកគ្រប់គ្រងជាន់ខ្ពស់**<br>ករណីយកិច្ចត្រូវឆ្លើយតប<br>កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់<br>(due diligence)<br>ទំនួលខុសត្រូវ<br>គណនេយ្យភាព | សិទ្ធិអំណាចផ្លូវការ |
| **សហប្រធាន គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម**<br>សកម្មភាព និងប្រតិភូកម្ម<br>ចាត់ចែងការប្រជុំ<br>ប្រគល់ភារកិច្ច សកម្មភាព ចំណុចរបៀបវារៈ<br>ធានាការតាមដានបន្ត | ការកំណត់របៀបវារៈ |
| **គណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម**<br>គោលនយោបាយសុខភាពនិងសុវត្ថិភាព<br>កម្មវិធីសុខភាពនិងសុវត្ថិភាព<br>នីតិវិធីសុខភាពនិងសុវត្ថិភាព<br>ផ្ដល់អនុសាសន៍ដល់អ្នកគ្រប់គ្រងជាន់ខ្ពស់ | ក្រុម/អង្គតំណាង |
| **ផ្នែក/នាយកដ្ឋានសុវត្ថិភាព**<br>អ្នកត្រួតពិនិត្យការងារផ្ទាល់<br>គ្រប់គ្នា | រដ្ឋបាល/ការអនុវត្ត |

## កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ (DUE DILIGENCE)

ដោយសារវាជាឃ្លាដែលតែងតែកើតឡើងនៅក្នុងការពិភាក្សាអំពីទំនួលខុសត្រូវផ្ទៃក្នុង នេះគឺជាទីកន្លែងដ៏សមស្របមួយដើម្បីពិភាក្សាអំពីគោលគំនិតនៃកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ។

កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ គឺជាការការពារផ្នែកច្បាប់មួយ ។ នៅក្រោមច្បាប់ស្ដីពីសុខភាព និងសុវត្ថិភាពការងារ ប្រសិនបើនិយោជកអាចបញ្ជាក់យ៉ាងច្បាស់ថា ពួកគេបានអនុវត្តកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ដោយត្រឹមត្រូវ នោះមានន័យថា ពួកគេបានចាត់វាល់វិធានការប្រុងប្រយ័ត្នដែលសមស្របទៅតាមគ្រប់កាលៈទេសៈ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តាមរយៈការប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ជាប្រព័ន្ធការពារមួយ ច្បាប់ក៏បង្កប់ន័យដែរថា វានឹងក្លាយជាស្តង់ដារមួយនៃការអនុវត្តសុវត្ថិភាពប្រចាំថ្ងៃ ។

សំណួរសួរថា តើអ្នកបង្កើត "កិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់" ដោយរបៀបណា? ការបញ្ជាក់ថា អ្វីមួយត្រូវបានធ្វើរួច មានការលំបាកជាងការបញ្ជាក់ថា អ្វីមួយមិនទាន់បានធ្វើ ។

ក្នុងករណីនានា ដូចជាមានរបួសធ្ងន់ធ្ងរ ឬស្លាប់ និយោជកត្រូវតែបង្ហាញពីការខិតខំប្រឹងប្រែងគ្រប់ពេលដើម្បីទប់ស្កាត់ឧប្បត្តិហេតុបែបនេះ ។ ដើម្បីបង្ហាញពីកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និយោជកត្រូវតែបង្ហាញពីការប្ដេជ្ញាចិត្តទាំងស្រុងចំពោះសុខភាព និងសុវត្ថិភាព ។

ប្រព័ន្ធសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ត្រូវតែមានលក្ខណៈទូលំទូលាយ បំពេញតម្រូវការរបស់កម្មករ និងត្រូវតែមានដំណើរការ ។ ការគ្រាន់តែបង្ហាញពីគោលនយោបាយដែលស្ដាប់ទៅដូចជាល្អលើក្រដាស មិនបង្ហាញពីកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់នោះទេ ។ មានតែភស្តុតាងរឹងទេ ក្នុងទម្រង់ជាការចុះត្រួតពិនិត្យ និងសវនកម្មជាទៀងទាត់ ដែលធ្វើឡើងដោយគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម និងភស្តុតាងនៃការតាមដានបន្តលើអនុសាសន៍របស់គណៈកម្មាធិការ អាចបង្ហាញថា មានការអនុវត្តជាក់ស្ដែង មិនមែនគ្រាន់តែជាពាក្យសំដីប៉ុណ្ណោះទេ ។

ឧទាហរណ៍ ប្រសិនបើគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួមកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់ណាមួយ ហើយស្នើឡើងនូវមធ្យោបាយសម្រាប់គ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់នោះ ហើយប្រសិនបើអ្នកគ្រប់គ្រងមិនចាត់វិធានការទេ មានន័យថា ពួកគេមិនបានអនុវត្តកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ឡើយ ។

# ការកំណត់អត្តសញ្ញាណ និង ការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់

នៅពេលព្យាយាមបង្កើតវិធានការគ្រប់គ្រងដែលល្អបំផុតសម្រាប់មុខសញ្ញាគ្រោះថ្នាក់នៅកន្លែងធ្វើការ ជាការសំខាន់ដែលត្រូវយល់ ៖

1. លក្ខណៈនៃមុខសញ្ញាគ្រោះថ្នាក់
2. ទម្រង់នៃមុខសញ្ញាគ្រោះថ្នាក់
3. របៀបដែលកម្មករប៉ះពាល់នឹងមុខសញ្ញាគ្រោះថ្នាក់ (ប្រសិនបើជាមុខសញ្ញាគ្រោះថ្នាក់គីមី ផ្លូវដែលចូលទៅក្នុងរាងកាយ)
4. ប្រភេទនៃផលប៉ះពាល់ (របួស ឬជំងឺ) ដែលមុខសញ្ញាគ្រោះថ្នាក់អាចបង្កឡើង
5. តើមានព័ត៌មានអ្វីខ្លះអំពីវិធានការបង្ការរបួសនិងបង្ការគ្រោះថ្នាក់ប្រកបដោយប្រសិទ្ធភាព និង
6. វិធីល្អបំផុតដើម្បីគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់

ផ្នែកខាងក្រោមនេះ បង្ហាញពីមុខសញ្ញាគ្រោះថ្នាក់មួយចំនួនដែលសមាជិកសហជីពជាច្រើនជួបប្រទះ ។ នេះគ្រាន់តែជាមុខសញ្ញាគ្រោះថ្នាក់មួយចំនួនប៉ុណ្ណោះ ។

## សារធាតុគីមីពុល

ចូរពិចារណាតារាងខាងក្រោម ។ (ពាក្យពេចន៍ដែលប្រើក្នុងតារាងនេះត្រូវបានពន្យល់លម្អិតនៅក្នុងសទ្ទានុក្រមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ។)

| លក្ខណៈ | ទម្រង់ | ផ្លូវចូល | ផលប៉ះពាល់ | ព័ត៌មាន | ការគ្រប់គ្រង |
|---|---|---|---|---|---|
| ជាតិពុល<br>សារធាតុអាឡែស៊ី (sensitizer)<br>សារធាតុបន្ថយអុកស៊ីសែនក្នុងខ្យល់ (asphyxiant)<br>សារធាតុកាត់ (Corrosive)<br>សារធាតុបង្កមហារីក<br>សារធាតុបំលែង(Mutagen)<br>សារធាតុតេរ៉ាតូជែន (Teratogen)<br>សារធាតុជំរុញចំហេះ (Oxidizer)<br>សារធាតុជំរុញប្រតិកម្ម (Reactive)<br>សារធាតុអាចបង្កចំហេះ (Flammable)<br>សារធាតុផ្ទុះ (Explosive)<br>សារធាតុវិទ្យុសកម្ម (Radioacive) | រឹង<br>រាវ<br>ឧស្ម័ន<br>ធូលី<br>សន្សើម<br>ផ្សែង | ហឺតចូល<br>លេបចូល<br>ជ្រាបចូល | ប្រព័ន្ធ<br>សរីរាង្គ<br>កោសិកា<br>ម៉ូលេគុល<br><br>ស្រួចស្រាល់<br>រ៉ាំរ៉ៃ<br>សម្ងំយូរ<br>បង្ករ<br>ប្រតិកម្មបន្ថែម | MSDS<br>លក្ខណៈសម្គាល់<br>ជាតិពុលវិទ្យា<br>ស្តង់ដារ<br>លេខកូដ | › នៅត្រង់ប្រភពផ្ទាល់<br>› ជាបន្តបន្ទាប់<br>› នៅជាមួយកម្មករផ្ទាល់<br><br>អនុសាសន៍<br>អនុវត្ត<br>ពិនិត្យឡើងវិញ |

ប្រសិនបើអ្នកព្រួយបារម្ភអំពីសារធាតុគីមីពុលនៅកន្លែងធ្វើការរបស់អ្នក សូមព្យាយាមវិភាគបញ្ហា និងដាក់ចេញនូវវិធានការឆ្លើយតបសមស្របមួយ ដោយធ្វើការទៅលើជួរឈរខាងឆ្វេងបំផុតនៃតារាងខាងលើ ទៅខាងស្តាំបំផុត ។

**ធម្មជាតិ** ៖ កំណត់ថាតើមុខសញ្ញាគ្រោះថ្នាក់អ្វីខ្លះដែលបង្កឡើងដោយសារធាតុគីមី ។ ទាំងនេះគឺជាលក្ខណៈនៃសារធាតុគីមីនោះ ។

**ទម្រង់** ៖ តើវាបញ្ចេញនៅកន្លែងធ្វើការក្នុងទម្រង់បែបណា? ការដឹងពីទម្រង់ នឹងជួយអ្នកវាយតម្លៃសក្តានុពលនៃការប៉ះពាល់ ។

**ផ្លូវចូល** ៖ តើសារធាតុគីមីចូលក្នុងខ្លួនដោយរបៀបណា?

**ផលប៉ះពាល់** ៖ តើសរីរាង្គឬប្រព័ន្ធអ្វីខ្លះដែលរងផលប៉ះពាល់ជាទូទៅ? តើជាទូទៅ ជំងឺមានការកើតឡើងយ៉ាងដូចម្តេច?

**ព័ត៌មាន** ៖ ប្រមូលព័ត៌មានអំពីសារធាតុគីមីនោះឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ ចំណុចចាប់ផ្តើមដ៏ល្អមួយ គឺក្រដាសទិន្នន័យសុវត្ថិភាពរបស់សារធាតុនោះ ។

**ការគ្រប់គ្រង** ៖ ការអនុវត្តអនាម័យឧស្សាហកម្មល្អ ។ តើមានមធ្យោបាយគ្រប់គ្រងជំនួស ដែលអាចប្រើបានដែរឬទេ?

## មុខសញ្ញាគ្រោះថ្នាក់គ្រឿងម៉ាស៊ីន

បរិក្ខារ ឧបករណ៍ យានជំនិះ ឬវត្ថុទាំងឡាយណាដែលមានចលនា អាចបង្កគ្រោះថ្នាក់ ។ កម្មកររាប់រយពាន់នាក់ទទួលរងរបួសដោយការមុត ឬការប៉ះពារជារៀងរាល់ឆ្នាំ ។ ជួនកាល ការដែលកម្មករយល់ឃើញថាពួកគេស្គាល់ពីប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់ទាំងនេះ អាចធ្វើឱ្យពួកគេមានការធ្វេសប្រហែស ។

ការការពារម៉ាស៊ីនឱ្យបានត្រឹមត្រូវ គឺជាការសំខាន់ណាស់ ។ ការជ្រើសរើស និងការប្រើប្រាស់ឧបករណ៍ដែលប្រើថាមពលអគ្គិសនី មានសារៈសំខាន់ណាស់ ។ ចលនានិងការគ្រប់គ្រងយានយន្ត និងថ្មើរជើងនៅកន្លែងធ្វើការ មានសារៈសំខាន់ ។ ជាសំណាងល្អ ចំណុចទាំងអស់នេះក៏ជាប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់ដែលងាយស្រួលបំផុតក្នុងការកំណត់អត្តសញ្ញាណ និងកែតម្រូវក្នុងអំឡុងពេលចុះអធិការកិច្ចនៅកន្លែងធ្វើការ ។

ជារឿយៗ មុខសញ្ញាគ្រោះថ្នាក់គ្រឿងម៉ាស៊ីនបង្កឱ្យមានរបួសក្នុងពេលប្រើប្រាស់ដែលមិនគោរពតាមស្តង់ដារ ដូចជា មិនមានការកែតម្រូវតំហែទាំ និងការជួសជុលឧបករណ៍ ។ គោលបំណងនៃនីតិវិធីចាក់សោគឺដើម្បីធានាថា ថាមពលត្រូវបានផ្តាច់ចេញទាំងស្រុងពីបរិក្ខារ ។

នីតិវិធីនៃការចាក់សោត្រូវតែត្រូវធ្វើការពិនិត្យឡើងវិញ និងសវនកម្មជាទៀងទាត់ ដើម្បីធានាថា វាមានប្រសិទ្ធភាពបំផុតតាមដែលអាចធ្វើទៅបាន ហើយថា គ្រប់គ្នាយកចិត្តទុកដាក់អនុវត្តតាមនីតិវិធីនេះ ។ ប្រភពថាមពលទាំងអស់ត្រូវតែកំណត់អត្តសញ្ញាណ ដាក់ដាច់ដោយឡែក ចាក់សោ និងផ្ទៀងផ្ទាត់ នៅពេលរៀបចំឧបករណ៍សម្រាប់ការថែទាំ ។

ទោះបីជានីតិវិធីនេះមានលក្ខណៈសាមញ្ញគ្រប់គ្រាន់ជាគោលការណ៍ក្តី ប៉ុន្តែ ជួនកាលគេពិបាកថែរក្សាថាមពលដែលនៅសល់ និងធានាមិនឱ្យមានការបញ្ចេញថាមពលដោយចៃដន្យណាមួយ ។ សូម្បីតែនៅពេលដែលឧបករណ៍ត្រូវបានរៀបចំរួចរាល់សម្រាប់ការថែទាំក៏ដោយ ក៏សុវត្ថិភាពរបស់ឧបករណ៍នោះត្រូវតែធ្វើការផ្ទៀងផ្ទាត់ ហើយគេត្រូវតែផ្តល់ព័ត៌មានច្បាស់លាស់អំពីស្ថានភាពរបស់ឧបករណ៍ដល់ភាគីពាក់ព័ន្ធទាំងអស់ ។

នីតិវិធីចាក់សោរល្អ គឺប្រើគោលគំនិត "កម្មករម្នាក់ មេសោមួយ កូនសោមួយ" ។ ពោលគឺ បុគ្គលម្នាក់ៗផ្ទៀងផ្ទាត់ស្ថានភាពរបស់ឧបករណ៍ដោយប្រើសោផ្ទាល់ខ្លួនរបស់ពួកគេ ។

## អគ្គិសនី

ការប្រើប្រាស់អគ្គិសនីជាសកលនៅក្នុងសង្គមរបស់យើង មានទំនោរបង្កើតការព្រងើយកន្តើយចំពោះមុខសញ្ញាគ្រោះថ្នាក់របស់វា ប៉ុន្តែ អគ្គិសនីអាចបណ្តាលឆក់ រលាកធ្ងន់ធ្ងរ និងស្លាប់ ។ វាក៏អាចផ្តល់ជាប្រភពបញ្ឆេះដែលបង្កជាអគ្គិភ័យ និងការផ្ទុះផងដែរ ។ គោលការណ៍ណែនាំទូទៅនេះ អាចផ្តល់ការរំលឹកអំពីរបៀបពិចារណាមុខសញ្ញាគ្រោះថ្នាក់អគ្គិសនីនៅកន្លែងធ្វើការ ៖

- **ការងារអគ្គិសនីគួរតែមានការរៀបចំផែនការជាមុនល្អ ឯកសារត្រឹមត្រូវ បរិក្ខារនិងឧបករណ៍ត្រឹមត្រូវ**
- **នីតិវិធីចាក់សោរត្រឹមត្រូវ គឺចាំបាច់សម្រាប់ការងារអគ្គិសនីប្រកបដោយសុវត្ថិភាព**
- **បរិក្ខារដែលមានវ៉ុលតាខ្ពស់ គួរតែត្រូវបានចាត់ចែងដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលជាក់លាក់តែប៉ុណ្ណោះ បើមិនដូច្នោះទេ ត្រូវស្ថិតនៅឱ្យឆ្ងាយពីបរិក្ខារទាំងនេះ**
- **សម្លៀកបំពាក់ ឧបករណ៍ និងបរិក្ខារដែលមិនចម្លងចរន្តអគ្គិសនី គឺជាស្រទាប់ការពារចុងក្រោយមួយ ។**
- **ពិចារណាអំពីមុខសញ្ញាគ្រោះថ្នាក់អគ្គិសនីនៅពេលប្រើជណ្តើរ ជណ្តើរយន្ត ដងស្ទូច ឬបរិក្ខារដែលអាចលើកឡើងបាន**
- **ប្រើតែបរិក្ខារអគ្គិសនីដែលបានអនុញ្ញាតឱ្យប្រើប៉ុណ្ណោះ**
- **កុំប្រើបរិក្ខារដែលខូចខ្សែ ឬឌុយតំណ ។**
- **ការដំឡើងអគ្គិសនីបណ្តោះអាសន្ន គួរតែមាន "កាលបរិច្ឆេទផុតកំណត់", កាលបរិច្ឆេទច្បាស់លាស់សម្រាប់ការដកចេញ ។**
- **កុំប្រើបរិក្ខារអគ្គិសនីណាដែលមិនមានសុវត្ថិភាពក្នុងការប្រើ**
- **ស្វែងរកខ្សែភ្លើងដែលកប់ក្នុងដីឱ្យឃើញជាមុនសិន មុនពេលជីកដី**
- **កុំប្តូរហ្វ៊ុយហ្ស៊ីប ឬដាក់ឡើងវិញនូវសៀគ្វីផ្តាច់ចរន្តរ ប្រសិនណាបើអ្នកមិនដឹងពីមូលហេតុដែលវាឆេះ ឬដាច់, ហើយ**
- **គ្រឿងបន្លាស់ សូម្បីតែអំពូលភ្លើង ក៏គួរតែត្រូវគ្នានឹងស្តង់ដាររចនាដើមដែរ ។**

## ការបញ្ចេញវិទ្យុសកម្ម

ការបញ្ចេញវិទ្យុសកម្មគឺជាថាមពលឆ្លងកាត់ ជាថាមពលដែលអាចធ្វើដំណើរក្នុងចម្ងាយខ្លះពីប្រភពរបស់វា ដោយគ្មានមធ្យោបាយបញ្ជូន ។ យើងទាំងអស់គ្នា ប៉ះពាល់នឹងវិទ្យុសកម្មដែលមានប្រភេទផ្សេងៗគ្រប់ពេល - ពោលគឺ ពីកំដៅ ពន្លឺភ្លើង ឧបករណ៍អេឡិចត្រូនិក ព្រះអាទិត្យ វិទ្យុសកម្មដែលកើតឡើងតាមធម្មជាតិ ។ល។ - ប៉ុន្តែក្នុងកម្រិតទាប ។

## វិសាលគមអេឡិចត្រូម៉ាញ៉េទិក

លើកលែងតែករណីមួយចំនួន ថាមពលភាគច្រើនដែលយើងហៅថា "វិទ្យុសកម្ម" គឺជាផ្នែកមួយនៃវិសាលគមអេឡិចត្រូម៉ាញ៉េទិក ។ "វិសាលគមអេឡិចត្រូម៉ាញ៉េទិក" គឺជាដែនថាមពលពីប្រេកង់ទាប (ឧទា. វិទ្យុ AM) រហូតដល់ថាមពលខ្ពស់ (ការបញ្ចេញវិទ្យុសកម្មហ្គាម៉ា) ។ គេគួរចងចាំថា អគ្គិសនីតែងតែបង្កើតដែនអគ្គិសនីនិងដែនម៉ាញេទិក ។ នៅខាងចុងប្រេកង់ទាបនៃវិសាលគមអេឡិចត្រូម៉ាញ៉េទិក (ជាពិសេសសំដៅលើមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាននៃប្រដាប់ប្រដាអគ្គិសនីក្នុងផ្ទះ ឧបករណ៍កុំព្យូទ័រ ។ល។) "ដែន" គឺជាការពិពណ៌នាដែលសមស្របជាង "វិទ្យុសកម្ម" ។ សំណួរជុំវិញមុខសញ្ញាគ្រោះថ្នាក់នៃដែនអេឡិចត្រូម៉ាញ៉េទិកដែលមានប្រេកង់ទាបបំផុតទាំងនេះ គឺជាប្រធានបទដាច់ដោយឡែកមួយ ។

ប្រេកង់វិទ្យុ និងវិទ្យុសកម្មមីក្រូវ៉េវ ជ្រៀតចូលពេញរាងកាយរបស់យើងរៀងរាល់នាទីរៀងរាល់ថ្ងៃ ដោយសារការប្រើប្រាស់សម្ភារៈទាំងនេះនៅក្នុងការផ្សាយតាមវិទ្យុ និងទូរទស្សន៍ ទូរសព្ទចល័ត ឆ្នាំងកម្ដៅមីក្រូវ៉េវ និងរ៉ាដា ។

ការប៉ះពាល់កាន់តែខ្លាំងថែមទៀតអាចកើតឡើងជាមួយឧបករណ៍កំដៅឧស្សាហកម្មនៃការតភ្ជាប់ឌីអេឡិចទ្រិក និងប្រភេទមីក្រូវ៉េវ និងការព្យាបាលជំងឺដោយចរន្តអគ្គិសនី ។ ប្រេកង់វិទ្យុ និងវិទ្យុសកម្មមីក្រូវ៉េវអាចដុតកំដៅជាលិកា និងបង្កឱ្យរលាក ។ គេយល់ឃើញផងដែរថាសមត្ថភាពផលិតកំដៅរបស់វា អាចបណ្ដាលឱ្យមានជំងឺបាយភ្នែក និងផលប៉ះពាល់ដល់ប្រព័ន្ធបន្តពូជ ។ បន្ថែមពីលើផលប៉ះពាល់ដោយកម្ដៅបែបនេះ ថាមពលទាំងនេះត្រូវបានគេសង្ស័យថា មានផលប៉ះពាល់ទៅលើប្រព័ន្ធសរសៃប្រសាទកណ្ដាល សរសៃឈាមបេះដូង និងភាពតានតឹង(ស្រ្តេស)ទូទៅ ។ លើសពីនេះទៀត ការឆក់ និងរលាកដោយប្រេកង់វិទ្យុ ក៏ដូចជាការរំខានទៅលើការតំណភ្ជាប់ទំនាក់ទំនងសញ្ញាជីវិតអាចត្រូវបានចាត់ទុកថាជាមុខសញ្ញាគ្រោះថ្នាក់សុវត្ថិភាព ។

វិទ្យុសកម្មអ៊ីនហ្វ្រារ៉េដ ត្រូវបានបញ្ចេញដោយវត្ថុធាតុដែលរលាយដោយសារកម្ដៅ ដូចជាលោហៈ និងកែវ ។ ម៉ាស៊ីនកម្ដៅអ៊ីនហ្វ្រារ៉េដ និងឆ្នាំងរក្សាកម្ដៅ គឺជាប្រភពផ្សេងទៀតដែលកម្មករប៉ះពាល់ជាមួយ ។

ពន្លឺដែលអាចមើលឃើញគឺជាអ្វីដែលយើងទាំងអស់គ្នាប៉ះពាល់រាល់ថ្ងៃពីពន្លឺសិប្បនិម្មិត និងពីព្រះអាទិត្យ ។

កាំរស្មីអ៊ុលត្រាវីយូឡេ (ពណ៌ស្វាយ) ត្រូវបានបញ្ចេញមិនត្រឹមតែដោយព្រះអាទិត្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយចង្កៀងពន្លឺព្រះអាទិត្យនិងឧបករណ៍ស្នេរីលឧស្សាហកម្ម ផងដែរ ។

ពន្លឺផ្សារដែក គឺជាប្រភពពន្លឺអ៊ុលត្រាវីយូឡេដ៏ខ្លាំងក្លាមួយ ។

កាំរស្មីអ៊ីនហ្វ្រារ៉េដ ពន្លឺដែលអាចមើលឃើញដោយភ្នែក និងកាំរស្មីពណ៌ស្វាយ អាចបង្ក ឬធ្វើកាន់តែធ្ងន់ធ្ងរនូវជំងឺរលាកផ្នែកដោយសារពន្លឺពណ៌ស្វាយ, ជំងឺភ្នែកក្រហម, ជំងឺបាយភ្នែក, រលាកស្បែក, ស្បែកចាស់មុនអាយុ និងមហារីកស្បែក ។ ពន្លឺឡាស៊ែរក៏បង្កផលវិបាកធ្ងន់ធ្ងរផងដែរ ដោយសារតែកំហាប់ដ៏ខ្ពស់នៃរលកពន្លឺតែមួយ ។ ឡាស៊ែរត្រូវបានប្រើប្រាស់កាន់តែច្រើននៅកន្លែងធ្វើការ ជាឧបករណ៍ស្កេន ឧបករណ៍ស្ទង់ និងនៅក្នុងការផ្សារ និងកាត់ដែក ។

ខាងចុងថាមពលខ្ពស់នៃដែនពន្លឺពណ៌ស្វាយ បូកនឹងកាំរស្មីអ៊ិច និងវិទ្យុសកម្មហ្គាម៉ា ត្រូវបានហៅថា "វិទ្យុសកម្មអ៊ីយ៉ូដ" ។ វិទ្យុសកម្មអ៊ីយ៉ូដ គឺជាវិទ្យុសកម្មដែលមានថាមពលខ្ពស់អាចបង្កើតជាភាគល្អិតដែលមានថាមពល ។

កាំរស្មីអ៊ិក និងកាំរស្មីហ្គាម៉ា គឺជាវិទ្យុសកម្មអេឡិចត្រូម៉ាញ៉េទិកដែលមានថាមពលខ្ពស់ ។ វាមានសមត្ថភាពជ្រៀតចូលយ៉ាងខ្លាំង ពោលគឺវាមានលក្ខណៈពិសេសមួយសម្រាប់ប្រើប្រាស់នៅក្នុងវិស័យវេជ្ជសាស្ត្រ និងវាឆ្លងកាត់រាងកាយបានយ៉ាងងាយបំផុត ។ កាំរស្មីហ្គាម៉ា ត្រូវបានផលិតដោយសារធាតុវិទ្យុសកម្មជាច្រើន និងមានថាមពលខ្ពស់ជាងកាំរស្មីអ៊ិក ។ មនុស្សគ្រប់រូបមានការប៉ះពាល់ទៅនឹងវិទ្យុសកម្មអ៊ីយ៉ូដ, ពីលំហ ពីវត្ថុធាតុវិទ្យុសកម្មនៅក្នុងដី ថែមទាំងពីរាងកាយផ្ទាល់របស់យើងផងដែរ ដោយហេតុថាយើងទាំងអស់គ្នាមានកាបូន-១៤ វិទ្យុសកម្មក្នុងបរិមាណជាក់លាក់ ។ វិទ្យុសកម្មវេជ្ជសាស្ត្រ ដូចជាកាំរស្មីអ៊ិក និងវិទ្យុសកម្មដែលប្រើក្នុងការព្យាបាលជំងឺមហារីក និងជំងឺផ្សេងៗទៀត ធ្វើឱ្យមានការប៉ះពាល់បន្ថែមទៀតផងដែរ ។

## ភាគល្អិតវិទ្យុសកម្ម

គឺជាអ្វីដែលត្រូវបានគេហៅជាទូទៅថាជា "វិទ្យុសកម្ម" ។ តាមពិត វាគឺជាភាគល្អិតដែលបញ្ចេញដោយសារធាតុវិទ្យុសកម្ម ដែលជាផ្នែកមួយនៃដំណើរការធម្មជាតិនៃការពុករលួយអាតូម ។

ភាគល្អិតអាល់ហ្វា គឺជាបំណែកល្អិតៗដែលធ្ងន់, មានបន្ទុកវិជ្ជមានបញ្ចេញដោយដំណើរការវិទ្យុសកម្មនានា ដូចជាការពុកផុយនៃអ៊ុយរ៉ាញ៉ូម ។ តាមពិតភាគល្អិតអាល់ហ្វា គឺជាស្រោមស្នូលអេលីយ៉ូមដែលមានប្រូតុងពីរ និងណឺត្រុងពីរ ប៉ុន្តែមិនមានអេឡិចត្រុងទេ ។ ទោះបីជាធ្ងន់និងផ្ទុកថាមពលខ្ពស់ក្តី វាមិនអាចជ្រាបចូលទៅក្នុងជាលិការាងកាយបានទេ ។

ភាគល្អិតបេតាគឺជាអេឡិចត្រុងដែលមានថាមពលខ្ពស់ ។ ភាគល្អិតនេះក៏ត្រូវបានញេញដោយដំណើរការវិទ្យុសកម្មផងដែរ ។ ជាទូទៅ វាអាចជ្រៀតចូលទៅក្នុងជាលិការហូតដល់ ២ សង់ទីម៉ែត្រ ។

នឺត្រុងគឺជាភាគល្អិតដែលគ្មានបន្ទុក ដែលត្រូវបានបញ្ចេញនៅក្នុងដំណើរការវិទ្យុសកម្មមួយខ្លះផងដែរ ។ វាមានសមត្ថភាពជ្រៀតចូលយ៉ាងខ្លាំង និងមានលក្ខណៈបន្ថែមដែលអាចធ្វើឱ្យសារធាតុផ្សេងទៀតបញ្ចេញវិទ្យុសកម្ម ។

## ការប៉ះពាល់របស់កម្មករទៅនឹងវិទ្យុសកម្ម និងសារធាតុវិទ្យុសកម្ម

នៅក្នុងឧស្សាហកម្ម ការជីកយករ៉ែ និងចម្រាញ់សារធាតុអ៊ុយរ៉ាញ៉ូម ការផលិតប្រេងឥន្ធនៈ និងម៉ាស៊ីនរ៉េអាក់ទ័រថាមពល គឺជាប្រភពជាក់ស្តែងនៃការប៉ះពាល់ ។ ការថតកាំរស្មីក្នុងឧស្សាហកម្ម ការប្រើភ្លើងបំភ្លឺ ការផលិតអ៊ីសូតូបវិទ្យុសកម្ម និង ការស្រាវជ្រាវមន្ទីរពិសោធន៍ជាប្រភេទផ្សេងៗ ក៏ជាមុខរបរដែលអាចប៉ះពាល់ផងដែរ ក៏ដូចជាការងារដែលពាក់ព័ន្ធនឹងការជីកយករ៉ែក្រៅពីអ៊ុយរ៉ាញ៉ូម និងការផលិតជីផូស្វាត ។

ចំពោះកាំរស្មីអ៊ិច កាំរស្មីហ្គាម៉ា ភាគល្អិតបេតា និងណឺត្រុង ផ្លូវចូលសំខាន់គឺពីខាងក្រៅ ពោលគឺ នៅពេលនរណាម្នាក់ឈរនៅជិតប្រភពវិទ្យុសកម្ម និងប៉ះពាល់ ។

ទោះជាយ៉ាងណាក៏ដោយ សម្រាប់ភាគល្អិតអាល់ហ្វា ការប៉ះពាល់ខាងក្នុងគឺជាបញ្ហាព្រួយបារម្ភយ៉ាងខ្លាំង ។ ឧទាហរណ៍ ប្រសិនបើសារធាតុដែលបញ្ចេញភាគល្អិតអាល់ហ្វា ត្រូវបានយឺតចូលជាធូលីដី ហើយចូលទៅក្នុងសួត ជាលិកាជុំវិញសារធាតុនោះ នឹងទទួលនូវកម្រិតវិទ្យុសកម្មយ៉ាងខ្លាំងបំផុត ។ នេះគឺដោយសារតែភាគល្អិតអាល់ហ្វា មិនជ្រៀតចូល ដូច្នេះវានឹងបញ្ចេញថាមពលរបស់វាក្នុងបរិមាណតិចតួចនៃជាលិកា ប្រហែលជាក្នុងកោសិកាមួយចំនួនប៉ុណ្ណោះ ។ បញ្ហានេះនឹងបង្កើនហានិភ័យយ៉ាងខ្លាំងដែលថាកោសិកាដែលពាក់ព័ន្ធនោះ នឹងក្លាយទៅជាមហារីក ។ ការលេបចូល និងការស្រូបចូលក៏អាចជាបញ្ហាយ៉ាងខ្លាំងផងដែរជាមួយសារធាតុបញ្ចេញអាល់ហ្វា ។

សារធាតុវិទ្យុសកម្មភាគច្រើនជ្រៀតចូលទៅកាន់ផ្នែកផ្សេងៗនៃរាងកាយ ។ ឧទាហរណ៍ ប្រសិនបើសារធាតុដែលមិនរលាយ ត្រូវបានហឺតចូល វានឹងស្ថិតនៅក្នុងសួត ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើសារធាតុរលាយត្រូវបានស្រូបចូល សារធាតុនោះនឹងត្រូវបានស្រូបចូលទៅក្នុងចរន្តឈាម ហើយនឹងទៅដល់ផ្នែកផ្សេងៗទៀតនៃរាងកាយ ។

ឯកតារង្វាស់វិទ្យុសកម្មផ្សេងៗជាច្រើន ត្រូវបានគេប្រើប្រាស់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយឯកសារស្តីពីសុវត្ថិភាពវិទ្យុសកម្មអាចមានការភាន់ច្រឡំ ជាពិសេសប្រសិនបើឯកសារនោះទើតតែមានអាយុកាលពីរបីឆ្នាំ ។

## ធូលី និងសរសៃដែលអាចស្រូបចូលតាមរយៈការដកដង្ហើម

សារធាតុខ្លះមានគ្រោះថ្នាក់ដោយសារតែលក្ខណៈរូបវន្តរបស់វា ជាជាងលក្ខណៈគីមី ។ អាបេស្តូស ស៊ីលីកា និងសរសៃសំយោគមួយចំនួន (មិនមែនទាំងអស់ទេ) គឺស្ថិតនៅក្នុងសារធាតុប្រភេទនេះ ។

ធូលីដែលត្រូវបានចាត់ទុកថា "អាចដកដង្ហើមចូលបាន" ឬអត់ អាស្រ័យលើទំហំភាគល្អិត ។ ភាគល្អិតធំមិនអាចហឺតចូលបានទេ ប្រសិនបើវាហើរក្នុងខ្យល់ វាដក់ជាប់នឹងច្រមុះខាងក្រៅ និងបំពង់ក ។

ភាគល្អិតតូចៗអាចឆ្លងកាត់បំពង់សំឡេង ប៉ុន្តែមានតែភាគល្អិតតូចបំផុតប៉ុណ្ណោះដែលនឹងទៅដល់ថង់ខ្យល់ (ថង់ខ្យល់តូចបំផុត) នៃសួត ។ ទំហំធំបំផុតនៃភាគល្អិតដែលអាចជ្រៀតចូលយ៉ាងជ្រៅទៅក្នុងថង់ខ្យល់ ជាធម្មតា គឺមានអង្កត់ផ្ចិតប្រហែល ៥ ឬ ៦ មីក្រូម៉ែត្រ ។

**កំណត់សម្គាល់** ៖ និយមន័យ "តាមច្បាប់" នៃអ្វីដែលជាធូលីដែលអាចដកដង្ហើមចូលបាន អាចខុសគ្នានៅក្នុងពីប្រទេសមួយទៅប្រទេសមួយ ។ ផ្អែកតាមច្បាប់ អ្នកត្រូវយោងលើឯកសារពាក់ព័ន្ធនៅក្នុងប្រទេសរបស់អ្នក ។

ប្រសិនបើភាគល្អិតអាចជ្រៀតបចូលយ៉ាងជ្រៅទៅក្នុងសួត នោះវាអាចដក់ជាប់នៅទីនោះ ដែលអាចបណ្តាលឱ្យក្រហាយ រលាក និងការខូចខាតរយៈពេលយូរអង្វែង ឬអចិន្ត្រៃយ៍ ។

ជំងឺសួតដែលអាចបណ្តាលមកពីធូលី និងសរសៃដែលដកដង្ហើមចូលរួមមាន ក្រហាយ អាឡែរហ្ស៊ី ជំងឺខូចសាច់សួត (ស្នាមរបួស និងស្នះសួត) រលាកទងសួត ជំងឺហឺត និងមហារីក ។

ជាពិសេស សារធាតុអាបស្តូស និងស៊ីលីកា គឺជាសារធាតុដ៏សាហាវបំផុតដែលគេមិនធ្លាប់ប្រើក្នុងឧស្សាហកម្ម ហើយជាប្រធានបទដែលបានលើកឡើងនៅក្នុងសៀវភៅរបស់ IndustriALL ដាច់ដោយឡែកដែលមានតាមគេហទំព័រ www.industriall-union.org ។

**ឯកសារបោះពុម្ពរបស់ INDUSTRIALL**

# ការស៊ើបអង្កេតឧប្បត្តិហេតុ

IndustriALL ច្រើនតែស៊ើបអង្កេតគ្រោះថ្នាក់ និងឧបទ្ទវហេតុនានា ដោយសហការជាមួយនិយោជក ផ្អែកតាមដំណើរការដែលបានព្រមព្រៀងគ្នាទៅវិញទៅមក ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើយើងយល់ថា ដំណើរការស៊ើបអង្កេតគ្រោះថ្នាក់មិនមានភាពយុត្តិធម៌ ឬមិនមានសមត្ថភាពក្នុងការកំណត់ពីមូលហេតុទាំងអស់នៃគ្រោះថ្នាក់ទេ ឬប្រសិនបើយើងជឿថាការស៊ើបអង្កេតគ្រោះថ្នាក់ កំពុងត្រូវបានធ្វើឡើងដើម្បីធ្វើការស្តីបន្ទោស ជាជាងកែតម្រូវទៅលើមុខសញ្ញាគ្រោះថ្នាក់ យើងរក្សាសិទ្ធិក្នុងការធ្វើការស៊ើបអង្កេតដោយខ្លួនយើងផ្ទាល់ និងធ្វើរបាយការណ៍នៅពេលណាដែលយើងជឿថា វាជារឿងដែលល្អបំផុតនោះ ។

មានហេតុផលជាច្រើនដែលការស៊ើបអង្កេត និងវិភាគឧបទ្ទវហេតុ ជាញឹកញាប់ ក្លាយជារឿងពិបាកកាន់តែខ្លាំងជាងការគិតរបស់អ្នកស៊ើបអង្កេតពីដំបូង ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន (អាចមានករណីផ្សេងៗទៀតផងដែរ) ៖

- **ស្ថានភាពជាក់ស្តែងអាចមានភាពស្មុគស្មាញជាងការគិតពីដំបូង**
- **អ្នកស៊ើបអង្កេតអាចយល់ឃើញថា អ្នកដែលពាក់ព័ន្ធមានភាពស្ទាក់ស្ទើរក្នុងការពិភាក្សា ឬទទួលស្គាល់ការបរាជ័យ - របស់ពួកគេផ្ទាល់ ឬរបស់អ្នកដទៃទៀត' - ឬព្យាយាមការពារការសម្រេចចិត្តមិនល្អ ឬគោលនយោបាយដែលបរាជ័យ ដោយសារតែពួកគេមានមោទនភាព ឬដោយសារតែនយោបាយ ឬការភ័យខ្លាច ។**
- **អ្នកស៊ើបអង្កេតធ្វើការសន្និដ្ឋានភ្លាមៗដោយមិនត្រឹមត្រូវ ឬស្ថិតក្រោមឥទ្ធិពលនៃការសន្និដ្ឋានមិនត្រឹមត្រូវរបស់អ្នកដទៃ និង**
- **វិបត្តិដែលកើតឡើងភ្លាមៗ និងភាពច្របូកច្របល់ក្នុងកំឡុងពេលក្រោយឧបទ្ទវហេតុនេះ បណ្តាលឱ្យមានការភ័យស្លន់ស្លោ ដែលធ្វើឱ្យមានការវិភាគទៅលើព្រឹត្តិការណ៍ដោយមិនសមហេតុផល**

ដើម្បីជៀសវាងបញ្ហាទាំងនេះ និងកង្វះខាតដែលអាចកើតមានផ្សេងៗទៀត អ្នកស៊ើបអង្កេតត្រូវតែធានាថា ដំណើរការស៊ើបអង្កេតគ្រោះថ្នាក់មានភាពឱ្យច្បាស់លាស់ និងសាមញ្ញបំផុតតាមដែលអាចធ្វើទៅបាន ។

ការស៊ើបអង្កេតគ្រោះថ្នាក់ គឺជាឧទាហរណ៍មួយនៃការប្រើប្រាស់បច្ចេកទេសដោះស្រាយបញ្ហាជាមូលដ្ឋាន ។ ដូច្នេះ ការស៊ើបអង្កេតគ្រោះថ្នាក់ដែលមានប្រសិទ្ធភាព នឹងអនុវត្តតាមលំដាប់លំដោយនេះ ៖

1. **យល់ច្បាស់អំពីអ្វីដែលជាបញ្ហា ។ ត្រូវតែមានអ្វីមួយកើតឡើងមុននឹងអ្នកនឹងកំណត់ថាជាគ្រោះថ្នាក់ ឬជាឧប្បត្តិហេតុធំដុំ ។ ហេតុការណ៍បែបនេះ នឹងត្រូវឱ្យមានការអនុវត្តដំណើរការស៊ើបអង្កេតគ្រោះថ្នាក់ និងដាក់ឱ្យដំណើរការក្រុមស៊ើបអង្កេតគ្រោះថ្នាក់ ។**
2. **ប្រមូលព័ត៌មាន ។ កិច្ចការនេះអាចរួមមានការចុះទៅដល់ទីតាំងផ្ទាល់ កត់ត្រាទុកអ្វីដែលបានសង្កេតឃើញ ការថតរូប ការសម្ភាសជនរងគ្រោះ, សាក្សី, អ្នកជំនាញ និងអ្នកដទៃ ។ នីតិវិធីការងារជាលាយលក្ខណ៍អក្សរ គំនូសប្លង់វិស្វកម្ម កំណត់ត្រាតំហែទាំ លក្ខណៈបច្ចេកទេសនៃការទិញ និងកំណត់ត្រាការបណ្តុះបណ្តាល ក៏អាចពាក់ព័ន្ធផងដែរ ។**
3. **វិភាគទិន្នន័យដើម្បីព្យាយាមកំណត់ពីមូលហេតុនានា (ពហុវចនៈ) នៃគ្រោះថ្នាក់ (តែងតែមានមូលហេតុលើសពីមួយ)។**
4. **សម្រេចចិត្តតើត្រូវធ្វើអ្វីខ្លះដើម្បីទប់ស្កាត់គ្រោះថ្នាក់នោះកុំឱ្យកើតឡើងនៅពេលអនាគត ឬយ៉ាងហោចណាស់ កាត់បន្ថយលទ្ធផលប្រសិនបើវាបានកើតឡើងរួចទៅហើយ ។ ត្រូវមានភាពជាក់លាក់បំផុតតាមដែលអាចធ្វើទៅបាន ។ ពិចារណាវិធានការរយៈពេលខ្លី និងវិធានការរយៈពេលវែង តាមដែលសមស្រប ។**
5. **ធានាថា វិធានការបង្ការត្រូវបានអនុវត្ត ។ តាមដានមើលការអនុវត្ត ។**

នៅក្នុងវិស័យសុខភាព និងសុវត្ថិភាពការងារ ជាការប្រសើរដែលត្រូវមានប្រព័ន្ធដើម្បីទប់ស្កាត់មុខសញ្ញាគ្រោះថ្នាក់មិនឱ្យកើតឡើង ជាជាងការគ្រាន់តែកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់ និងកែតម្រូវវា ។ ការស៊ើបអង្កេតគ្រោះថ្នាក់ គឺជាឱកាសដើម្បីពិនិត្យមើលប្រព័ន្ធសុវត្ថិភាព ។

ការកសាង ឬកែលម្អប្រព័ន្ធ តម្រូវឱ្យមានការយល់ដឹងអំពីវិធីសាស្ត្រដោះស្រាយបញ្ហាជាមូលដ្ឋានដែលបានរៀបរាប់ខាងលើ ។ ការស៊ើបអង្កេតគ្រោះថ្នាក់ គឺធ្វើតាមរចនាសម្ព័ន្ធមូលដ្ឋាននេះ ។ ជំហានទីមួយគឺត្រូវយល់ថាបញ្ហានោះគឺជាអ្វី ពោលគឺកំណត់និយមន័យគ្រោះថ្នាក់នោះ ។

កិច្ចការនេះ មើលទៅហាក់ដូចជាឃើញច្បាស់ជាក់ស្តែង ប៉ុន្តែអ្នកស៊ើបអង្កេតគួរតែចំណាយពេលពីដើមដំបូងនៃការស៊ើបអង្កេតគ្រោះថ្នាក់ដើម្បីកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ ៖

**តើអ្វីបានកើតឡើង?** ប្រើពាក្យខ្លីបំផុតតាមដែលអាចធ្វើបាន ហើយផ្តោតលើលទ្ធផលជាក់ស្តែង (ឬលទ្ធផលដែលអាចកើតមាន ប្រសិនបើការស៊ើបអង្កេតលើបញ្ហា "ប៉ិះបរាជ័យ/ជិតខូចខាត") ។ នៅក្នុងសកម្មភាពនេះ អ្នកគួរតែពណ៌នាជាមូលដ្ឋានអំពីព្រឹត្តិការណ៍នោះ និងមូលហេតុដែលអ្នកគិតថា គួរធ្វើការស៊ើបអង្កេត ។ កុំព្យាយាមរៀបរាប់អំពីព្រឹត្តិការណ៍ និងបុព្វហេតុដែលពាក់ព័ន្ធទាំងអស់នៅដំណាក់កាលនេះ ។

**តើវាកើតឡើងនៅឯណា?** តើវាជាព្រឹត្តិការណ៍ជាក់លាក់មួយដែលកើតឡើងនៅទីតាំងមួយជាក់លាក់ ឬតើគួរពណ៌នាថា វាកើតឡើងនៅក្នុងតំបន់មួយ ឬនៅក្នុងតំបន់ជាច្រើន?

**តើវាកើតឡើងពេលណា?** ពេលវេលាដ៏សំខាន់បំផុតដែលត្រូវកត់សម្គាល់ គឺជាពេលវេលានៃលទ្ធផលដែលអ្នកមានការព្រួយបារម្ភទៅលើ ពោលគឺ ករណីរបួស ឬស្លាប់ ។ ទោះយ៉ាងណាក៏ដោយ ខណៈពេលដែលកត់ត្រាទុកព្រឹត្តិការណ៍នេះ សូមពិចារណាខ្លះៗទៅលើសំណួរដូចខាងក្រោម ។ តើវាជាព្រឹត្តិការណ៍ជាក់លាក់មួយ (ឧទា. ការធ្លាក់ពីលើជណ្តើរ) ឬជាព្រឹត្តិការណ៍មួយដែលកើតឡើងបន្តិចម្តងៗក្នុងរយៈពេលមួយ (ឧទា. ជំងឺហឺតដោយសារការងារ)?

## ការប្រមូលព័ត៌មាន

ជាសំខាន់ខ្លាំងណាស់ដែលត្រូវប្រមូលអង្គហេតុឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន! ប្រភពព័ត៌មានអាចរួមមាន ៖

- **កំណត់សម្គាល់ដែលបានធ្វើឡើងក្នុងអំឡុងពេលសង្កេតទៅលើទីតាំងដោយផ្ទាល់**
- **រូបថត ឬវីដេអូ**
- **ការសម្ភាសជនរងគ្រោះ សាក្សី អ្នកធ្វើការជាមួយ អ្នកជំនាញ និងអ្នកដទៃទៀត**
- **នីតិវិធីការងារជាលាយលក្ខណ៍អក្សរ**
- **ដ្យាក្រាមវិស្វកម្ម**
- **លក្ខណៈបច្ចេកទេសសម្រាប់ការទិញ**
- **កំណត់ត្រាតំហែទាំ**
- **របាយការណ៍អំពីបញ្ហាសុវត្ថិភាព**
- **គ្រោះថ្នាក់ និងឧប្បត្តិហេតុពីមុន**
- **កំណត់ត្រាបណ្តុះបណ្តាល**

នៅពេលប្រមូលព័ត៌មាន (ជាពិសេសនៅពេលសម្ភាសជនរងគ្រោះ សាក្សី អ្នកត្រួតពិនិត្យការងារ មិត្តរួមការងារ និងអ្នកផ្សេងទៀតដែលទាក់ទងដោយផ្ទាល់ទៅនឹងគ្រោះថ្នាក់នោះ) ជាការសំខាន់ដែលត្រូវយកចិត្តទុកដាក់លើអារម្មណ៍អ្នកដែលប៉ះពាល់ ។ អារម្មណ៍របស់ពួកគេ - កំហឹង ការភ័យខ្លាច កំហុស ទុក្ខព្រួយ - អាចកើនឡើងខ្ពស់ ។ ត្រូវប្រើភាសាការទូតជាពិសេសនៅពេលមានរបួសធ្ងន់ធ្ងរ ឬស្លាប់ ។

ទោះបីជាការយល់ឃើញរបស់មនុស្សចំពោះបញ្ហាគឺជាអ្វីដែលសំខាន់ក៏ដោយ ក៏វាមិនសំខាន់ដូចការអង្គហេតុដែរ ។ **បែងចែកភាពខុសគ្នារវាងទស្សនៈ និងការពិត** ។ មិនត្រូវសួរសំណួរដែលបង្កប់ន័យស្តីបន្ទោសឡើយ ឧទា. “ហេតុអ្វីបានជាអ្នកធ្វើ (មិនធ្វើ)...” ឬ “តើអ្នកបានដឹង (ឬមិនដឹង) អំពីរឿងនោះ...” ។ កុំស្វែងរកការស្តីបន្ទោស ។ ចូររកមើលប្រព័ន្ធ និងធាតុផ្សំនៃប្រព័ន្ធដែលបរាជ័យ ។

តើគួររកមើលអង្គហេតុបែបណាខ្លះ?

1. **សម្ភារៈ ឧបករណ៍ បរិក្ខារ ។ល។ - "វត្ថុ" ដែលពាក់ព័ន្ធ**
2. **ការងារ ឬកិច្ចការ ៖ អ្វីខ្លះដែលកំពុងធ្វើជាក់ស្តែង នីតិវិធី ការត្រួតពិនិត្យសុវត្ថិភាពដែលត្រូវធ្វើឡើង និងបរិក្ខារចាំបាច់ ។ល។**
3. **ការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង - លក្ខណៈបច្ចេកទេស ការរចនាបទកន្លែង/គំនូសប្លង់ធ្វើការ ការជួសជុល ការត្រួតពិនិត្យ ការពង្រឹងសុវត្ថិភាព ការចាត់តាំងការងារ**
4. **កត្តាបរិស្ថាន - កំដៅ, ត្រជាក់, ពន្លឺ, ធូលី, សំលេងរំខាន, ផ្សែង, កម្រាលឥដ្ឋរអិល, ។ល។ និង**
5. **មនុស្ស - ការបណ្តុះបណ្តាល បទពិសោធន៍ ភាពតានតឹង ការប្រុងប្រយ័ត្ន កត្តាផ្ទាល់ខ្លួន ។ល។**

ដើម្បីជៀសវាងការមើលរំលងអង្គហេតុណាមួយ ត្រូវប្រាកដថា អ្នកកត់ត្រាអ្វីៗគ្រប់យ៉ាង - ទោះបីជាអ្នកត្រូវបន្ថែមប្រភេទថ្មីមួយទៀតក៏ដោយ ។

នៅពេលដែលអ្នកបានប្រមូល និងរៀបចំអង្គហេតុទាំងអស់រួចហើយ អ្នកត្រៀមធ្វើការវិភាគអង្គហេតុទាំងនោះដើម្បីកំណត់ពីមូលហេតុនៃគ្រោះថ្នាក់នោះ ។

កម្មវត្ថុនៃការស៊ើបអង្កេតគ្រោះថ្នាក់ គឺដើម្បីរកឱ្យឃើញពីមូលហេតុនៃគ្រោះថ្នាក់ និងស្នើឡើងនូវវិធានការនានាដើម្បីទប់ស្កាត់ឧបទ្ទវហេតុដដែលនោះឬស្រដៀងគ្នាមិនឱ្យកើតឡើងដដែលៗ ។

### ពាក្យខ្លះៗអំពីការស្តីពីបន្ទោស និងការដាក់កំហុស

ការស្តីបន្ទោស ឬការទម្លាក់កំហុសលើបុគ្គល ឬវត្ថុណាមួយ គឺជាកំហុសទូទៅមួយក្នុងការស៊ើបអង្កេតគ្រោះថ្នាក់ ។ ហេតុផលសម្រាប់ការផ្តោតការយកចិត្តទុកដាក់ទាំងស្រុងទៅលើមនុស្សម្នាក់ ឬបរិក្ខារណាមួយ គឺឃើញជាក់ស្តែង - ព្រោះ ការងារដែលត្រូវធ្វើគឺមានតិចជាងមុន ហើយការធ្វើដូច្នេះ ធ្វើឱ្យមិនមានចោទសួរ និងគ្មានការរិះគន់ទៅលើប្រព័ន្ធនោះ ។

ប្រព័ន្ធដែលពឹងផ្អែកលើការប្រុងប្រយ័ត្ន ១០០ ភាគរយ, ពោលគឺផ្អែកលើលើការប្រុងប្រយ័ត្នរបស់មនុស្ស ១០០ ភាគរយគ្រប់ពេលនោះ គឺពិតជាមិនអាចជៀសវាងគ្រោះថ្នាក់បាននោះទេ ។ ប្រសិនបើមនុស្សម្នាក់នៅក្នុងស្ថាប័នមួយ ធ្វើឱ្យមានកំហុស ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ពេលនោះ វាអាចថានរណាម្នាក់ទៀតទំនងជាបានធ្វើ ឬនឹងធ្វើឱ្យមានកំហុសដដែលនោះដែរ ។ គោលដៅមិនត្រូវភ្ជាប់ជាមួយការស្តីបន្ទោសឡើយ ។ ប្រសិនបើការស៊ើបអង្កេតគ្រោះថ្នាក់ត្រូវបានគេប្រើដើម្បីភ្ជាប់ជាមួយការស្តីបន្ទោស ឬដាក់វិន័យនោះ គ្មាននរណាម្នាក់មានបំណងសហការជាមួយការស៊ើបអង្កេតនាពេលអនាគតនោះឡើយ ។

ការទម្លាក់កំហុសទៅលើសមាសភាគឬវត្ថុណាមួយ គឺមិនប្រសើរជាងការស្តីបន្ទោសបុគ្គលប៉ុន្មាននោះទេ ។ សូមរំលឹកឡើងវិញអំពីការផ្ទុះនៃយានអវកាស Challenger ដែលនៅពេលនោះ មូលហេតុដែលគេលើកឡើងភ្លាមៗគឺថា បញ្ហានោះបណ្តាលមកពីការលិចប្រេងជុំវិញកងមូល “O” នៅចន្លោះដំណាក់កាលរ៉ុកែត ។ ប្រសិនបើអ្នកស៊ើបអង្កេតទៅលើការផ្ទុះនោះ ទម្លាក់កំហុសទៅលើកងមូល "O" ដែលខូចនោះ គេនឹងមិនអាចយល់បានច្រើនអំពីការខូចប្រព័ន្ធសុវត្ថិភាពជាច្រើនរបស់ NASA នោះទេ ។ ហេតុអ្វីបានជាគេមិនយកចិត្តទុកដាក់ចំពោះភស្តុតាងពីមុននៃបញ្ហាជាមួយកងមូល “O”-rings? ហេតុអ្វីបានជាបញ្ហាទាក់ទងនឹងសុវត្ថិភាពធម្មតា មិនត្រូវបានគេយកចិត្តទុកដាក់ក្នុងករណីនេះ? តើបញ្ហានេះពាក់ព័ន្ធនឹងអាកាសធាតុដែរឬទេ? តើប្រព័ន្ធមួយនេះត្រូវបានគេសម្រេចផលិតឡើងដោយរបៀបណាដែរ?

## ការវិភាគគ្រោះថ្នាក់ - ដើមឈើបន្ទាត់ពេលវេលា និងកំហុស

នីតិវិធីស៊ើបអង្កេតគ្រោះថ្នាក់ជាលាយលក្ខណ៍អក្សរជាច្រើន ផ្តោតលើដំណាក់កាលវិភាគថា ជាជំហានដ៏លំបាកបំផុត ។ នេះគឺជាដំណាក់កាលនៃការស៊ើបអង្កេតដែលអ្នកស៊ើបអង្កេតត្រូវតែព្យាយាមយល់ពីអង្គហេតុដើម្បីកំណត់អត្តសញ្ញាណមូលហេតុទាំងអស់នៃគ្រោះថ្នាក់ ។

មានបច្ចេកទេសមូលដ្ឋានចំនួនពីរដែលអ្នកស៊ើបអង្កេតប្រើប្រាស់ ដើម្បីធ្វើកិច្ចការនេះ ៖

(i) រៀបចំព័ត៌មានជាលំដាប់តែមួយនៃព្រឹត្តិការណ៍ ឬបន្ទាត់ពេលវេលា ។

(ii) រៀបចំព័ត៌មានជាលំដាប់នៃព្រឹត្តិការណ៍ ប៉ុន្តែបង្ហាញខ្សែសង្វាក់មូលហេតុ និងផលប៉ះពាល់ដាច់ដោយឡែក ទោះជាតូចប៉ុណ្ណាក៏ដោយ ដូចជាសាខា និងអនុសាខា រហូតដល់សាខាធំ ឬលំដាប់ចម្បង ។ ដោយសារតែរូបភាពបង្ហាញពីការវិភាគនេះ បច្ចេកទេសនេះត្រូវបានគេហៅថា "ដើមឈើកំហុស" (“fault tree”) ។

វិធីសាស្រ្តទី (i) ត្រូវបានគេប្រើញឹកញាប់បំផុតដើម្បីស៊ើបអង្កេតគ្រោះថ្នាក់ឧស្សាហកម្មធម្មតា ។

វិធីសាស្រ្តទី (ii) មានប្រយោជន៍ច្រើន ជាពិសេសប្រសិនបើពាក់ព័ន្ធនឹងព័ត៌មានលម្អិតបច្ចេកទេស ។

## បន្ទាត់ពេលវេលា

ដើម្បីបង្កើតការវិភាគ "លំដាប់នៃព្រឹត្តិការណ៍" ដោយចាប់ផ្តើមពីលទ្ធផល - ការរងរបួស ការស្លាប់ ឬការបាត់បង់ - និងធ្វើការត្រឡប់មកវិញ ។

1. ដើម្បីចាប់ផ្តើម **ចូរសរសេរការពិពណ៌នាខ្លីមួយអំពីលទ្ធផល ។**
2. **បន្ទាប់មក សូមសួរសំណួរថា «តើស្ថានភាពភ្លាមៗមុនពេលកើតហេតុនោះ មានអ្វីខ្លះដែលរួមចំណែកដល់គ្រោះថ្នាក់ ឬដែលអាចទប់ស្កាត់គ្រោះថ្នាក់ ឬរបួសបាន?** ចម្លើយរបស់អ្នកគួរតែផ្អែកលើព័ត៌មាន ឬភស្តុតាងដែលមាន ឬការសន្និដ្ឋានសមហេតុផលពីព័ត៌មាននើ ។
3. **សរសេរការពិពណ៌នាខ្លីមួយអំពីស្ថានភាពមុនកើតហេតុនោះ -** ជាលទ្ធផល ចម្លើយរបស់អ្នកចំពោះសំណួរខាងលើ ។
4. **អនុវត្តជំហានទី (២) និង (៣)** ឡើងវិញ រហូតដល់អ្នកអស់ចម្លើយចំពោះចំណុចទី (២) ។

ឧទាហរណ៍ ចូរព្យាយាមបង្កើតលំដាប់នៃព្រឹត្តិការណ៍ ឬបន្ទាត់ពេលវេលា ការវិភាគទៅលើរបួសភ្នែករបស់ជាងឈើ ដែលគាត់កាត់ឈើដោយប្រើរណាចាស់មួយនៅកន្លែងធ្វើការ ដែលមិនសូវយកចិត្តទុកដាក់លើសុវត្ថិភាព ដូចបង្ហាញខាងក្រោម ៖

- **លទ្ធផល ៖ របួសភ្នែកមួយបានកើតឡើងពេលដែកមួយដុំបានប៉ះអ្នកប្រើរណា ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ជាងឈើមិនបានពាក់វ៉ែនតាសុវត្ថិភាព ដែលអាចរារាំងកំទេចលោហៈនោះបាន ។**
  តើមានអ្វីខ្លះអំពីស្ថានភាពភ្លាមៗមុននេះ ដែលបានរួមចំណែកដល់គ្រោះថ្នាក់ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **មិនមានរបាំងនៅលើរណាដែលអាចបញ្ឈប់ភាគល្អិតលោហៈនោះ ។**
  តើមានអ្វីខ្លះអំពីស្ថានភាពភ្លាមៗមុននេះ ដែលបានរួមចំណែកដល់គ្រោះថ្នាក់ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ផ្លែរណាប៉ះនឹងដែកគោលនៅក្នុងដុំឈើនោះ ដែលធ្វើឱ្យបែកចេញជាកំទេចដែក**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ហាងលក់គ្រឿងឈើនោះមិនមានពន្លឺគ្រប់គ្រាន់ ដែលធ្វើឱ្យមានការលំបាកក្នុងការពិនិត្យមើលឈើ ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **មិនមានគោលនយោបាយ ឬការបណ្តុះបណ្តាលអំពីភាពចាំបាច់ដែលត្រូវពិនិត្យមើលឈើរកមើលដែកគោលនោះទេ ហើយទោះបីជាមានក៏ដោយ ការងារនេះគឺជាការងារ "ប្រញាប់ប្រញាល់" ដែលធ្វើឱ្យអ្នកប្រើប្រាស់រណាមិនអាចចំណាយពេលពិនិត្យឈើឱ្យបានហ្មត់ចត់នោះឡើយ ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ការត្អូញត្អែរអំពីតំហែទាំរណា និងពន្លឺភ្លើងក្នុងហាង មិនត្រូវបានគេដោះស្រាយនោះទេ ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **គ្មានការវិភាគណាមួយត្រូវបានគេធ្វើឡើងទៅលើមុខសញ្ញាគ្រោះថ្នាក់ដែលទាក់ទងនឹងការផ្លាស់ប្តូរសម្ភារៈ ពីឈើថ្មី ទៅជាឈើកែច្នៃឡើងវិញនោះទេ ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ថ្មីៗនេះ អ្នកគ្រប់គ្រងបានចាប់ផ្តើមទទូចឱ្យប្រើប្រាស់ឈើកែច្នៃនៅពេលណាដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការចំណាយ ។ ឈើដែលគេប្រើរួចហើយ ទំនងជាមានដែកគោលច្រើនជាងឈើថ្មី ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ស្ថាប័នទាំងមូលមានឥរិយាបថមិនសូវយកចិត្តទុកដាក់ចំពោះសុវត្ថិភាព ។ បញ្ហាសុវត្ថិភាព ទោះបីជានៅពេលរាយការណ៍ប្រាប់ក៏ដោយ កម្រត្រូវបានកែតម្រូវក្នុងរយៈពេលតិចជាងបីខែណាស់ ។ ភស្តុតាងបង្ហាញថា និយោជិតកម្រពាក់ឧបករណ៍ការពារសុវត្ថិភាព ដូចជា វ៉ែនតាសុវត្ថិភាពជាដើម ។ នេះរួមបញ្ចូលទាំងអ្នកត្រួតពិនិត្យហាងផងដែរ ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **ជាទូទៅ មិនមានគោលនយោបាយ នីតិវិធី និងការពង្រឹងការអនុវត្តសុវត្ថិភាព ហើយមិនមានវិធីជាប្រព័ន្ធដើម្បីធានាថារាល់កម្មវិធីថ្មីនីមួយៗបានទទួលការវិភាគមុខសញ្ញាគ្រោះថ្នាក់ ការអភិវឌ្ឍគោលនយោបាយ និងការបណ្តុះបណ្តាលត្រឹមត្រូវ ។ ជាទូទៅ និយោជិតមិនបានទទួលការបណ្តុះបណ្តាល ឬការធ្វើបច្ចុប្បន្នភាពជំនាញនោះទេ សូម្បីតែនៅពេលនីតិវិធី ឬបរិក្ខារមានការផ្លាស់ប្តូរក៏ដោយ ។ ហាងពឹងផ្អែកលើបទពិសោធន៍ផ្ទាល់ជាជាងការបណ្តុះបណ្តាល ។**
  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **មិនមានប្រព័ន្ធត្រួតពិនិត្យទៀងទាត់ ឬតំហែទាំបង្ការទៅលើបរិក្ខារនោះទេ ។**

  តើមានអ្វីខ្លះនៅក្នុងស្ថានភាពភ្លាមៗមុនកើតហេតុនោះ ដែលរួមចំណែកដល់គ្រោះថ្នាក់នេះ ឬដែលអាចទប់ស្កាត់របួសនោះបាន?

- **កាលពីពីរឆ្នាំមុន ក្រុមហ៊ុនបានចាប់ផ្តើមអនុវត្តកម្មវិធីកាត់បន្ថយការចំណាយដ៏ធំមួយ ដែលត្រូវបានគេយល់ថា ជាការធ្វើឱ្យសុវត្ថិភាពក្លាយជាអាទិភាពទីពីរ បន្ទាប់ផលិតកម្ម ហើយក៏បន្ថយអាទិភាពនៃតំហែទាំបង្ការផងដែរ ។ នេះហាក់ដូចជាធ្វើបាត់បង់ដល់ការយកចិត្តទុកដាក់អំពីសុវត្ថិភាពរបស់និយោជិតគ្រប់គ្នា ។**

ទោះបីជាឧទាហរណ៍មួយមិនអាចបង្ហាញពីអ្វីៗគ្រប់យ៉ាងក៏ដោយ ក៏បន្ទាត់ពេលវេលាខាងលើកើតមានជាទូទៅតាមវិធីផ្សេងៗជាច្រើន ។ នៅក្នុងពេលមួយនោះ នៅពេលដែលហៀបនឹងកើតមានព្រឹត្តិការណ៍ជាក់ស្តែង ជាធម្មតា គេយល់ឃើញថា កត្តាសំខាន់គឺទាក់ទងនឹងសម្ភារៈឧបករណ៍ បរិក្ខារ និងបរិយាកាសនៅកន្លែងធ្វើការ ។ លើសពីនេះទៀត កាលពីអតីតកាល ជារឿយៗ គេយល់ថា កត្តាពាក់ព័ន្ធគឺមានដូចជាការបណ្តុះបណ្តាល ការថែទាំ ស្តង់ដារនៃការទិញ គោលនយោបាយជាដើម ។

**តេស្ត ៖** ប្រសិនបើអ្នកបានបង្កើតបន្ទាត់ពេលវេលារបស់អ្នកបានត្រឹមត្រូវនោះ ប្រសិនបើអ្នកអានវាតាមលំដាប់បញ្ច្រាស អ្នកគួរតែដឹងពីរឿងរ៉ាវដែលសមហេតុផល ។ ប្រសិនបើវាមិនសមហេតុផល ឬផ្នែកធំបំផុតនៃរឿងនោះ ហាក់ដូចជាបាត់មិនឃើញមាន អ្នកគួរតែពិនិត្យមើលការវិភាគរបស់អ្នកឡើងវិញ ដើម្បីប្រាកដថា អ្នកពិតជាបានធ្វើការពិចារណារាល់អង្គហេតុទាំងអស់រួចហើយ ។

នៅក្នុងឧទាហរណ៍ខាងលើនេះ សាច់រឿងអាចនឹងមានលក្ខណៈដូចខាងក្រោមនេះ ៖

“នៅក្នុងហាងជាងឈើដែលមានឥរិយាបថមិនសូវយកចិត្តទុកដាក់ចំពោះសុវត្ថិភាព ហើយគ្មានការប្តេជ្ញាចិត្តចំពោះការបណ្តុះបណ្តាល ការផ្លាស់ប្តូរទៅលើវត្ថុធាតុដើម ត្រូវបានធ្វើឡើងដោយប្តូរពីឈើថ្មី ទៅជាឈើកែច្នៃវិញ ។ បញ្ហាសុវត្ថិភាពដែលអាចកើតមានពីការផ្លាស់ប្តូរនេះមិនត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយសុវត្ថិភាព ឬការបណ្តុះបណ្តាលណាមួយឡើយ ។ លើសពីនេះទៀត បរិក្ខារក្នុងហាងគឺមានសភាពចាស់ និងថែទាំមិនបានល្អ ហើយបរិយាកាសការងារជាពិសេសភ្លើងបំភ្លឺ គឺអន់ ។

នៅថ្ងៃកើតហេតុ កម្មករម្នាក់ត្រូវបានគេស្នើឱ្យធ្វើ "ការងារប្រញាប់" មួយ, គាត់បានទទួលឈើដែលគេប្រើរួចមួយចំនួន ដោយមិនបានពិនិត្យរកមើលដែកគោល ឬមិនបានឃើញដែកគោល ដោយសារភ្លើងមិនភ្លឺល្អ ហើយបានចាប់ផ្តើមកាត់ឈើនោះដោយរណាមួយដែលគ្មានរបាំងការពារ ។ បំណែកដែកមួយបានខ្ទាតចេញពីរណា ហើយអាចធ្វើឲ្យខូចភ្នែកកម្មករដែលមិនមានអ្វីការពារ»។

## សំខាន់

## លំដាប់នៃព្រឹត្តិការណ៍មិនដូចគ្នានឹងទំនាក់ទំនងរវាងមូលហេតុ និងផលប៉ះពាល់!

កំហុសមួយក្នុងចំណោមកំហុសទូទៅបំផុត គឺការសន្មតថា ព្រឹត្តិការណ៍ពីមុនៗ "បានបង្ក" ព្រឹត្តិការណ៍ផ្សេងៗនៅពេលក្រោយមកទៀត ។ ការដាក់ព្រឹត្តិការណ៍ក្នុងលំដាប់លំដោយ ហាក់ដូចជាបង្កប់អត្ថន័យនេះនៅក្នុងចិត្តមនុស្សមួយចំនួន ។ ចូរចងចាំថា បន្ទាត់ពេលវេលាមិនដូចស៊េរីនៃល្បែងដូមីណូ (dominos) ទេ ។ អាយុ និងស្ថានភាពមិនល្អរបស់រណា មិនបាន "បណ្តាលឱ្យ" កម្មករកាត់ឈើដោយមិនមានវ៉ែនតាសុវត្ថិភាពនោះទេ ។ ការសម្រេចចិត្តប្រើប្រាស់ឈើកែច្នៃ មិនបាន “បណ្តាលឱ្យ” រណាបាត់របាំងការពាររបស់វានោះទេ ។ អ្វីដែលយើងកំពុងនិយាយ គឺថាលក្ខខណ្ឌមួយប្រហែលជាកើតមានមុនលក្ខខណ្ឌមួយទៀត ហើយថា លក្ខខណ្ឌទាំងអស់មានចំណែកក្នុងលទ្ធផលដែលជាអកុសល ។

## ដើមឈើកំហុស

ផ្ទុយពីការវិភាគបន្ទាត់ពេលវេលាសាមញ្ញ "ដើមឈើកំហុស" ព្យាយាមភ្ជាប់មូលហេតុ និងផលវិបាកដែលពាក់ព័ន្ធគ្នា ឬ មូលហេតុ និងផលប៉ះពាល់ អាស្រ័យលើអ្នកចង់បាន ។

ជំហានដំបូងក្នុងការសង់ដើមឈើកំហុស គឺត្រូវបង្កើតការវិភាគ "លំដាប់លំដោយនៃព្រឹត្តិការណ៍" ដូចដែលបានពិភាក្សាក្នុងទំព័រមុន ។ ចាប់ផ្តើមពីលទ្ធផល - ការរងរបួស ការស្លាប់ ឬការបាត់បង់ - និងធ្វើការត្រឡប់មកក្រោយវិញ ។

1. ដើម្បីចាប់ផ្តើម **ចូរសរសេរការពិពណ៌នាខ្លីមួយអំពីលទ្ធផល ។**
2. បន្ទាប់មក **សួរសំណួរថា «តើមានអ្វីខ្លះកើតឡើងនៅក្នុងស្ថានភាពនោះភ្លាមៗនៅមុនព្រឹត្តិការណ៍នេះកើតឡើង ដែលរួមចំណែកដល់គ្រោះថ្នាក់ ឬដែលទប់ស្កាត់របួស ឬគ្រោះថ្នាក់នោះបាន? ចម្លើយរបស់អ្នកគួរតែផ្អែកលើព័ត៌មាន ឬភស្តុតាងដែលមាន ឬជាការសន្និដ្ឋានដ៏សមហេតុផលមួយពីព័ត៌មាននោះ ។**
3. **សរសេរការពិពណ៌នាខ្លីមួយអំពីស្ថានភាពមុនពេលកើតហេតុណ៍** - ពោលគឺ ចម្លើយរបស់អ្នកចំពោះសំណួរខាងលើ ។
4. **អនុវត្តឡើងវិញជំហានទី (២) និងទី (៣)** រហូតដល់អ្នកអស់ចម្លើយចំពោះជំហានទី (២) ។
5. ពិនិត្យមើលចម្លើយទាំងអស់របស់អ្នក ហើយ**រកមើលព្រឹត្តិការណ៍នានាដែលទាក់ទងនឹងមូលហេតុ និងផលប៉ះពាល់** ។
6. **បង្ហាញការវិភាគរបស់អ្នកដោយប្រើដ្យាក្រាម ។** រៀបចំព្រឹត្តិការណ៍ដែលពាក់ព័ន្ធជាលំដាប់លំដោយដាច់ដោយឡែកនៅលើ "មែក" ដាច់ដោយឡែកពីគ្នានៅលើបន្ទាត់ពេលវេលាចម្បងរបស់អ្នក ។ មែកអាចដាច់ចេញពីគ្នា និងភ្ជាប់គ្នាមកវិញតាមការចាំបាច់ ហើយប្រសិនបើចាំបាច់ អ្នកអាចគូសមែកធាងតូចៗចេញពីមែកធំៗតៗគ្នា ដើម្បីពន្យល់ឱ្យបានពេញលេញអំពីព្រឹត្តិការណ៍មួយ ។ ធានាថា ការធ្វើតាមបន្ទាត់ពេលវេលាណាដ៏ដោយ គួរតែបង្ហាញព្រឹត្តិការណ៍ដែលទាក់ទងនឹងបុព្វហេតុ និងផលប៉ះពាល់ជានិច្ច ។

តោះយើង ប្រើឧទាហរណ៍ដដែល ដែលយើងបានបង្កើតលំដាប់លំដោយនៃព្រឹត្តិការណ៍នៅលើទំព័រមុន ៖ ជាងឈើម្នាក់បានកាត់ឈើដែលគេប្រើរួចដោយប្រើរណាចាស់មួយនៅកន្លែងធ្វើការ ដែលមានឥរិយាបថមិនសូវយកចិត្តទុកដាក់ចំពោះបញ្ហាសុវត្ថិភាព ។

ឧទាហរណ៍ អ្នកគូសរូបបង្ហាញកម្មវិធីកាត់បន្ថយការចំណាយរបស់ក្រុមហ៊ុននេះ ការសម្រេចចិត្តប្រើឈើកែច្នៃ ការដែលមានដែកគោលនៅក្នុងដុំឈើដែលត្រូវកាត់នៅថ្ងៃនោះ និងបំណែកដែកដែលជាប់ក្នុងភ្នែករបស់ជាងឈើ ដាក់នៅលើមែនធាងមួយ” ។ អាទិភាពសុវត្ថិភាពជារួម ឥរិយាបថចំពោះការប្រើវ៉ែនតាសុវត្ថិភាព និងបញ្ហាមិនពាក់វ៉ែនតាសុវត្ថិភាពក្នុងពេលធ្វើការនៅថ្ងៃនោះ ដាក់លើ "មែនធាង" ផ្សេងមួយទៀត ។

ជារឿយៗ មែនធាងបង្ហាញពី "ប្រព័ន្ធ" សំខាន់ៗខ្លះ ដែលគួរតែមានដើម្បីទប់ស្កាត់គ្រោះថ្នាក់ ។ ឧទាហរណ៍ ៖ លក្ខណៈបច្ចេកទេស តំហែថែទាំ និងការត្រួតពិនិត្យឧបករណ៍បរិក្ខារ ឬនីតិវិធី និងការបណ្តុះបណ្តាល គឺពិតជាមិនមាននៅទីនេះ និងបានរួមចំណែកដល់ការរងរបួស/គ្រោះថ្នាក់នោះ ។

## ឧទាហរណ៍សាមញ្ញ - ការវិភាគរបួសភ្នែក



## ការរៀនសូត្រពីគ្រោះថ្នាក់ - ការសរសេរអនុសាសន៍

តើគេអាចធ្វើអ្វីខ្លះដើម្បីកុំឱ្យគ្រោះថ្នាក់ដដែល ឬស្រដៀងគ្នានេះកើតឡើងនៅពេលអនាគត ឬកុំឱ្យកើតឡើងម្តងទៀត?

កុំបណ្តោយឱ្យខ្លួនអ្នករងការរំខានដោយអំណះអំណាងទាក់ទងនឹងអត្ថន័យនៃពាក្យមូលហេតុ "ឫសគល់" ឬ "ភ្លាមៗ" នៃគ្រោះថ្នាក់ ។ រាល់មូលហេតុដែលបានកំណត់ទាំងអស់ ត្រូវតែដោះស្រាយ ។ ជាជាងការរៀបចំដាក់មូលហេតុទៅជា "ឫសគល់" ឬ "ភ្លាមៗ" ចូរគិតអំពីដំណោះស្រាយរយៈពេលវែង មធ្យម និងរយៈពេលខ្លី ។

ពាក្យមួយអំពីទម្រង់ ដែលគេហៅថា "ការស៊ើបអង្កេតគ្រោះថ្នាក់" ឬ "ការរាយការណ៍អំពីគ្រោះថ្នាក់" ។ ទម្រង់មិនមែនជានីតិវិធីស៊ើបអង្កេតគ្រោះថ្នាក់នោះទេ ។ ប្រសិនបើស្ថាប័នរបស់អ្នក មានទម្រង់ចាំបាច់ដែលត្រូវបំពេញ នោះអ្នកធ្វើតាមនោះចុះ ។ មានហេតុផលសមស្របសម្រាប់ការរក្សាទុកព័ត៌មានមួយចំនួននៅលើទម្រង់ស្តង់ដារ ។ ទោះយ៉ាងណាក៏ដោយ ទម្រង់ក៏អាចជាឧបសគ្គរាំងអ្នក ក្នុងការស្វែងរកមូលហេតុទាំងអស់នៃគ្រោះថ្នាក់ផងដែរ ។

**ជានិច្ចជាកាល ត្រូវធ្វើការស៊ើបអង្កេតដំបូងសិន បន្ទាប់មក បំពេញទម្រង់ដោយផ្អែកលើអ្វីដែលអ្នកបានរកឃើញ ។**

ឧទាហរណ៍ (ដោយប្រើប្រាស់គ្រោះថ្នាក់ដែលបានវិភាគរួចហើយ) ៖

### រយៈពេលខ្លី ៖

1. **អនុវត្តគោលនយោបាយថ្មីស្តីពីវ៉ែនតាសុវត្ថិភាព ។**
2. **ឈប់ប្រើរណានេះ រហូតដល់ជួសជុលរួច ។**
3. **ប្រើឈើថ្មីរហូតដល់នីតិវិធីសម្រាប់ការប្រើប្រាស់ឈើចាស់ដោយសុវត្ថិភាព ត្រូវបានបង្កើតឡើង និង**
4. **ជួសជុលអំពូលភ្លើងដែលខូច ។**

### រយៈពេលមធ្យម ៖

1. **ពិភាក្សាអំពីការផ្លាស់ប្តូរចំពោះអំពូលភ្លើងបំភ្លឺជារួមនៅក្នុងគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពការងាររួម (JHSC) និង**
2. **ផ្តល់ការបណ្តុះបណ្តាលស្តីពីការការពារភ្នែក ។**

### រយៈពេលវែង ៖

1. **កែសម្រួលប្រព័ន្ធស្នើសុំការងារ ដើម្បីកាត់បន្ថយការងារប្រញាប់ប្រញាល់ និង**
2. **បង្កើតវប្បធម៌សុវត្ថិភាពតាមរយៈការប្តេជ្ញាចិត្តរបស់អ្នកគ្រប់គ្រងការអប់រំ និងការដឹកនាំដោយធ្វើជាគំរូ ។**

ជាញឹកញាប់ ដំណោះស្រាយដើម្បីទប់ស្កាត់ការកើតឡើងវិញនូវគ្រោះថ្នាក់ក្នុងរយៈពេលខ្លី គឺផ្តោតលើសម្ភារៈ ឧបករណ៍ បរិក្ខា ការការពារផ្ទាល់ខ្លួន ឬនីតិវិធីការងារជាក់លាក់ ។

ដំណោះស្រាយដែលត្រូវបានរៀបចំឡើងដើម្បីទប់ស្កាត់ការកើតឡើងវិញនូវគ្រោះថ្នាក់ក្នុងរយៈពេលវែង ជាទូទៅ ត្រូវតែដោះស្រាយប្រព័ន្ធសុវត្ថិភាព ជាជាងដោះស្រាយមុខសញ្ញាគ្រោះថ្នាក់នីមួយៗ ឬការធ្វេសប្រហែស ។

## ការស៊ើបអង្កេតជំងឺដែលទាក់ទងនឹងការងារ

នៅក្នុងផ្នែកមុន យើងបានពិភាក្សាអំពីបច្ចេកទេសមួយចំនួនដើម្បីស៊ើបអង្កេតគ្រោះថ្នាក់ និងឧបទ្ទវហេតុទាក់ទងនឹងការងារ ។ ការស៊ើបអង្កេតជំងឺទាក់ទងនឹងការងារ ក៏ជាកិច្ចការដ៏លំបាកផងដែរ ។

អ្នកវិទ្យាសាស្ត្រដ៏គួរឱ្យគោរព និងអ្នកជំនាញខាងរោគរាតត្បាត អាចជួបប្រទះបញ្ហានៅក្នុងការបង្ហាញពីមូលហេតុនៃការផ្ទុះជំងឺ ។ តើសកម្មជនសុខភាព និងសុវត្ថិភាពសហជីពថ្នាក់មូលដ្ឋាន អាចធ្វើអ្វីខ្លះបាន នៅពេលដែលមានការសង្ស័យថាមានទំនាក់ទំនងរវាងការងារ និងជំងឺ? អ្វីដែលគួរឱ្យភ្ញាក់ផ្អើល សូម្បីតែការសិក្សាស្រាវជ្រាវដោយស្ថាប័នខ្លួនឯង ក៏អាចមានប្រយោជន៍ដែរ ។ ជារឿយៗ ការសិក្សាបែបនេះ គឺជាជំហានទីមួយក្នុងការកំណត់អត្តសញ្ញាណបញ្ហានានាដូចជា សារធាតុបង្កមហារីកនៅកន្លែងធ្វើការ ទោះបីជាការសិក្សាបែបវិទ្យាសាស្ត្រដ៏ម៉ត់ចត់ជាងនេះគឺជាការចាំបាច់ដែលត្រូវធ្វើបន្តក៏ដោយ ។ ជំហានជាមូលដ្ឋាននានាដែលពាក់ព័ន្ធ រួមមាន ៖ (១) ការប្រមូលព័ត៌មាន, (២) ការវិភាគព័ត៌មាន, (៣) ការធ្វើការសន្និដ្ឋាន, (៤) ធ្វើផ្តល់អនុសាសន៍ និងតាមដានបន្ត ។ ចូរស្វែងរកដំបូន្មានមុននឹងចាប់ផ្តើម - ការស៊ើបអង្កេតដែលមានលក្ខណៈបែបនេះ បង្កជាបញ្ហាជាក់លាក់ ហើយមិនតែងតែជាការឆ្លើយតបដ៏សមស្របនោះទេ ។ នៅគ្រប់ដំណាក់កាល អ្នកចាំបាច់ត្រូវធ្វើការជាមួយថ្នាក់ដឹកនាំសហជីពរបស់អ្នក ដើម្បីជៀសវាងកំហុសដែលអាចកើតមាន ។

# ប្រព័ន្ធនិងកម្មវិធីសុវត្ថិភាព

នេះមិនមែនជារឿងដូចគ្នាទេ បើទោះបីជាទីប្រឹក្សាឬតំណាងអ្នកគ្រប់គ្រងខ្លះ បានប្រាប់អ្នកអំពីអ្វីខ្លះក៏ដោយ ។

ខាងក្រោមនេះគឺជារបៀបដែល IndustriALL កំណត់និយមន័យពាក្យសំខាន់ៗទាំងនេះ ៖

**ប្រព័ន្ធសុវត្ថិភាព** គឺជាក្របខណ្ឌទាំងមូលដែលស្ថាប័នព្យាយាមធានាថា សម្ភារៈ ឧបករណ៍ បរិយាកាសការងារ ការគ្រប់គ្រង និងមនុស្សទាំងអស់ចូលរួមចំណែកដល់សុវត្ថិភាព និងសុខភាពរបស់កម្មករ ។

**កម្មវិធីសុវត្ថិភាព** គឺជាដំណើរការដែលត្រូវបានអនុវត្តដើម្បីជំរុញសមាសភាគនានានៃប្រព័ន្ធសុវត្ថិភាពទៅកាន់កម្រិតមួយទៀតដែលកាន់តែប្រសើរ ។

**សវនកម្មសុវត្ថិភាព** គឺជាមធ្យោបាយវាស់វែងវឌ្ឍនភាពរបស់អ្នកឆ្ពោះទៅរកគោលដៅរបស់យើងដើម្បីសម្រេចបានកន្លែងធ្វើការមួយប្រកបដោយសុវត្ថិភាព និងសុខភាពល្អ ។

| | |
|---|---|
| ប្រព័ន្ធសុវត្ថិភាព | **គឺជាអ្វីដែលអ្នកចង់បាន** |
| កម្មវិធីសុវត្ថិភាព | **ជួយឱ្យអ្នកសម្រេចបានគោលដៅនេះ** |
| សវនកម្មសុវត្ថិភាព | **វាស់វែងវឌ្ឍនភាពរបស់អ្នក** |

## សវនកម្មសុវត្ថិភាព

សវនកម្ម ៖ គឺជាដំណើរការជាលក្ខណៈប្រព័ន្ធ ឯករាជ្យ និងមានការកត់ត្រាទុកជាឯកសារដើម្បីទទួលបានភស្តុតាង និងវាយតម្លៃភស្តុតាងនោះដើម្បីកំណត់វិសាលភាពនៃការបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ។

នេះមិនសុទ្ធតែមានន័យថា សវនកម្មខាងក្រៅឯករាជ្យនោះទេ (ដោយសវនករមកពីខាងក្រៅស្ថាប័ន) ។

សៀវភៅណែនាំនេះចាត់ទុកសវនកម្ម ជាឧបករណ៍វាយតម្លៃមួយ ដែលត្រូវបានប្រើដើម្បីវាស់វែងវឌ្ឍនភាពរបស់ស្ថាប័នក្នុងការសម្រេចបានគោលបំណងសុខភាព សុវត្ថិភាព និងបរិស្ថាន ។

ដើម្បីអនុវត្តសវនកម្មសុវត្ថិភាព ជាធម្មតា សកម្មភាពសុខភាពនិងសុវត្ថិភាពការងារ ត្រូវបានបែងចែកចេញជាប្រធានបទផ្សេងៗ ។

ប្រធានបទទាំងនេះត្រូវបានជ្រើសរើសដើម្បីពិពណ៌នាអំពីសមាសភាគសំខាន់ៗនៃប្រព័ន្ធសុវត្ថិភាព ហើយជារឿយៗ ត្រូវបានគេហៅថា សមាសធាតុ ។ សម្រាប់សមាសធាតុនីមួយៗ សវនកម្មមានគោលបំណងបង្កើតវិធីសាស្ត្រជាលក្ខណៈប្រព័ន្ធដើម្បីស្រាវជ្រាវរក និងការកែតម្រូវមុខសញ្ញាគ្រោះថ្នាក់ ។ ក្នុងន័យនេះ កិច្ចការនេះ ជាធម្មតាពាក់ព័ន្ធនឹងជំហានទាំងឡាយដូចខាងក្រោម ៖

1. **ការកំណត់ និងការវាស់វែងនៃសូចនាករសមស្រប**
2. **ការអនុម័តស្តង់ដារសមស្រប**
3. **ការប្រៀបធៀបសូចនាករការអនុវត្តចុងក្រោយ ជាមួយនឹងស្តង់ដារ ហើយពិនិត្យឡើងវិញលើបញ្ហាទាំងមូលឡើងវិញប្រសិនបើចាំបាច់**

ដូចដែលបានពិភាក្សាពីមុនមកហើយ ការរៀបចំសូចនាករ និងស្តង់ដារសមស្រប គឺជាកិច្ចការដ៏លំបាកមួយដែលមនុស្សជាច្រើនជួបប្រទះនៅពេលព្យាយាមអនុវត្តសវនកម្មសុវត្ថិភាព ។ ក្រោយមកទៀត នៅក្នុងសៀវភៅណែនាំនេះ អ្នកនឹងឃើញសំណូមពរមួយចំនួនអំពីសូចនាករ ។

សវនកម្មសុវត្ថិភាពអាចត្រូវបានគេប្រើជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍ និងការវាយតម្លៃនៃកម្មវិធីសុវត្ថិភាព ។ កម្មវិធីសុវត្ថិភាពអាចរួមមាននីតិវិធី ឬគោលនយោបាយដែលត្រូវបានរៀបចំឡើងដើម្បីកែលម្អការអនុវត្តសុវត្ថិភាពរបស់ស្ថាប័ន ។ កិច្ចការនេះអាចរួមបញ្ចូលការកំណត់ស្តង់ដារថ្មីសម្រាប់ជំហានទី ៣ នៃដំណើរការសវនកម្ម ។ តាមរយៈការធ្វើសវនកម្មនៅមុនពេលនិងក្រោយពេលអនុវត្តកម្មវិធីសុវត្ថិភាព សវនករអាចវាយតម្លៃថា តើកម្មវិធីបច្ចុប្បន្នរបស់អ្នកកំពុងមានដំណើរការឬអត់ និងជួយអ្នក ធ្វើការសម្រេចចិត្តអំពីកម្មវិធីនាពេលអនាគត ។

ការត្អូញត្អែរដ៏ធ្ងន់ធ្ងរបំផុតអំពីគម្រោងសវនកម្មសុវត្ថិភាពមួយចំនួនគឺថា កម្មករអាចមានអារម្មណ៍ថា ពួកគេមិនត្រូវបានគេយកចិត្តទុកដាក់ ហើយប្រសិនបើទំនាក់ទំនងតែមួយគត់ដែលពួកគេមានជាមួយកម្មវិធីនោះ គឺជាការជួបម្តងម្កាលជាមួយសវនករ ដែលពួកគេអាចមានអារម្មណ៍ថាត្រូវបានគេលួចតាមដានមើល ។ ក្រុមហ៊ុនទីប្រឹក្សាមួយចំនួនដែលផ្តល់សេវាសវនកម្មសុវត្ថិភាព មានបទពិសោធន៍តិចតួច ឬគ្មានបទពិសោធន៍ជាមួយគណៈកម្មការសុខភាព និងសុវត្ថិភាពរួម ហើយមានចំណាប់អារម្មណ៍តិចតួចក្នុងការសម្របសម្រួលកិច្ចការនេះ ។

ដើម្បីសម្រេចបានលទ្ធផលល្អបំផុតពីការធ្វើសវនកម្មសុវត្ថិភាព ត្រូវមានការប្រាស្រ័យទាក់ទងឱ្យបានច្រើន ។

គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម គួរតែចូលរួមឱ្យបានពេញលេញក្នុងការអនុវត្តកម្មវិធី, ចូលរួមយ៉ាងហោចណាស់នៅក្នុងសវនកម្មមួយចំនួន, ទទួលរបាយការណ៍ និងផ្តល់អនុសាសន៍ដោយផ្អែកលើសវនកម្មទាំងនោះ ។

មនុស្សគ្រប់រូបគួរតែទទួលបានរបាយការណ៍ពីសវនកម្មខាងក្នុង និងខាងក្រៅ ប៉ុន្តែគេគួរខិតខំប្រឹងប្រែដើម្បីផ្តល់ព័ត៌មានអំពីលទ្ធផលដែលពាក់ព័ន្ធ ដល់កម្មករដែលបានចូលរួមនៅក្នុងសវនកម្ម ឬដែលអាចត្រូវបានប៉ះពាល់ដោយអនុសាសន៍ដែលកើតចេញពីសវនកម្មទាំងនោះ ។

## កម្មវិធីសុវត្ថិភាព

ប្រសិនបើកម្មវិធីសុវត្ថិភាពនៅតែធ្វើការងារបានល្អនៅក្នុងការវិភាគមុខសញ្ញាគ្រោះថ្នាក់ និងការបង្កើតវិធានការបង្ការប្រកបដោយប្រសិទ្ធភាព នោះនឹងមានការផ្លាស់ប្តូរបន្តិចម្តងៗទៅលើឥរិយាបថ និងការចាប់ផ្តើមអនុវត្ត "វប្បធម៌សុវត្ថិភាព" កាន់តែប្រសើរឡើង ។

ការគ្រប់គ្រងការផ្លាស់ប្តូរនៅកន្លែងធ្វើការមានសារៈសំខាន់ ដូច្នេះ នីតិវិធីគួរតែត្រូវបានពិនិត្យឡើងវិញឱ្យបានញឹកញាប់ និងតាមតម្រូវការជាក់ស្តែង ។ អ្នកម៉ៅការត្រូវតែអនុលោមតាមស្តង់ដារដូចគ្នានឹងនិយោជិតដែរ ។ ការស៊ើបអង្កេតគ្រោះថ្នាក់/ឧប្បត្តិហេតុ និងការរៀបចំផែនការគ្រោះបន្ទាន់ ក៏ជាផ្នែកមួយនៃកម្មវិធីផងដែរ ។ បញ្ហាទាំងនេះត្រូវបានដោះស្រាយនៅក្នុងគ្រោងសវនកម្មសុវត្ថិភាពភាគច្រើន ។

ជាធម្មតា សកម្មភាពទាំងនេះត្រូវបានធ្វើឡើងនៅកន្លែងធ្វើការ ដែលគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម មានដំណើរការតាមការគ្រោងទុក ។ ដោយសារហេតុផលនេះហើយ ដែល IndustriALL ចាត់ទុកថា គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមដែលមានប្រសិទ្ធភាព គឺជាកម្មវិធីសុវត្ថិភាព "របស់យើង" ។ ជារឿយៗ គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងការវិភាគមុខសញ្ញាគ្រោះថ្នាក់ និងការរៀបចំវិធានការបង្ការដូចជា ស្តង់ដារនៃការទិញ និងនីតិវិធីការងារប្រកបដោយសុវត្ថិភាព ។ គណៈកម្មាធិការរបស់យើងជាច្រើន ប្រើសវនកម្មជាមធ្យោបាយមួយដើម្បីកំណត់អត្តសញ្ញាណ និងគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ជាលក្ខណៈប្រព័ន្ធ ។

IndustriALL ជឿជាក់ថា គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមដែលមានប្រសិទ្ធភាព គឺជា "កម្មវិធីសុវត្ថិភាព" តែមួយគត់ ដែលចាំបាច់ និងគ្រប់គ្រាន់ ដើម្បីសម្រេចបានឧត្តមភាពក្នុងការអនុវត្តវិធានការសុខភាព និងសុវត្ថិភាពការងារ ។

កម្មវិធីផ្សេងទៀតដែលនិយោជក ឬរដ្ឋាភិបាលអាចគាំទ្រ ត្រូវតែអនុវត្តតាមរយៈគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ដោយមានការឯកភាពជាមុនពីសហជីព ។

គោលការណ៍នៃការយកចិត្តទុកដាក់ដោយសមស្រប អាចត្រូវបានប៉ះពាល់ ប្រសិនបើមានការភាន់ច្រឡំអំពីថាតើក្រុមណាដែលជាអ្នកទទួលខុសត្រូវនៅកន្លែងធ្វើការ ។ (ឧទា. ក្រុមសវនកម្មសុវត្ថិភាព អ្នកដឹកនាំកម្មវិធីសុវត្ថិភាព ឬគណៈកម្មាធិការសុខភាពនិងសុវត្ថិភាពរួម និងតំណាង) ។ ប្រសិនបើបញ្ហានេះត្រូវបានគេទុកឱ្យកើតឡើង នោះបញ្ហាសុវត្ថិភាពសំខាន់ៗអាចត្រូវបាត់បង់ រវាងគណៈកម្មាធិការនានាដែលប្រកួតប្រជែងគ្នា ហើយអារម្មណ៍នៃការខកចិត្តអាចកើតឡើង ដែលនឹងជះឥទ្ធិពលអវិជ្ជមានទៅលើឥរិយាបថរបស់មនុស្សគ្រប់រូបនៅកន្លែងធ្វើការទាក់ទងនឹងសុខភាព និងសុវត្ថិភាព ។

# ការដោះស្រាយបញ្ហាជាមូលដ្ឋាន

នៅក្នុងសុខភាព និងសុវត្ថិភាពការងារ ជាការប្រសើរដែលត្រូវមានប្រព័ន្ធដើម្បីទប់ស្កាត់គ្រោះថ្នាក់មិនឱ្យកើតឡើង ជាជាងគ្រាន់តែកំណត់មុខសញ្ញាគ្រោះថ្នាក់ និងកែតម្រូវវា ។ ដូច្នេះហើយបានគេត្រូវធ្វើសវនកម្មសុវត្ថិភាពឱ្យបានច្រើនជាងការត្រួតពិនិត្យនៅកន្លែងធ្វើការតាមធម្មតា ។

មានជំហានមួយចំនួនដែលត្រូវតែអនុវត្តតាម ដើម្បីដោះស្រាយបញ្ហាណាមួយ ៖

1. **យល់ច្បាស់ថាតើបញ្ហានោះគឺជាអ្វី ។**
2. **ប្រមូលព័ត៌មាន ។**
3. **វិភាគព័ត៌មាន ។ តើព័ត៌មាននោះគឺអំពីអ្វី?**
4. **ធ្វើការសម្រេចចិត្តណាដែលអ្នកគិតថា នឹងអាចដោះស្រាយបញ្ហានោះបាន ។**
5. **អនុវត្តការសម្រេចចិត្តរបស់អ្នក ហើយតាមដានបន្ត ដើម្បីប្រាកដថា បញ្ហានោះត្រូវបានដោះស្រាយ ។**

ដំណើរការជាមូលដ្ឋាននេះនឹងជួយអ្នកក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាភាគច្រើន ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងបញ្ហាដែលស្មុគស្មាញជាងនេះ ប្រព័ន្ធនេះនឹងជួយឱ្យមានស្តង់ដារ ឬគោលដៅ និងសូចនាករ ។ នេះមិនមែនជាដំណើរការដោះស្រាយបញ្ហាផ្សេងមួយទៀតនោះទេ ប៉ុន្តែជាការរៀបរាប់លម្អិតអំពីដំណើរការដែលបានរៀបរាប់ខាងលើ ។ ប្រសិនបើអ្នកដឹងពីកម្រិត ឬស្តង់ដារនៃការអនុវត្តដែលធ្វើឱ្យអ្នកសប្បាយចិត្ត នោះគឺអ្នកមានគោលដៅហើយ ។ ប្រសិនបើអ្នកមានវិធីមួយចំនួនក្នុងការវាស់វែងនូវកម្រិតនៃការអនុវត្តនោះ នោះមានន័យថាអ្នកមានសូចនាករមួយ ។

នេះប្រហែលជាងាយស្រួលយល់ជាង ដោយប្រើឧទាហរណ៍មួយ ។ ឧបមាថា គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមរបស់អ្នក មានការព្រួយបារម្ភអំពីជណ្តើរដែលមានបញ្ហា ។ អ្នកសម្រេចចិត្តព្យាយាមដោះស្រាយបញ្ហានេះ ដោយធ្វើតាមនីតិវិធីខាងលើ ។

1. **ការកំណត់បញ្ហា ៖ មានជណ្តើរមានបញ្ហាដ៏ច្រើនសន្ធឹកសន្ធាប់ដែលមិនអាចទទួលយកបាននៅក្នុងរោងចក្រ ។**
2. **សូចនាកររបស់អ្នក គឺជារបាយការណ៍ត្រួតពិនិត្យកន្លែងធ្វើការប្រចាំខែ ។ បច្ចុប្បន្ននេះ ចំនួនមធ្យមនៃជណ្តើរដែលខូចដែលបានរកឃើញ គឺចំនួនប្រាំ ឬប្រាំមួយក្នុងមួយខែ ។**
3. **គោលដៅដែលត្រូវបានព្រមព្រៀងគ្នា គឺដើម្បីស្វែងរកឃើញកាំជណ្តើរដែលមានបញ្ហាមិនលើសពីមួយក្នុងមួយឆ្នាំ ។**
4. **គណៈកម្មាធិការប្រមូលព័ត៌មានមួយចំនួនអំពីប្រភេទនៃជណ្តើរការងារដែលត្រូវប្រើជណ្តើរទាំងនោះ ផ្នែកដែលមានបញ្ហាជណ្តើរញឹកញាប់បំផុត ។ល។**
5. **អ្នក ធ្វើការវិភាគព័ត៌មាន ។ ឧទាហរណ៍ អ្នកអាចជជែកគ្នាថា តើបញ្ហានោះកើតឡើងដោយសារតែការមិនបានទិញជណ្តើរធន់ធ្ងន់ កង្វះកន្លែងរក្សាទុកជណ្តើរ ឬការប្រើប្រាស់ជណ្តើរមិនបានត្រឹមត្រូវ ។**
6. **គណៈកម្មាធិការ សម្រេចថា បញ្ហាចម្បងគឺមកពីជណ្តើរតែម្តង ហើយថាជណ្តើរដែលធន់ធ្ងន់គួរទទួលបាន។ ការព្រួយបារម្ភក្រៅពីនេះអំពីការប្រើប្រាស់កន្លែងរក្សាទុក និងរន្ទា គឺត្រូវដោះស្រាយដោយដាក់បញ្ចូលទៅក្នុងគោលនយោបាយថ្មី និងកម្មវិធីអប់រំសម្រាប់និយោជិត ។**
7. **អ្នកគ្រប់គ្រងទទួលយកអនុសាសន៍របស់គណៈកម្មាធិការ ។ ជណ្តើរថ្មីត្រូវបានទិញ ហើយជណ្តើរចាស់ត្រូវបានយកចេញពីកន្លែងធ្វើការ ។ គោលនយោបាយថ្មីត្រូវបានបង្កើតឡើង ហើយការប្រើប្រាស់ និងការរក្សាទុករន្ទា និងជណ្តើរគឺជាប្រធានបទនៃកម្មវិធីអប់រំនៅក្នុងរោងចក្រទាំងមូល ។**
8. **បន្ទាប់ពីរយៈពេលពីរបីខែមក គណៈកម្មាធិការពិនិត្យមើលរបាយការណ៍ត្រួតពិនិត្យប្រចាំខែ ហើយរកឃើញថា ចំនួនជណ្តើរដែលមានបញ្ហា បានធ្លាក់ចុះយ៉ាងខ្លាំង ។**
9. **គណៈកម្មាធិការអបអរសាទរខ្លួនឯង ចំពោះការងារដែលខ្លួនធ្វើបានល្អ ហើយបន្តតាមដានមើលរបាយការណ៍ត្រួតពិនិត្យប្រចាំខែ ។**

អ្វីដែលគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមបានធ្វើ ក្នុងន័យនេះ គឺបង្កើតប្រព័ន្ធមួយសម្រាប់ទប់ស្កាត់មុខសញ្ញាគ្រោះថ្នាក់នៃជណ្តើរដែលខូច ។ ប្រព័ន្ធនេះរួមបញ្ចូលសមាសធាតុជាច្រើន ។ សម្ភារៈសមស្របត្រូវបានបញ្ជាក់ ។ គោលនយោបាយសម្រាប់ការប្រើប្រាស់ និងការថែទាំសម្ភារៈទាំងនេះ ត្រូវបានដាក់បញ្ចូល ។ ការអប់រំត្រូវបានអនុវត្ត ។ ការពិនិត្យឡើងវិញតាមកាលកំណត់ នឹងត្រូវធ្វើឡើង ។

## សូចនាករ និងស្តង់ដារ

សូចនាករ - អ្វីមួយដែលអ្នកអាចវាស់វែង ដែលបង្ហាញពីលទ្ធផលនៃការអនុវត្តវិធានការសុខភាព និងសុវត្ថិភាព ។

ស្តង់ដារ - កម្រិតនៃការអនុវត្តដែលសូចនាករពាក់ព័ន្ធគួរតែផ្តោតទៅលើ ។

គួរឱ្យស្តាយ ស្ថិតិគ្រោះថ្នាក់ គឺជាសូចនាករដែលគេប្រើជាទូទៅបំផុតសម្រាប់លទ្ធផលនៃការអនុវត្តវិធានការសុខភាព និងសុវត្ថិភាពរបស់និយោជក ។ ប៉ុន្តែ យើងដឹងថា ស្ថិតិទាំងនេះមិនត្រឹមត្រូវទេ ។

អត្រាគ្រោះថ្នាក់ដែលអាចកត់ត្រាទុក ឬអាចរាយការណ៍បាន មិនមែនជាសូចនាករសមស្របសម្រាប់សវនកម្មសុវត្ថិភាពនោះទេ ដោយសារតែហេតុផលជាច្រើនដូចខាងក្រោម ៖

1. **អត្រាទាំងនេះមិនមានភាពត្រឹមត្រូវទេ ដោយសារតែការរាយការណ៍មិនត្រឹមត្រូវ**
2. **អត្រាទាំងនេះងាយក្នុងការកែប្រែ**
3. **វាគឺជាព្រឹត្តិការណ៍ដ៏កម្រ - វាមិនតំណាងឱ្យការផលិត ឬប្រតិបត្តិការធម្មតាទេ ប៉ុន្តែផ្ទុយទៅវិញ វាជាផលវិបាកនៃស្ថានភាពមិនប្រក្រតី ឬករណីពិសេស ។**
4. **ទីកន្លែងធ្វើការភាគច្រើន មានកម្លាំងការងារតិចតួចពេក ដែលធ្វើឱ្យគេមិនចាត់ទុកស្ថិតិគ្រោះថ្នាក់ម្តងម្កាលជារឿងបានការនោះឡើយ ។**

ដូច្នេះ ស្ថិតិអំពីគ្រោះថ្នាក់មានន័យតិចតួច ។ ប្រសិនបើព័ត៌មានផ្សេងទៀតត្រូវបានពិនិត្យក្នុងពេលតែមួយនោះ ស្ថិតិទាំងនោះនឹងកាន់តែមានន័យថែមទៀត ។ សវនកម្មតម្រូវឱ្យយើងវាស់វែង ឬតាមដានទៅលើអ្វីមួយ ។ សំណួរគឺថា តើអ្វីទៅជាលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសសូចនាករ? តើគោលដៅ និងគោលបំណងមួយណា? សកម្មភាពអ្វីខ្លះ?

អ្វីដែលសូចនាករគួរធ្វើ គឺបង្ហាញថា តើស្ថាប័នយកចិត្តទុកដាក់ខ្លាំងប៉ុណ្ណាចំពោះបញ្ហាសុវត្ថិភាព ពោលគឺ អ្វីមួយអំពី "វប្បធម៌សុវត្ថិភាព" ។ ប្រសិនបើយើងត្រូវតែវាស់វែងអ្វីមួយ ពេលនោះអាចមានសូចនាករមួយចំនួនតូច ដែលអាចយកមកប្រើនៅកន្លែងធ្វើការធម្មតា ។ លក្ខណៈវិនិច្ឆ័យខ្លះសម្រាប់ការជ្រើសរើសសូចនាករអាចមានដូចខាងក្រោម ។ អ្វីដែលល្អបំផុត គឺ ៖

- **គួរតែផ្អែកលើលក្ខខណ្ឌដែលយើងពិតជាចង់ដោះស្រាយឱ្យបាន ឬកំពុងព្យាយាមទប់ស្កាត់**
- **គួរតែមិនផ្តោតលើបុគ្គល និងមិនស្តីបន្ទោស**
- **មិនគួរត្រូវបានភ្ជាប់ជាចម្បងទៅនឹងការខូចគាំង គ្រោះថ្នាក់ ឬវិបត្តិផ្សេងៗទៀតទេ (ទោះជាយ៉ាងណាក្តី សូចនាករខ្លះ នៅតែពាក់ព័ន្ធនឹងបញ្ហាទាំងនេះផងដែរ)**
- **គួរតែអាចត្រួតពិនិត្យមើលជាញឹកញាប់ ហើយគួរតែអាចផ្តល់ព័ត៌មាន យ៉ាងហោចណាស់ព័ត៌មានបែបគុណភាព ប៉ុន្តែយកល្អព័ត៌មានបែបបរិមាណ**
- **គួរតែអាចប្រៀបធៀបបាននៅក្នុងបរិយាកាសនៅកន្លែងធ្វើការផ្សេងៗគ្នា**
- **គួរតែមានន័យផ្នែកស្ថិតិ**

ចាំបាច់ត្រូវមានយន្តការវាយតម្លៃ ឬវាស់វែង ព្រោះជារឿយៗ ជាការសំខាន់ដែលត្រូវមានរង្វាស់មួយចំនួនទៅលើការអនុវត្តដើម្បីកំណត់ពីផ្នែកនានាសម្រាប់ការកែលម្អ ។ សវនកម្មដែលមិនអាចផ្តល់ការវាយតម្លៃទូទៅខ្លះទៅលើថាតើស្ថាប័នមានដំណើរការទៅល្អប៉ុណ្ណា បើប្រៀបធៀបទៅនឹងស្តង់ដាររបស់ខ្លួន ហើយបើប្រៀបធៀបទៅនឹងស្ថាប័នស្រដៀងគ្នាផ្សេងទៀត នឹងមិនត្រូវបានគេចាត់ទុកថាមានប្រយោជន៍ដូចសវនកម្មដែលអាចធ្វើបាននោះទេ ។

## សូចនាករសម្រាប់សវនកម្មសុវត្ថិភាព

ដើម្បីអនុវត្តសវនកម្មសុវត្ថិភាពគ្រប់ជ្រុងជ្រោយ ប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារសារវន្ត ត្រូវតែដាក់បញ្ចូលក្នុងសវនកម្មនោះផងដែរ ។ សម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ប្រព័ន្ធចំនួនប្រាំមួយត្រូវបានកំណត់ដូចខាងក្រោម ។ កញ្ចប់សវនកម្មសុវត្ថិភាពពាណិជ្ជកម្មខ្លះអាចមានក្រុមច្រើន ឬតិចជាងនេះ ។

ប្រព័ន្ធទាំងប្រាំមួយនេះ គឺ ៖

1. **គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមដែលមានប្រសិទ្ធភាព**
2. **អ្នកគ្រប់គ្រងដែលមានការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់**
3. **ប្រព័ន្ធធនធានមនុស្ស ៖ ធានាថា មនុស្សត្រឹមត្រូវត្រូវបានចាត់តាំងឱ្យធ្វើការងារត្រឹមត្រូវ រួមទាំងការបណ្តុះបណ្តាល និងការលើកទឹកចិត្ត**
4. **ប្រព័ន្ធវិស្វកម្ម ការរចនាការងារ និងវិធាន និងនីតិវិធីការងារ ៖ ធានាថា ការងារ និងភារកិច្ចត្រូវបានតាក់តែងឡើងយ៉ាងត្រឹមត្រូវដើម្បីចាប់ផ្តើម ហើយមាននីតិវិធីដើម្បីការងារទាំងនេះដោយសុវត្ថិភាព ។**
5. **ប្រព័ន្ធទិញ និងថែទាំ ៖ ធានាថា សម្ភារៈ ឧបករណ៍ និងបរិក្ខារមានសុវត្ថិភាពបំផុតតាមដែលអាចធ្វើទៅបាន។**
6. **ប្រព័ន្ធសុវត្ថិភាព និងអនាម័យការងារ ៖ ធានាថា មានបរិយាកាសការងារដែលមានសុវត្ថិភាព និងសុខភាពល្អបំផុតដែលអាចធ្វើទៅបានប្រកបដោយនិរន្តរភាព**

# របៀបវាស់វែង និងវាយតម្លៃប្រព័ន្ធសុខភាពនិងសុវត្ថិភាព

"កម្រងសូចនាករ" ខាងក្រោមនេះ មានគោលបំណងជាចម្បងសម្រាប់អ្នកដែលចាប់អារម្មណ៍ក្នុងការតាក់តែង និងអនុវត្តសវនកម្មសុវត្ថិភាពប្រកបដោយគុណភាព ។ ការពិនិត្យឡើងវិញតាមកាលកំណត់ជាបន្តបន្ទាប់ទៅលើសូចនាករទាំងនេះ នឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ដឹងថា តើការអនុវត្តសុវត្ថិភាពរបស់ពួកគេមានភាពប្រសើរឡើង កាន់តែយ៉ាប់យ៉ឺន ឬនៅដដែល ។

ម្យ៉ាងទៀត សហជីពមូលដ្ឋានអាចប្រើសូចនាករទាំងនេះជាបច្ចេកទេសវាយតម្លៃដោយខ្លួនឯង ដើម្បីវិនិច្ឆ័យថាតើផ្នែកណាខ្លះនៃប្រព័ន្ធសុខភាពនិងសុវត្ថិភាពរបស់ពួកគេ ដែលត្រូវការការយកចិត្តទុកដាក់ ។

សូចនាករនីមួយៗខាងក្រោមនេះ ត្រូវបានពិពណ៌នាដោយសំណួរជាបន្តបន្ទាប់ ដែលលើកឡើងថាតើប្រព័ន្ធ និងប្រព័ន្ធរងប្រភេទណាខ្លះគួររៀបចំឡើង ។ លើសពីនេះទៀត គំនិតទូទៅខ្លះអំពីនរណាដែលត្រូវសួរ ឬកន្លែងដែលត្រូវរកមើលចម្លើយចំពោះសំណួរ ត្រូវបានផ្តល់ជូនផងដែរ ។

## សូចនាករនៃគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម (JHSC) ដែលមានប្រសិទ្ធភាព

1. **ការចូលរួម ៖** តើគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមចូលរួមក្នុងដំណាក់កាលរៀបចំផែនការ ការអភិវឌ្ឍ និងការអនុវត្តសម្រាប់បញ្ហាសុខភាពនិងសុវត្ថិភាពការងារទាំងអស់ដែរឬទេ? ប៉ាន់ស្មានបញ្ហានេះ ដោយការស្ទង់មតិសមាជិក JHSC ។
2. **ប្រសិទ្ធភាព ៖** តើអនុសាសន៍របស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ជាទូទៅ ត្រូវបានគេអនុវត្ត (ភាគរយនៃពេលវេលា) ដែរឬទេ? តើសកម្មភាព "ការងារចាស់" មានចំនួនប៉ុន្មានដែលមិនទាន់បានដោះស្រាយអស់រយៈពេលជាងបីខែ? តើចំណុចនៃសកម្មភាពរបស់ JHSC ប៉ុន្មានភាគរយ ត្រូវបានដោះស្រាយក្នុងរយៈពេលមួយខែ ឬតិចជាងនេះ? មួយឆ្នាំឬយូរជាងនេះ? ប៉ាន់ស្មានភាគរយនេះ ដោយពិនិត្យមើលកំណត់ហេតុកិច្ចប្រជុំ JHSC ។
3. **អាទិភាព និងការគាំទ្ររបស់អ្នកគ្រប់គ្រង ៖** តើរយៈពេលជាមធ្យមសម្រាប់នាយកដ្ឋានវិស្វកម្ម ឆ្លើយតបទៅនឹងការសាកសួរពីគណៈកម្មាធិការសុវត្ថិភាពគឺប៉ុន្មាន ធៀបនឹងរយៈពេលជាមធ្យមសម្រាប់ផ្នែកវិស្វកម្មដែលឆ្លើយតបទៅនឹងការសាកសួរពីអ្នកគ្រប់គ្រងផលិតកម្ម? ប៉ាន់ស្មានរយៈពេលនេះ ដោយការពិនិត្យមើលកំណត់ហេតុរបស់ JHSC ការស្ទង់មតិសមាជិក JHSC ការស្ទង់មតិសមាជិកនៃផ្នែកវិស្វកម្ម ។
4. **ការគាំទ្រផ្នែកបច្ចេកទេស ៖** តើអ្នកបច្ចេកទេសមិន "គ្រប់គ្រង" គណៈកម្មាធិការនេះ ប៉ុន្តែតើការគាំទ្រផ្នែកបច្ចេកទេសអាចរកបានឬទេសម្រាប់គណៈកម្មាធិការនេះនៅពេលចាំបាច់? ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យមើលកំណត់ហេតុរបស់ JHSC និងការស្ទង់មតិសមាជិក JHSC ។
5. **ការយល់ដឹងរបស់កម្មករ ៖** តើកំណត់ត្រាពេញលេញនៃអនុសាសន៍ទាំងអស់របស់ JHSC និងស្ថានភាពនៃអនុសាសន៍ (ត្រូវបានទទួលយក បដិសេធ ពេញលេញ កំពុងរង់ចាំ) ក៏ដូចជាហេតុផលសម្រាប់ស្ថានភាពបច្ចុប្បន្ននៃអនុសាសន៍ទាំងនេះ មានសម្រាប់កម្មករទាំងអស់ដែរឬទេ? តើកម្មករជាសមាជិកនៃ JHSC រាយការណ៍ជូនកិច្ចប្រជុំសហជីពមូលដ្ឋានជាទៀងទាត់ដែរឬទេ? ប៉ាន់ប្រមាណបញ្ហានេះ ដោយពិនិត្យមើលកំណត់ត្រាលាយលក្ខណ៍អក្សរដែលមានសម្រាប់កម្មករ និងធ្វើការស្ទង់មតិកម្មករ ។
6. **កម្មវិធីសុវត្ថិភាពរបស់ក្រុមហ៊ុន ៖** តើក្រុមហ៊ុនចូលរួមក្នុងកម្មវិធីសុវត្ថិភាព "ជាកញ្ចប់" ដែរទេ? តើកម្មវិធីសុវត្ថិភាពរបស់ក្រុមហ៊ុនគាំទ្រ គេចវេស ឬបំផ្លាញ JHSC ដែរឬទេ?

   ដើម្បីបញ្ជាក់បន្ថែម តើ JHSC៖ (ក) បញ្ជាកម្មវិធីដែរឬទេ? (ខ) ចូលរួមក្នុងការអនុវត្តកម្មវិធីឬទេ? (គ) ទទួលព័ត៌មានអំពីស្ថានភាពរបស់កម្មវិធីឬទេ? (ឃ) មិនមានតួនាទីអ្វីនៅក្នុងកម្មវិធីឬទេ? ប៉ាន់ស្មាន ដោយការស្ទង់មតិសមាជិក JHSC ។

## សូចនាករនៃអ្នកគ្រប់គ្រងដែលមានការប្តេជ្ញាចិត្តជាក់លាក់

1. **វប្បធម៌សុវត្ថិភាព ៖** តើនិយោជិតណាម្នាក់ អាចរាយការណ៍ថា យ៉ាងហោចណាស់ម្តងក្នុងឆ្នាំមុន ពួកគេត្រូវបានលើកទឹកចិត្តបង្ខិតបង្ខំ ឬជំរុញឱ្យមិនគោរពច្បាប់ ឬនីតិវិធីដោយមេការ/អ្នកត្រួតពិនិត្យការងារ ឬនិយោជិតរួមការងារឬទេ? តើធ្លាប់មានការដាក់ពិន័យចំពោះការរំលោភលើសុខភាព និងសុវត្ថិភាពដែរឬទេ? (សូចនាករអវិជ្ជមាន - ប្រសិនបើវិន័យត្រូវបានប្រើដើម្បីធានាការអនុលោមតាមមុខសញ្ញាគ្រោះថ្នាក់សុខភាព និងសុវត្ថិភាព កម្មករនឹងឆ្លើយតបដោយការលាក់បាំងបញ្ហា ។) ប៉ាន់ស្មានបញ្ហានេះ ដោយការស្ទង់មតិបុគ្គលិក ។ ការស្ទង់មតិអំពីឥរិយាបថសុខភាព និងសុវត្ថិភាពជារួម គឺជាប្រភពព័ត៌មានដ៏ល្អប្រសើរ ។ អ្វីដែលមានប្រយោជន៍ផងដែរ គឺការស្ទង់មតិរបស់កម្មករបច្ចុប្បន្ន និងអតីតកាល (មិនបញ្ចេញឈ្មោះ) ដោយសួរពួកគេអំពីការរងរបួស ឬជំងឺដែលពួកគេយល់ថាពាក់ព័ន្ធនឹងការងាររបស់ពួកគេ ក៏ដូចជាការយល់ឃើញរបស់ពួកគេអំពី "វប្បធម៌សុវត្ថិភាព" ។
2. **អនុលោមភាព ៖** តើក្រុមហ៊ុនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានដែរឬទេ? តើមាននរណាម្នាក់ (អ្នកគ្រប់គ្រង ឬកម្មករ) នៅក្នុងស្ថាប័ន ធ្លាប់ត្រូវបានចោទប្រកាន់ពីបទរំលោភលើសុខភាព និងសុវត្ថិភាពដោយភ្នាក់ងារអនុវត្តច្បាប់ដែរឬទេ?
3. **សិទ្ធិក្នុងការដឹង ៖** សម្រាប់សារធាតុគីមី និងសារធាតុគ្រោះថ្នាក់មួយចំនួនទៀត មានប្រព័ន្ធចំណាត់ថ្នាក់ និងការដាក់ស្លាកសម្គាល់សារធាតុគីមីសុខដុមនីយកម្មសកល (GHS) ដែលកំណត់ស្តង់ដារអប្បបរមាមួយចំនួនសម្រាប់ការដាក់ស្លាកសម្គាល់ និងការបង្ហាញព័ត៌មាន ។ កម្មករនិយោជិតទាំងអស់គួរតែមានចំណេះដឹង និងទទួលបានព័ត៌មាននេះ, និងត្រូវបានផ្តល់ការអប់រំ និងការបណ្តុះបណ្តាលដែលចាំបាច់ ដើម្បីយល់ពីប្រព័ន្ធនេះ ។ សូម

កត់សម្គាល់ថា ប្រព័ន្ធនេះអាចត្រូវបានគេស្គាល់ដោយឈ្មោះផ្សេងៗគ្នានៅក្នុងប្រទេសផ្សេងៗ ឧទាហរណ៍ ប្រព័ន្ធព័ត៌មានសម្ភារៈគ្រោះថ្នាក់នៅកន្លែងធ្វើការ (WHMIS) ឬជាធម្មតាគេហៅថា ប្រព័ន្ធព័ត៌មានសម្ភារៈគ្រោះថ្នាក់ (HMIS) ។ បណ្ណាល័យរក្សាទុកបណ្ណទិន្នន័យសុវត្ថិភាពសម្ភារៈ (SDS ឬនៅក្នុងប្រទេសខ្លះ គេហៅថា MSDS) គួរតែមានភាពពេញលេញ និងទាន់សម័យ ។ អ្នកគ្រប់គ្រងត្រូវតែស្នើសុំ SDS ដែលមានភាពត្រឹមត្រូវពីអ្នកផ្គត់ផ្គង់ ។ តើអ្នកគ្រប់គ្រងសាកសួរអ្នកផ្គត់ផ្គង់ឬទេនៅពេលពួកគេផ្ដល់ SDS ដែលហាក់ដូចជាមានភាពមិនត្រឹមត្រូវ ឬមិនមានព័ត៌មានពាក់ព័ន្ធ? ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យជាមួយអាជ្ញាធរនិយ័តកម្ម ។ សូមពិនិត្យមើលបណ្ណាល័យ SDS សម្រាប់ភាពពេញលេញផងដែរ ។ ពិនិត្យមើល SDS ដែលមានអំណះអំណាងដោយគ្មានការគាំទ្រសម្រាប់ការសម្ងាត់ពាណិជ្ជកម្ម ។ តើមានភស្តុតាងជាលាយលក្ខណ៍អក្សរណាមួយដែលថា អ្នកគ្រប់គ្រងបានតាមដានបញ្ហានោះជាមួយអ្នកផ្គត់ផ្គង់ ឬបានស្នើសុំ SDS ពេញលេញដែរឬទេ?

4. **ការស៊ើបអង្កេតគ្រោះថ្នាក់/ឧប្បត្តិហេតុ** ៖ តើការស៊ើបអង្កេតគ្រោះថ្នាក់ដឹកនាំដោយបុគ្គលមិនលំអៀង (ឧទា. មិនមែនជាអ្នកគ្រប់គ្រងនាយកដ្ឋានឬផ្នែកដែលគ្រោះថ្នាក់បានកើតឡើង) ឬទេ? តើ JHSC ចូលរួមយ៉ាងសកម្មក្នុងការស៊ើបអង្កេតគ្រោះថ្នាក់ដែរឬទេ? តើការស៊ើបអង្កេតគ្រោះថ្នាក់ធ្វើសារជាវិជ្ជមាន (តើយើងអាចរៀនអ្វីខ្លះ?) ឬសារអវិជ្ជមាន (តើយើងអាចបន្ទោសអ្នកណា?)? តើការស៊ើបអង្កេតគ្រោះថ្នាក់ នាំមកនូវការកែលម្អជាក់ស្ដែងដែរឬទេ? (ការកែលម្អជាក់ស្ដែងមានន័យថាអ្វីមួយបានផ្លាស់ប្ដូរ — បរិក្ខារ នីតិវិធី គោលនយោបាយ និងការបណ្ដុះបណ្ដាល ។ ប្រសិនបើការស៊ើបអង្កេតគ្រោះថ្នាក់ ជារឿយៗ កំណត់ពីនានាមូលហេតុដូចជា "ការធ្វេសប្រហែស" ឬអាក្រក់ជាងនេះ នៅតែធ្វើការស្ដីបន្ទោសនោះ នឹងមានផ្លាស់ប្ដូរតែបន្តិចបន្តួច ហើយសារចំពោះស្ថាប័ននឹងក្លាយទៅជា "កុំរាយការណ៍អំពីគ្រោះថ្នាក់ ។") ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យមើលរបាយការណ៍ស៊ើបអង្កេតគ្រោះថ្នាក់ចំនួនប្រាំមួយចុងក្រោយ ។

5. **ម៉ោងបន្ថែម** ៖ តើចំនួនម៉ោងបន្ថែមសរុបដែលបានធ្វើការច្រើនហួសហេតុដែរឬទេ? នេះអាចមានន័យថាច្រើន ៖ ស្ថាប័ននោះមានខ្វះបុគ្គលិក, ស្ថាប័ននោះកំពុងលាក់បាំងអវត្តមាន ហើយស្ថាប័ននោះកំពុងតែបង្កើតភាពតានតឹងបន្ថែមកាន់តែច្រើនសម្រាប់និយោជិតរបស់ខ្លួន ។ ចំណុចលម្អិតគួរឱ្យចាប់អារម្មណ៍មួយដើម្បីពិនិត្យមើល គឺថាតើម៉ោងបន្ថែមជាច្រើនដែលបានស្នើឡើងមិនត្រូវបានបំពេញ ។ នៅពេលដែលកម្មករនិយោជិតមិនចង់ធ្វើការបន្ថែមម៉ោង សូម្បីតែជាថ្នូរនឹងប្រាក់ឈ្នួលដ៏ខ្ពស់ក៏ដោយ ក៏ប្រហែលជានៅមានបញ្ហាដែលមិនអាចដោះស្រាយបានដដែល — រួមទាំងបញ្ហាសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការផងដែរ ។ ចូរពិចារណាលើបន្ទុកការងារ - តើកម្មករយល់ឃើញថា បន្ទុកការងារមានការកើនឡើង ឬថយចុះ? ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យមើលកំណត់ត្រាម៉ោងបន្ថែម និងដោយការស្ទង់មតិនិយោជិត ។

6. **ការគ្រប់គ្រងការផ្លាស់ប្ដូរ** ៖ ការផ្លាស់ប្ដូរទៅលើសារធាតុគីមី បច្ចេកវិទ្យា បរិក្ខារ នីតិវិធី និងអគារ/ទីកន្លែង ត្រូវតែធ្វើការវាយតម្លៃសម្រាប់ផលប៉ះពាល់លើសុខភាព និងសុវត្ថិភាព និងធ្វើការផ្លាស់ប្ដូរសមស្របទៅលើនីតិវិធី និងផ្ដល់ការបណ្ដុះបណ្ដាល ។ មូលព័ត៌មានអំពីផ្នែកនេះ ដោយពិនិត្យមើលកំណត់ហេតុកិច្ចប្រជុំរបស់ JHSC ថាតើមានការពិភាក្សាទាក់ទងនឹងសំណើធ្វើការផ្លាស់ប្ដូរទៅលើបរិក្ខារឬដំណើរការនាពេលថ្មីៗនេះដែរឬទេ ។

7. **អវត្តមាន** ៖ ប្រសិនបើការភ័យខ្លាចចំពោះវិន័យ ឬការបណ្ដេញចេញ គឺជាកត្តារារាំងការរាយការណ៍អំពីគ្រោះថ្នាក់ កម្មករអាចប្រើពេលឈឺជំនួសវិញ ដើម្បីដោះស្រាយបញ្ហារបួសបន្តិចបន្តួច ។ តើអត្រាអវត្តមាន និងការប្រើប្រាស់អត្ថប្រយោជន៍ពិការ មានកម្រិតខ្ពស់ជាង ឬទាបជាងបទដ្ឋាន? (ប្រសិនបើការរាយការណ៍អំពីគ្រោះថ្នាក់ និង/ឬការស្នើសុំសំណងរបស់កម្មករមិនត្រូវបានលើកទឹកចិត្តនោះ និយោជិតដែលរងរបួស ឬមានជំងឺ អាចនឹងត្រូវដោះស្រាយទាំងនេះតាមវិធីផ្សេងៗទៀត ។) ចូរពិនិត្យមើលកំណត់ត្រា ហើយប្រៀបធៀបជាមួយការប្រើប្រាស់សំណងរបស់កម្មករ ។

## សូចនាករសម្រាប់ប្រព័ន្ធធនធានមនុស្ស

1. **ការជ្រើសរើស និងការផ្ដល់ការងារ** ៖ តើជំនាញ និងសមត្ថភាពរបស់បុគ្គលិកមានភាពត្រូវគ្នាទៅនឹងការងាររបស់ពួកគេដូចម្ដេចដែរ? តើការពិពណ៌នាការងារមានភាពត្រឹមត្រូវ និងទាន់សម័យឬទេ មិនស្រពិចស្រពិលពេក ឬមិនលម្អិតពេកទេ? តើការប្រកាសផ្សាយជ្រើសរើសបុគ្គលិក មានភាពប្រាកដនិយម និងមានភាពពាក់ព័ន្ធទៅនឹងតម្រូវការរបស់ការងារដែលត្រូវការដែរឬទេ? ប៉ាន់ស្មានព័ត៌មាននេះ ដោយពិនិត្យមើលការប្រកាសផ្សាយជ្រើសរើសបុគ្គលិកចុងក្រោយចំនួនប្រាំមួយ និងការស្ទង់មតិបុគ្គលិកដែលបានទទួលការងារទាំងនោះ ។

2. **ផាសុកសមរម្យ** ៖ តើមានកម្មវិធីសម្រាប់ទទួលយកកម្មករដែលមានពិការភាពដែរឬទេ? តើកម្មវិធីនេះអនុវត្តចំពោះកម្មករដែលមានពិការភាពទាំងអស់ ឬចំពោះតែកម្មករដែលធ្លាក់ខ្លួនពិការនៅខណៈពេលធ្វើការ? តើមានកិច្ចសហការពេញលេញរវាងសហជីព និងអ្នកគ្រប់គ្រងដែរឬទេ? សូមកត់សម្គាល់ថា កាតព្វកិច្ចក្នុងការទទួលយកកម្មករដែលមានពិការភាព អាចនឹងត្រូវពិភាក្សារវាងសហជីព និងអ្នកគ្រប់គ្រងដាច់ដោយឡែកពី JHSC ។

3. **ការបណ្ដុះបណ្ដាល** ៖ តើការបណ្ដុះបណ្ដាលត្រូវបានវាយតម្លៃទាំងបរិមាណ និងគុណភាពដែរឬទេ? តើមានការចូលរួមពីសំណាក់និយោជិតតាមរយៈ JHSC នៅក្នុងការវិភាគតម្រូវការ ការអភិវឌ្ឍកម្មវិធី និងការផ្ដល់ការបណ្ដុះបណ្ដាល — ត្រូវបានពិនិត្យឡើងវិញជាប្រចាំដែរឬទេ? តើមានកម្មវិធីបណ្ដុះបណ្ដាលមុនពេលចូលធ្វើការត្រឹមត្រូវ ឬមានការពឹងផ្អែកភាគច្រើនលើ "លើការបណ្ដុះបណ្ដាលក្នុងពេលធ្វើការងារ" (ជារឿយៗ ការបណ្ដុះបណ្ដាលក្នុងពេលធ្វើការ គឺជាពាក្យគួរសមមួយដែលគេប្រើជំនួសឱ្យពាក្យគ្មានការបណ្ដុះបណ្ដាលអ្វីទាំងអស់) ។ តើការបណ្ដុះបណ្ដាលអំពីឯកសារទិន្នន័យសុវត្ថិភាពសម្ភារៈ ត្រូវបានធ្វើឡើង និងត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ដែរឬទេ?

4. **ការលើកកម្ពស់សុវត្ថិភាព** ៖ តើសុខភាព និងសុវត្ថិភាព ត្រូវបានលើកកម្ពស់យ៉ាងដូចម្ដេច? តើមានកម្មវិធី "រង្វាន់" សុខភាពនិងសុវត្ថិភាពដែរឬទេ? តើកម្មវិធីនេះផ្ដល់រង្វាន់ចំពោះ "សុវត្ថិភាព" ឬ "ការលាក់បាំង"? តើកម្មវិធីនេះផ្អែកលើការវង្វាស់/សូចនាករអ្វី? ប៉ាន់ស្មាន ដោយប្រៀបធៀបកម្មវិធីលើកកម្ពស់សុវត្ថិភាពដែលបានកត់ត្រាទុកជាឯកសារ ជាមួយនឹងការយល់ឃើញរបស់កម្មករអំពីកម្មវិធីនេះ តាមរយៈការស្ទង់មតិពួកគេ ។

5. **អ្នកម៉ៅការ** ៖ និយោជកត្រូវតែវាយតម្លៃការអនុវត្តសុវត្ថិភាពរបស់អ្នកម៉ៅការ ។ អ្នកម៉ៅការត្រូវតែបណ្ដុះបណ្ដាល និងផ្ដល់ព័ត៌មានដល់កម្មកររបស់ពួកគេ និងគោរពតាមបទបញ្ជាសុវត្ថិភាពរបស់រោងចក្រ ដោយរាយការណ៍អំពីបញ្ហានានាដែលកើតឡើង ។ ប៉ាន់ស្មាន ដោយពិនិត្យមើលភស្តុតាងឯកសារនៃកម្មវិធីបណ្ដុះបណ្ដាលអ្នកម៉ៅការ និងដោយការស្ទង់មតិនិយោជិតដែលមានកិច្ចសន្យានៅនឹងការដ្ឋានផ្ទាល់ ។

6. **ជំនួយសម្រាប់និយោជិត** ៖ តើមានកម្មវិធីជំនួយ ឬកម្មវិធីប្រឹក្សាបុគ្គលិកប្រកបដោយប្រសិទ្ធភាពនិងមានភាពសម្ងាត់ដែរឬទេ? តើកម្មវិធីនេះត្រូវបានគ្រប់គ្រងរួមគ្នាដោយសហជីព និងក្រុមហ៊ុនដែរឬទេ? តើកម្មវិធីនេះត្រូវបានអនុវត្តដោយអ្នកជំនាញសុខាភិបាលឯករាជ្យឬទេ? តើកម្មវិធីនេះត្រូវបានប្រើប្រាស់ដោយនិយោជិតញឹកញាប់ប៉ុណ្ណា? ប៉ាន់ស្មាន ដោយពិនិត្យមើលឯកសារកម្មវិធីជំនួយនិយោជិត ស្ថិតិនៃការប្រើប្រាស់ដែលមាន និងការយល់ឃើញរបស់និយោជិតអំពីកម្មវិធីនេះ តាមរយៈការស្ទង់មតិ ។

## សូចនាករសម្រាប់វិស្វកម្ម ការតាក់តែងការងារ វិធាននិងនីតិវិធីការងារ

1. **ការគ្រប់គ្រងផ្នែកវិស្វកម្ម ៖** តើយុទ្ធសាស្ត្រគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ត្រូវបានបង្កើតឡើងដោយផ្តល់អាទិភាពទៅលើការគ្រប់គ្រងនៅកន្លែង ឬនៅជិតប្រភព ដោយការលុបបំបាត់ការប្តូរជំនួស ការដាក់ដាច់ឆ្ងាយពីគេ ប្រព័ន្ធខ្យល់ចេញចូលប្រកបដោយប្រសិទ្ធភាព ដែរឬទេ? នៅក្នុងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ តើឧបករណ៍ការពារផ្ទាល់ខ្លួនគឺជាជម្រើសដំបូងបំផុតឬចុងក្រោយ? ប៉ាន់ស្មាន ដោយរកមើលភស្តុតាងនៃអាទិភាពទាំងនេះនៅក្នុងនាយកដ្ឋាន/ផ្នែកវិស្វកម្មជាការប្រតិបត្តិស្តង់ដារ ។ ធ្វើការស្ទង់មតិ JHSC ផងដែរដើម្បីស្វែងយល់ពីចំណាប់អារម្មណ៍របស់ពួកគេលើអាទិភាពនៃការបង្ការដែលធ្វើឡើងដោយនាយកដ្ឋានវិស្វកម្ម ។

2. **ការរចនាប្លង់កន្លែងធ្វើការ ៖** តើមានការយកចិត្តទុកដាក់កម្រិតណាដែរទៅលើការរចនាពីដំបូងនៃទីធ្លាធ្វើការងារថ្មី? តើការស្ទង់មតិ និងការសិក្សាត្រូវបានធ្វើឡើងឬនៅ? តើនិយោជិតធ្វើការកែប្រែ "ក្រៅផ្លូវការ" ញឹកញាប់ប៉ុណ្ណាទៅលើទីធ្លាធ្វើការ ដើម្បីបង្កើនផាសុកភាពរបស់ពួកគេ? ប៉ាន់ស្មាន ដោយប្រើធ្វើការពិនិត្យមើលលក្ខខណ្ឌរូបវន្ត ក៏ដូចជាការស្ទង់មតិកម្មករ ។

3. **ក) នីតិវិធីប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងបទបញ្ជាសុវត្ថិភាព ៖** តើបទបញ្ជា និងនីតិវិធីប្រតិបត្តិការផ្តោតជាក់លាក់លើបញ្ហាសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការដែរឬទេ? តើ JHSC ចូលរួមក្នុងការបង្កើតបទបញ្ជាសុវត្ថិភាពដែរឬទេ? តើបទបញ្ជាសុវត្ថិភាព ប្រើពាក្យពេចន៍ដែលងាយយល់ច្បាស់ដែរឬទេ? តើបទបញ្ជាប្រើពាក្យពេចន៍វិជ្ជមាន (“និយោជិតត្រូវ” មិនមែន “និយោជិតមិនត្រូវ”) ដែរឬទេ?

   **ខ) ការងារដែលមានគ្រោះថ្នាក់ និងនីតិវិធីសុវត្ថិភាពការងារ ៖** តើមាននីតិវិធីការងារប្រកបដោយសុវត្ថិភាពទាន់សម័យ សម្រាប់ការងារដែលមានគ្រោះថ្នាក់ដែរឬទេ? តើកិច្ចការតិចពេក ឬច្រើនពេកត្រូវចាត់ថាជា "គ្រោះថ្នាក់"? តើការវិភាគសុវត្ថិភាពការងារត្រូវបានធ្វើឡើងដែរឬទេ? តើនិយោជិតទាំងអស់យល់ពីនីតិវិធីការងារប្រកបដោយសុវត្ថិភាពដែរឬទេ? តើបទបញ្ជាសម្រាប់បុគ្គលិកទាំងអស់ មានទម្រង់ជាលាយលក្ខណ៍អក្សរដែរឬទេ? តើបទបញ្ជាត្រូវបានពិនិត្យឡើងវិញតាមពេលកំណត់ដើម្បីវាយតម្លៃប្រសិទ្ធភាព និងធ្វើការកែលម្អដែរឬទេ? តើការគោរពតាមបទបញ្ជាសុខភាព និងសុវត្ថិភាពគឺជាលក្ខខណ្ឌមួយនៃការផ្តល់ការងារសម្រាប់និយោជិតផ្ទាល់ និងសម្រាប់និយោជិតជាប់កិច្ចសន្យាដែរឬទេ? តើបទបញ្ជាត្រូវបានពន្យល់ដល់និយោជិតថ្មី នៅពេលពួកគេចាប់ផ្តើមធ្វើការ ឬនៅពេលផ្ទេរ ឬបណ្តុះបណ្តាលឡើងវិញ ដែរឬទេ?

   តើបទបញ្ជាត្រូវបានអនុវត្តដោយអ្នកគ្រប់គ្រង ថ្នាក់ដឹកនាំសហជីព និងសមាជិក JHSC ដែរឬទេ? តើនិយោជិតទាំងអស់យល់ពីបទបញ្ជាសុវត្ថិភាពដែរឬទេ? តើគ្រប់គ្នាយល់ច្បាស់តើពេលណាដែលការអនុញ្ញាតពិសេស ឬបទបញ្ជា ត្រូវអនុវត្តចំពោះ ឧទា. ការចាប់ផ្តើម ការបិទជាបន្ទាន់ ការងារក្តៅ ការចូលកន្លែងដាក់ហាមឃាត់ ការប្រើប្រាស់ឧបករណ៍ស្វ័យចលត ការបើកប្រព័ន្ធបន្តផ្ទាល់ ។ល។ ប៉ាន់ស្មាន ដោយធ្វើការស្ទង់មតិកម្មករអំពីចំណេះដឹងរបស់ពួកគេអំពីបទបញ្ជា និងនីតិវិធីទាំងនោះ និងការគោរពរបស់ពួកគេតាមបទបញ្ជានិងនីតិវិធីទាំងនេះ ។

4. **ការពិនិត្យមើលសុវត្ថិភាពមុនពេលចាប់ផ្តើមការងារ ៖** អនុវត្តចំពោះទីកន្លែងថ្មី និងដែលបានធ្វើការកែប្រែធំដុំ និងតម្រូវឱ្យមានការបញ្ជាក់ថា លក្ខណៈបច្ចេកទេសត្រូវបានបំពេញ, នីតិវិធីសម្រាប់ការចាប់ផ្តើម ប្រតិបត្តិការ ការថែទាំ និងការសង្គ្រោះបន្ទាន់ដែលត្រូវបានរៀបចំជាស្រេច ហើយការបណ្តុះបណ្តាលនឹងត្រូវបានធ្វើឡើង ។ ប៉ាន់ស្មាន ដោយពិនិត្យមើលលម្អិតលើកំណត់ត្រានៃស្ថានភាពចាប់ផ្តើមចុងក្រោយបំផុត ។

5. **ឧបករណ៍ការពារ ៖** តើការប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួននៅពេលចាំបាច់ត្រូវប្រើ មានរៀបរាប់នៅក្នុងនីតិវិធីប្រតិបត្តិការសម្រាប់ការងារនោះ និងត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់ការងារដែលពាក់ព័ន្ធដែរឬទេ? ធ្វើការស្ទង់មតិកម្មករអំពីចំណេះដឹងរបស់ពួកគេអំពីគោលនយោបាយស្តីពីឧបករណ៍ការពារផ្ទាល់ខ្លួន និងការគោរពតាមគោលយោបាយនេះផងដែរ។

6. **ផែនការគ្រោះអាសន្ន ៖** តើមានផែនការត្រៀមទប់ទល់ និងឆ្លើយតបបន្ទាន់សម្រាប់គ្រោះមហន្តរាយធំៗដែលអាចកើតឡើងដែរឬទេ? តើបានអនុវត្តដែរឬទេ? ប៉ាន់ស្មានដោយរកមើលភស្តុតាងនៃផែនការបែបនេះ និងការបណ្តុះបណ្តាល និងការអនុវត្តដែលចាំបាច់ដើម្បីគាំទ្រផែនការនេះ ។

## សូចនាករសម្រាប់ការទិញ និងតំហែទាំ

1. **ស្តង់ដារនៃការទិញ ៖** តើសុខភាព និងសុវត្ថិភាពគឺជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យសម្រាប់ការទិញសម្ភារៈ ឧបករណ៍ និងបរិក្ខារដែរឬទេ? តើមានស្តង់ដារសម្រាប់សំឡេងរំខានដែលបញ្ចេញចេញពីបរិក្ខារដែរឬទេ? តើមានស្តង់ដារសម្រាប់ការរចនាប្លង់ទីកន្លែងសម្រាប់ឧបករណ៍ដែលបានទិញ ឬស្ថានីយការងារដែរឬទេ? នៅពេលដែលមានជម្រើសជំនួស តើការពុលរបស់សារធាតុគីមី និងសម្ភារៈនៅកន្លែងធ្វើការទូទៅ (ឧទា. សារធាតុសម្រាប់សម្អាត សារធាតុរំលាយ ថ្នាំលាប ថ្នាំស្រោបពីក្រៅ) ត្រូវបានគេពិចារណាដែរឬទេ? ឬ តើ "ការតម្លៃដេញថ្លៃទាប" គឺជាលក្ខណៈវិនិច្ឆ័យតែមួយគត់ឬទេ? ប៉ាន់ស្មាន ដោយពិនិត្យមើលនាយកដ្ឋានទិញរកមើលតើមានគោលនយោបាយឬទេ ។

2. **ឧបករណ៍ និងបច្ចេកវិទ្យាថ្មី ៖** តើស្ថាប័នដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពទាក់ទងនឹងការផ្លាស់ប្តូរបច្ចេកវិទ្យាដែរឬទេ? តើតម្រូវការបណ្តុះបណ្តាលរបស់នាយកដ្ឋានថែទាំ ត្រូវបានពិចារណានៅពេលទិញបច្ចេកវិទ្យាថ្មីដែរឬទេ? ប៉ាន់ស្មាន ដោយពិនិត្យមើលនាយកដ្ឋានទិញ រកមើលភស្តុតាងនៃគោលនយោបាយ និងធ្វើការស្ទង់មតិកម្មករខាងតំហែទាំរកមើលភស្តុតាងនៃការប្រើប្រាស់របស់ពួកគេ ។

3. **ព័ត៌មានសុវត្ថិភាពនៃដំណើរការ ៖** នៅពេលទិញសម្ភារៈ ឧបករណ៍ និងបរិក្ខារថ្មី តើនិយោជកទទួលបាន និងរក្សាទុកព័ត៌មាន ដូចជា SDS ជាដើមដែររទេ? តើបុគ្គលិកខាងតំហែទាំនិងជំនាញ បានទទួលការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់ព័ត៌មាននេះដែរឬទេ? ប៉ាន់ស្មាន ដោយការពិនិត្យមើលកំណត់ត្រា និងការស្ទង់មតិកម្មករខាងតំហែទាំ ។

4. **ការវិភាគមុខសញ្ញាគ្រោះថ្នាក់នៃដំណើរការ ៖** ដោយសារតែរោងចក្រមានការផ្លាស់ប្តូរបន្តិចម្តងៗដោយសារមានការទិញ និងការដំឡើងឧបករណ៍ថ្មី និងបច្ចេកវិទ្យាថ្មី តើនិយោជករៀបចំធ្វើការវាយតម្លៃពេញលេញទៅលើមុខសញ្ញាគ្រោះថ្នាក់នៃដំណើរការផលិត ជារៀងរាល់ឆ្នាំដែរឬទេ? ប៉ាន់ស្មាន ដោយធ្វើការស្ទង់មតិបុគ្គលិកផ្នែកថែទាំដើម្បីស្វែងយល់ការយល់ដឹងរបស់ពួកគេអំពីព័ត៌មានបែបនេះ ។

5. **បូរណភាពនៃដំណើរការឧបករណ៍ ៖** តើនាវា បំពង់បង្ហូរ ប្រព័ន្ធគ្រប់គ្រង ម៉ាស៊ីនបូមទឹក និងឧបករណ៍សុវត្ថិភាព/គ្រោះអាសន្នមានចែងនៅក្នុងនីតិវិធីជាលាយលក្ខណ៍អក្សរ ដើម្បីអនុវត្តការត្រួតពិនិត្យ និងថែទាំតាមកាលកំណត់ ដើម្បីថែរក្សាបូរណភាពដំណើរការរបស់ឧបករណ៍ទាំងនេះដែរឬទេ? តើដំណើរការផលិតកម្មត្រូវបានរំខានជាញឹកញាប់ដោយសារឧបករណ៍/គ្រឿងម៉ាស៊ីនខូចមិនដំណើរការឬទេ (សូចនាករនៃស្តង់ដារតំហែទាំមិនល្អ)? ប៉ាន់ស្មានចំណុចនេះដោយពិនិត្យមើលទិន្នន័យនៃភាពជឿទុកចិត្តបានរបស់រោងចក្រ ។

6. **ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE)** ៖ តើឧបករណ៍ការពារផ្ទាល់ខ្លួនមានដាក់បញ្ចូលនៅក្នុង នីតិវិធីថែទាំជ្រើសរើសនិងការប្រើប្រាស់ដោយសមស្របដែរឬទេ? តើនិយោជកមានកម្មវិធី PPE ឬស្តង់ដារដែលផ្តោតលើឧបករណ៍ការពារខ្លួនដែរឬទេ? តើមានការគោរតាមគោលនយោបាយ PPE យ៉ាងណាដែរ? ប៉ាន់ស្មានចំណុចនេះ ដោយការពិនិត្យមើលគោលនយោបាយ PPE និងស្ទង់មតិនិយោជិតអំពីការយល់ដឹង និងការគោរពតាមគោលនយោបាយ PPE ។

## សូចនាករសម្រាប់កប្រព័ន្ធសុវត្ថិភាពនិងអនាម័យការងារ

1. **ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់សុវត្ថិភាព** ៖ តើ JHSC ធ្វើការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ដែរឬទេ? តើមុខសញ្ញាគ្រោះថ្នាក់សុវត្ថិភាពចំនួនប៉ុន្មានត្រូវបានកំណត់នៅក្នុងការត្រួតពិនិត្យជាប្រចាំ ហើយតើមុខសញ្ញាគ្រោះថ្នាក់ទាំងនេះត្រូវបានកែតម្រូវរហ័សយ៉ាងណាដែរ? តើ JHSC ធ្វើការត្រួតពិនិត្យជាប្រចាំដែរឬទេ? តើកំណត់ត្រានៃការត្រួតពិនិត្យលើកមុន ត្រូវបានពិនិត្យមើលជាទៀងទាត់ដែរឬទេ? តើមានការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងសម្ភារៈ ការចល័តទីតាំងឧបករណ៍បរិក្ខារ ការដំឡើងគ្រឿងអគ្គិសនី ទីតាំងជ្រើសរើសសំណាកគំរូ មុខសញ្ញាគ្រោះថ្នាក់គីមី និងជីវសាស្ត្រ កន្លែងឬឧបករណ៍ដែលក្តៅខ្លាំងនិងត្រជាក់ខ្លាំង ធូលី ចំហាយទឹក និងផ្សែង ការបញ្ចេញវិទ្យុសកម្ម សំលេងរំខាន លទ្ធភាពនៃការរអិល ការធ្លាក់ ជណ្តើរ ទុយោទឹក យានយន្ត មុខសញ្ញាគ្រោះថ្នាក់អគ្គិភ័យ និងប្រព័ន្ធការពារអគ្គិភ័យ? ប៉ាន់ស្មានចំណុចទាំងនេះ ដោយពិនិត្យមើលរបាយការណ៍ត្រួតពិនិត្យកន្លែងធ្វើការចំនួនប្រាំមួយចុងក្រោយ ហើយផ្ទៀងផ្ទាត់ថា ចំណុចសកម្មភាពទាំងអស់ត្រូវបានបំពេញ ។

2. **អនាម័យការងារ** ៖ តើ JHSC ចូលរួមក្នុងកម្មវិធីត្រួតពិនិត្យអនាម័យការងារដែរឬទេ? តើកម្រិតបំពុលឧស្សាហកម្មមានលក្ខណៈស្របតាមគោលការណ៍ច្បាប់ដែរឬទេ? តើកម្រិតជាតិពុលក្នុងឧស្សាហកម្ម មានភាពប្រសើរឡើងជាងមុន ឬកាន់តែអាក្រក់ទៅ? តើមានការត្អូញត្អែររបស់កម្មករអំពីគុណភាពខ្យល់ដែរឬទេ? ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យមើលកំណត់ត្រាដែលមានពីនាយកដ្ឋានអនាម័យការងារ និងដោយការស្ទង់មតិសមាជិក JHSC ។

3. **ជំងឺការងារ** ៖ តើមានជំងឺមហារីកប៉ុន្មានករណី ជាពិសេសចំពោះកម្មករដែលធ្វើការរយៈពេលវែង ឬចំពោះអ្នកចូលនិវត្តន៍? តើចំនួនករណីមហារីកដែលបានសង្កេត ខុសគ្នាពីចំនួនរំពឹងទុកយ៉ាងណាដែរ? ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យមើលកំណត់ហេតុកិច្ចប្រជុំរបស់ JHSC រកមើលភស្តុតាងនៃការយកចិត្តទុកដាក់អំពីបញ្ហានេះ ។

4. **ភាពតានតឹងក្នុងអារម្មណ៍** ៖ តើមានការត្អូញត្អែរអំពីភាពតានតឹងក្នុងអារម្មណ៍ ឬជំងឺប៉ុន្មានករណីដែលកម្មករជួបប្រទះ? តើមានបណ្តឹងសាទុក្ខចំនួនប៉ុន្មានករណីក្នុងមួយឆ្នាំ? តើអត្រានេះកើនឡើង ឬថយចុះ? តើការចាកចេញពីការងាររបស់បុគ្គលិក ការលាលែង ឬការចូលនិវត្តន៍មុនអាយុ មានអត្រាខ្ពស់ដែរឬទេ? តើមានសន្តិសុខការងារច្រើនឬតិច? តើមានករណីការបំផ្លាញទ្រព្យសម្បត្តិ និងចោរកម្មច្រើនដែរឬទេ? តើមានការត្អូញត្អែរពីអតិថិជនច្រើនអំពីផលិតផលដែរឬទេ? តើមានឧប្បត្តិហេតុនៃជម្លោះធ្ងន់ធ្ងរ ឬអំពើហិង្សាដែរឬទេ? តើមានការធ្វើអត្តឃាត ឬការប៉ុនប៉ងធ្វើអត្តឃាតក្នុងចំណោមក្រុមនិយោជិតដែរឬទេ? តើមានកម្មវិធីជំនួយបុគ្គលិក (EAP) ឬទេ? តើកម្មវិធីត្រូវបានប្រើប្រាស់ច្រើនប៉ុណ្ណាដែរ? តើមានកម្មវិធីធ្វើតេស្តគ្រឿងញៀន (សូចនាករអវិជ្ជមាន - បង្កើតភាពតានតឹងបន្ថែម និងមិនបានដោះស្រាយបញ្ហាបំពានគ្រឿងញៀន) ដែរឬទេ? តើនិយោជកចាត់វិធានការបង្ការក្នុងការព្យាយាមទប់ស្កាត់ការបៀតបៀន ការបំភិតបំភ័យ និងការរំលោភបំពានដែរឬទេ? តើកន្លែងធ្វើការនេះតម្រូវឱ្យមានការប្តូរវេនការងារដែរឬទេ? តើកម្មករបានទទួលការបណ្តុះបណ្តាលពីរបៀបសម្របខ្លួនទៅនឹងការងារប្តូរវេនដែរឬទេ? ប៉ាន់ស្មាន ដោយរកមើលភស្តុតាងនៃករណីទាំងឡាយខាងលើ ដោយពិនិត្យមើលកំណត់ត្រាស្ថិតិនៃការប្រើប្រាស់កម្មវិធីជំនួយនិយោជិត បណ្តឹងអំពីការបៀតបៀន កម្មវិធីបណ្តុះបណ្តាល និងសេវាកម្មសម្រាប់កម្មករដែលធ្វើការប្តូរវេន ។

5. **ការសម្អាតអនាម័យ** ៖ តើលក្ខខណ្ឌរូបវន្ត និងបរិយាកាសការងារ មានភាពស្អាត មានភ្លើងបំភ្លឺល្អ គ្មានភាពរញ៉េរញ៉ៃ និងអំណោយផលដល់សុវត្ថិភាព ដែរឬទេ? ប៉ាន់ស្មានផ្នែកនេះ ដោយការពិនិត្យមើលលក្ខខណ្ឌរូបវន្តរបស់ផ្នែកណាមួយនៃកន្លែងធ្វើការ ។

6. **ការបដិសេធការងារ** ៖ តើមានការបដិសេធការងារដែលទាក់ទងនឹងសុវត្ថិភាពច្រើនករណីដែរឬទេ? តើ JHSC មានតួនាទីអ្វីខ្លះក្នុងការស៊ើបអង្កេតការបដិសេធការងារ? តើបញ្ហានេះត្រូវបានដោះស្រាយបានល្អប៉ុណ្ណា? តើបញ្ហានេះត្រូវបានដោះស្រាយដោយរបៀបណា? ប្រសិនបើមានការបដិសេធការងារតិចតួច តើការភ័យខ្លាចគឺជាកត្តាចម្បងដែរឬទេ? ប៉ាន់ស្មានបញ្ហានេះ ដោយពិនិត្យមើលកំណត់ត្រារបស់ JHSC នៃការស៊ើបអង្កេតការបដិសេធការងារ ។

# ស្តង់ដារសម្រាប់សវនកម្មសុវត្ថិភាព

នៅក្នុងផ្នែកមុន សូចនាករជាច្រើនត្រូវបានស្នើឡើង ។ ការយោបល់ខ្លះក៏ត្រូវបានធ្វើឡើងផងដែរអំពីរបៀបប៉ាន់ស្មាន ឬវាយតម្លៃសូចនាករនីមួយៗ។

សម្រាប់សូចនាករខ្លះ គេអាចពិនិត្យមើលកំណត់ត្រាជាលាយលក្ខណ៍ ។ ដូច្នេះ នៅក្នុងករណីនៃសូចនាករសម្រាប់ប្រសិទ្ធភាពរបស់គណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម កន្លែងច្បាស់លាស់មួយដែលត្រូវរកមើលគឺនៅក្នុងកំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការនេះ ។ កំណត់ត្រាផ្សេងទៀតដែលអាចពិនិត្យមើល រួមមាន លិខិតអនុញ្ញាតការងារ កំណត់ត្រាឬរបាយការណ៍តំហែទាំ លទ្ធផលមន្ទីរពិសោធន៍ ។ល។

សម្រាប់សូចនាករផ្សេងទៀត គេអាចប្រើប្រាស់បច្ចេកទេសស្ទង់មតិ ។ សួរយោបល់របស់កម្មករ ហើយធ្វើតារាងលទ្ធផល ។

ការសង្កេតដោយផ្ទាល់ទៅលើលក្ខខណ្ឌគឺជាវិធីជាក់ស្តែងមួយទៀតនៃការវាយតម្លៃសូចនាករ ។

នៅពេលអ្នកបានកំណត់វិធីវាស់វែង ឬបច្ចេកទេសសង្កេតជាក់ស្តែងរួចហើយ ជំហានបន្ទាប់គឺត្រូវពិចារណាអំពីប្រភេទព័ត៌មានដែលត្រូវប្រមូលយក ។

នៅក្នុងការកំណត់ស្តង់ដារសម្រាប់សូចនាករនីមួយៗ អ្នកត្រូវកំណត់ពីអ្វីដែលជាការសង្កេតដែលអាចទទួលយកបានសម្រាប់សូចនាករនីមួយៗ ។

ប្រសិនបើគេអាចបង្កើតព័ត៌មានបែបបរិមាណ សូមចាប់ផ្តើមជាមួយមាត្រដ្ឋានដើម្បីធ្វើការចាត់ថ្នាក់លទ្ធផល ។ នៅលើមាត្រដ្ឋាននោះ តើកម្រិតនៃការអនុវត្តដែលអាចទទួលយកបានស្ថិតនៅត្រង់ណា?

ក្នុងករណីមួយចំនួន អាចមានច្បាប់ បច្ចេកទេស ឬស្តង់ដារដែលគេទទួលយកជាទូទៅផ្សេងទៀត ។ ជារឿយៗ សវនកម្មសុវត្ថិភាពជាកញ្ចប់ដាក់ចេញនូវសូចនាករ បច្ចេកទេសនៃការវាស់វែង និងស្តង់ដារដែលត្រូវប្រើ ។

ឥឡូវនេះ អ្នកត្រៀមខ្លួនរួចរាល់ដើម្បីប្រៀបធៀបលទ្ធផលរបស់អ្នកជាមួយស្តង់ដារដែលអ្នកបានជ្រើសរើស ។ នៅពេលពេលវេលាវិវឌ្ឍទៅមុខទៀត ហើយអ្នកមានបទពិសោធន៍ជាមួយប្រព័ន្ធសវនកម្មរបស់អ្នក អ្នកអាចនឹងចង់ពិនិត្យឡើងវិញលើស្តង់ដាររបស់អ្នក ដើម្បីចង់ដឹងថាតើអាចធ្វើឱ្យវាកាន់តែជាក់លាក់បំផុតតាមដែលអាចធ្វើទៅបានឬទេ ។

# គោលនយោបាយ និងនីតិវិធីសម្រាប់កែតម្រូវកំហុស

នៅពេលរៀបចំគោលនយោបាយ និងនីតិវិធីដើម្បីកែតម្រូវកំហុស ជាការសំខាន់ដែលត្រូវគិតពីការកែតម្រូវរយៈពេលខ្លី និងរយៈពេលវែង ។

ការកែតម្រូវរយៈពេលខ្លី សួរសំណួរ ៖ តើត្រូវធ្វើអ្វីខ្លះដើម្បីបង្ការកុំឲ្យមានគ្រោះថ្នាក់កើតឡើងក្នុងថ្ងៃនេះ?

ការកែតម្រូវរយៈពេលវែង សួរសំណួរ ៖ តើត្រូវធ្វើអ្វីខ្លះដើម្បីបង្ការគ្រោះថ្នាក់មិនឱ្យកើតឡើងសោះ?

ដូចដែលអាចមើលឃើញស្រាប់ ជារឿយៗ ចម្លើយចំពោះសំណួរទាំងពីរនេះ គឺខុសគ្នា ។

សកម្មភាពរបស់មនុស្សម្នាក់ សុទ្ធតែមានការពាក់ព័ន្ធនឹងការបង្កគ្រោះថ្នាក់ ប៉ុន្តែការរចនាទីកន្លែងធ្វើការមិនមែនជាគ្រោះថ្នាក់នោះទេ! នរណាម្នាក់ជាអ្នកធ្វើការសម្រេចចិត្តដោយដឹងជាមុនដើម្បីធ្វើកិច្ចការនេះតាមវិធីជាក់លាក់មួយ ។ ដើម្បីដោះស្រាយបញ្ហានៅទីកន្លែងធ្វើការទីមួយ យើងត្រូវតែពិនិត្យមើលបញ្ហាទាំងនោះដោយប្រុងប្រយ័ត្ន ។ យើងអាចនឹងចង់ប្រើប្រាស់ចំណេះដឹងរបស់អ្នកជំនាញខាងអនាម័យវិស្វករ គ្រូពេទ្យ អ្នកវិទ្យាសាស្ត្រ អ្នកជំនាញខាងជាតិពុល ឬបុគ្គលផ្សេងទៀត ប៉ុន្តែចុងក្រោយ អ្នកជំនាញនៅកន្លែងធ្វើការគឺជាមនុស្សដែលនៅកន្លែងធ្វើការនោះតែម្តង ៖ អ្នក ។

ចូរពិចារណាការពន្យល់បែបប្រពៃណីមួយចំនួននៃគ្រោះថ្នាក់ និងជំងឺដែលទាក់ទងនឹងការងារ ៖

1. **"កម្មករខ្លះ "ងាយនឹងគ្រោះថ្នាក់" ។ សំណាងអាក្រក់របស់ពួកគេនាំឲ្យមានគ្រោះថ្នាក់ដល់ពួកគេ» ។ ទោះបីជាមានការស្រាវជ្រាវទៅលើស្ថិតិនៃគ្រោះថ្នាក់ក៏ដោយ ក៏ពុំមានភស្តុតាងណាមួយត្រូវបានរកឃើញដើម្បីបញ្ជាក់ថា "មានភាពងាយទទួលរងគ្រោះថ្នាក់" ឡើយ ។**

2. **«កម្មករច្រើនតែ «ធ្វេសប្រហែស» ។ ការធ្វេសប្រហែសរបស់កម្មករ គឺជាមូលហេតុនៃគ្រោះថ្នាក់ភាគច្រើនបំផុត» ។ សញ្ញាណដែលថា កម្មករមិនខ្វល់ថាពួកគេបង្ករបួសដល់ខ្លួនឯងឬអត់ មានការសន្មតយ៉ាងច្រើន ហើយជារឿយៗ មានផលប៉ះពាល់ដោយធ្វើការស្តីបន្ទោសជនរងគ្រោះ ។ ថ្មីៗនេះ និយោជកខ្លះបានធ្លាក់ចូលទៅក្នុង "វិធីសាស្ត្រផ្អែកលើឥរិយាបថ" ចំពោះសុវត្ថិភាព ដែលផ្តោតលើការគ្រប់គ្រងឥរិយាបថប្រថុយគ្រោះថ្នាក់របស់កម្មករម្នាក់ៗ ។ ប៉ុន្តែ ជារឿយៗ និយោជកដដែលនេះ លើកទឹកចិត្តដល់ការទទួលយកហានិភ័យដោយមិនដឹងខ្លួន ។ មនុស្សច្រើនតែទទួលយកហានិភ័យកាន់តែច្រើននៅពេលដែលពួកគេត្រូវបានគេបានផ្តល់រង្វាន់សម្រាប់ការទទួលហានិភ័យទាំងនេះ នៅពេលដែលពួកគេទទួលបានសារចម្រុះអំពីសារៈសំខាន់នៃសុវត្ថិភាព ធៀបនឹងការផលិត ហើយនៅពេលដែលការប្រថុយគ្រោះថ្នាក់ ហាក់ដូចជាសមហេតុផលអំពីអ្វីដែលជាទិដ្ឋភាពដែលមិនអាចយល់បាននៃបរិយាកាសនៅកន្លែងធ្វើការ ("... យ៉ាងហោចណាស់ ហានិភ័យដែលខ្ញុំទទួលគឺជាអ្វីដែលខ្ញុំគ្រប់គ្រង"), និយាយម្យ៉ាងវិញទៀត ជាកន្លែងដែលខ្វះ "វប្បធម៌សុវត្ថិភាព" ។**

3. **"កម្មករខ្លះងាយនឹងរងរបួស ឬជំងឺជាងអ្នកផ្សេងទៀត" ។ ទ្រឹស្តីនេះនាំឱ្យមានការពិនិត្យសុខភាពមុនពេលចូលធ្វើការ ដើម្បីធានាថា មានតែបេក្ខជនដែលមានសុខភាពល្អ និងកាយសម្បទាមាំមួនបំផុតប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសឱ្យចូលធ្វើការ ។ ទោះបីជាមានការខិតខំប្រឹងប្រែងទាំងនេះក្តី ការស្រាវជ្រាវបានបង្ហាញថា ការពិនិត្យសុខភាពមុនពេលចូលធ្វើការ គឺកម្រនឹងអាចព្យាករណ៍ដឹងពីជំងឺនាពេលអនាគតណាស់ ។ ចំពោះរបួស កម្មករដែលបានទទួលសំណាងនៅពេលខ្លះ ហើយកម្មករដែលធ្លាប់មានសុខភាពល្អពីមុន ក៏មានស្ថិតិស្រដៀងគ្នាសម្រាប់របួស ជំងឺ និងអវត្តមានផងដែរ ។**

4. **"ជំងឺភាគច្រើនបំផុតបណ្តាលមកពីការជ្រើសរើសរបៀបរស់នៅ" ។ យើងទាំងអស់គ្នាមានសិទ្ធិក្នុងការជ្រើសរើសរបៀបរស់នៅ, អ្នកខ្លះធ្វើការជ្រើសរើសប្រកបដោយភាពឆ្លាតវៃ ខ្លះទៀតមិនសូវឆ្លាតវៃ ។ តើអំណាចរបស់និយោជកមានឥទ្ធិពលទៅលើជីវិតឯកជនរបស់យើងដល់កម្រិតណា? ចូរពិចារណាជំងឺមហារីកមួយភ្លែត ។ ការជក់បារី និងរបបអាហារ ត្រូវបានចាត់ទុកថាជាមូលហេតុចម្បងពីរនៃជំងឺមហារីក ។ ជារឿយៗ គេច្រើនតែភ្លេចថា មុខរបរយ៉ាងហោចណាស់ក៏ជាបុព្វហេតុឈានមុខទីបីដែរ ។ វាតំណាងឱ្យករណីស្លាប់ដ៏ច្រើនដោយសារជំងឺមហារីក ដែលជនរងគ្រោះគ្មានជម្រើសអាចជៀសវាងបាន ។**

5. **"សកម្មភាពទាំងអស់ រួមទាំងការងារ រួមមានធាតុផ្សំនៃហានិភ័យមួយ ។ នៅពេលកម្មករមកធ្វើការនៅទីនេះ ពួកគេស្ម័គ្រចិត្តទទួលយកហានិភ័យដែលមានមកជាមួយការងារនោះ» ។ អំណះអំណាងនេះ សន្មតថា ៖ — ទីផ្សារការងារគឺបើកចំហទាំងស្រុងជាមួយនឹងអត្រាគ្មានការងារធ្វើសូន្យ - ប្រាក់ឈ្នួលសម្រាប់ការងារផ្សេងៗគ្នា គឺផ្អែកទៅលើហានិភ័យតែប៉ុណ្ណោះ ហើយ — មនុស្សធ្វើការសម្រេចចិត្តអំពីអាជីពរបស់ខ្លួនដោយហេតុផលតែមួយគត់ ពោលគឺ ប្រៀបធៀបហានិភ័យទៅនឹងប្រាក់ឈ្នួល ។ ទាំងនេះគឺជាការសន្មតមិនពិត ។ មនុស្សធ្វើការដើម្បីរស់ មិនមែនដើម្បីស្លាប់ទេ ។**

## កម្មករមិនត្រូវទទួលការស្តីបន្ទោសឡើយ

នៅក្នុង "ទ្រឹស្តី" ទាំងអស់នៃបុព្វហេតុគ្រោះថ្នាក់នេះ ចំណុចផ្តោតសំខាន់គឺទៅលើកម្មករម្នាក់ៗ ។ ដូច្នេះ ការបង្ការរួមមានការការពារកម្មករដោយខ្លួនឯង ។

តាមពិត ការងារមិនមែនជាសកម្មភាពបុគ្គលនោះទេ ប៉ុន្តែជាសកម្មភាពសង្គម និងស្ថាប័ន ។ សមត្ថភាពរបស់កម្មករនិយោជិតម្នាក់ៗក្នុងការសម្រេចចិត្តអំពីរបៀបធ្វើការនៅខណៈពេលណាមួយ ត្រូវបានរាំរាំងដោយការត្រួតពិនិត្យ ឧបករណ៍ និងបរិក្ខារដែលបានផ្តល់ ការជ្រើសរើសត្រូវបានធ្វើរួចហើយអំពីដំណើរការនៃការផលិត និងការរចនាទីកន្លែងធ្វើការ សកម្មភាពរបស់មិត្តរួមការងារ និងអ្នកត្រួតពិនិត្យ សេចក្តីណែនាំ និងនិតិវិធីប្រតិបត្តិការ ។ល។ ដូច្នេះហើយ ដំណោះស្រាយត្រូវតែផ្តោតលើស្ថាប័ន មិនមែនលើបុគ្គលនោះទេ ។

ឧទាហរណ៍ កំហុសរបស់អ្នកប្រើម៉ាស៊ីន "ដោយបង្ខំ" ជារឿយៗ កើតឡើងជាដោយសារតែតម្រូវការផលិតកម្មដែលកំណត់ដោយម្ចាស់សហគ្រាស ។ម្យ៉ាងវិញទៀត ការរចនាទីកន្លែងធ្វើការគឺជាលទ្ធផលនៃការសម្រេចចិត្តដែលធ្វើឡើងដោយអ្នកគ្រប់គ្រង ។ ប្រសិនបើប្រព័ន្ធមួយតម្រូវឱ្យមានការប្រុងប្រយ័ត្ន ១០០%, ១០០% នៃពេលវេលាដែលត្រូវជៀសវាងគ្រោះមហន្តរាយ, មានន័យថាគ្រោះមហន្តរាយត្រូវបានធានា ហើយការស្ដីបន្ទោសកម្មករគឺមិនសមហេតុផលនោះទេ នៅពេលវាកើតឡើងនៅទីបំផុត ។

ការរចនាទីកន្លែងធ្វើការ និងដំណើរការ មិនកើតឡើងដោយចៃដន្យនោះទេ ។ នរណាម្នាក់ជាអ្នកសម្រេចចិត្តរចនា និងប្រតិបត្តិការរោងចក្រតាមរបៀបជាក់លាក់មួយ ។ អ្នកគ្រប់គ្រងមានសិទ្ធិអំណាចចុងក្រោយដើម្បីធ្វើការជ្រើសរើសអំពីសារធាតុគីមី បច្ចេកវិទ្យា ឧបករណ៍ ប្រព័ន្ធប្រកាសអាសន្ន ភាពញឹកញាប់នៃការថែទាំ និងនីតិវិធី និងថែមទាំងការបណ្ដុះបណ្ដាល — ហើយពួកគេរក្សាទំនួលខុសត្រូវដែលមានមកជាមួយអំណាចនោះ ។ ជម្រើសទាំងនេះ អាចល្អ ឬអាចអាក្រក់ ។ ប្រសិនបើល្អមានប្រព័ន្ធនៅនឹងកន្លែងដើម្បីបង្ការគ្រោះថ្នាក់ របួស និងជំងឺ ។ ដូច្នេះប្រព័ន្ធគួរតែបុរេសកម្មក្នុងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ។

ប្រសិនបើកំហុស ឬឥរិយាបថរបស់មនុស្ស ត្រូវបានយកមកពិចារណានោះ កត្តាមនុស្សខ្លះដែលគេច្រើនតែមើលរំលង អាចរួមមាន ភាពអស់កម្លាំង ភាពតានតឹងក្នុងការរចនាអារម្មណ៍ ការងារប្ដូរវេន និងការរៀបចំប្លង់កន្លែងធ្វើការទាក់ទងនឹងការរចនាស្ថានីយការងារ ឧបករណ៍ និងបរិក្ខារ ។ សូម្បីតែអ្វីមួយដែលសាមញ្ញ ដូចជានាឡិការវាស់ ឬដៃទ្វារ ក៏មនុស្សដែលជាអ្នកប្រើប្រាស់ត្រូវតែយល់ថាមានប្រយោជន៍ ហើយភាគច្រើនវាគឺជាមុខងារមួយដែលបង្ហាញថា តើប្រព័ន្ធបញ្ជា ឬឧបករណ៍ ត្រូវបានរចនាបានល្អដូចម្ដេច ។

ជាទូទៅ វិធានការកែតម្រូវគួរតែត្រូវបានជ្រើសរើសចេញពីជម្រើសជំនួសជាច្រើនដែលមាន យោងតាមលំដាប់នៃចំណង់ចំណូលចិត្តដូចខាងក្រោម ៖

1. **គ្រប់គ្រងនៅត្រង់ឬជិតប្រភព (ប្រសិនបើមុខសញ្ញាគ្រោះថ្នាក់អាចត្រូវបានលុបចោល ឬដាក់ឱ្យដាច់ដោយឡែកទាំងស្រុងតាមរយៈការប្ដូរជំនួស ឬការគ្រប់គ្រងផ្នែកវិស្វកម្មប្រកបដោយប្រសិទ្ធភាព) ។**
2. **គ្រប់គ្រងនៅតាមបណ្ដោយផ្លូវនៃការប៉ះពាល់ ។**
3. **គ្រប់គ្រងទៅលើកម្មករផ្ទាល់ ។**

## ទស្សនៈពីរបីចំណុចអំពីកម្មវិធីផ្អែកលើឥរិយាបថ

ទ្រឹស្ដីមួយដែលត្រូវបានផ្សព្វផ្សាយដោយទីប្រឹក្សាពិគ្រោះយោបល់ឥរិយាបថខ្លះ គឺថា មុខសញ្ញាគ្រោះថ្នាក់ទាំងអស់គឺសុទ្ធតែទាក់ទងនឹងឥរិយាបថ ។ ឧទាហរណ៍ សូម្បីតែឧបករណ៍ដែលខូច ឬសារធាតុគីមីគ្រោះថ្នាក់ក៏ដោយ ក៏ពាក់ព័ន្ធនឹងជម្រើសដែលធ្វើឡើងដោយវិស្វករ និងអ្នកទិញដែរ ។ ដូច្នេះ យោងទៅតាមអ្នកជំនាញខាងឥរិយាបថ ឥរិយាបថរបស់មនុស្សគឺជាគន្លឹះក្នុងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តសុខភាព និងសុវត្ថិភាព ។

ជាទូទៅ កម្មវិធីសុវត្ថិភាពឥរិយាបថ រួមមាន ៖

1. **ការសង្កេតមើលភារកិច្ច/កិច្ចការ**
2. **ការវិភាគការងារដើម្បីកំណត់បញ្ហាសុវត្ថិភាពដែលអាចកើតមានជាមួយភារកិច្ច/កិច្ចការដែលត្រូវបំពេញ**
3. **ការអនុវត្តវិធានការផ្អែកលើការសង្កេតមើលការងារ និងការវិភាគការងារ ដើម្បីបង្កើនការអនុវត្តវិធានការសុវត្ថិភាព និង**
4. **ការសង្កេតឡើងវិញ និងការវិភាគឡើងវិញតាមកាលកំណត់**

IndustriALL មិនណែនាំឱ្យប្រកាន់យកកម្មវិធីឥរិយាបថនោះទេ ដោយសារតែ ៖

- **ទំនោររបស់ពួកគេក្នុងការមិនអើពើ ឬកាត់បន្ថយសារៈសំខាន់នៃមុខសញ្ញាគ្រោះថ្នាក់ក្រៅពីឥរិយាបថ (ឧទា. មុខសញ្ញាគ្រោះថ្នាក់រូបវន្ត វិធានការអនាម័យការងារ ការរៀបចំប្លង់កន្លែងធ្វើការ និងសារធាតុគីមីពុល) ។**
- **ទំនោររបស់ពួកគេក្នុងការមិនអើពើចំពោះឥរិយាបថរបស់អ្នកគ្រប់គ្រង និងបុគ្គលិកវិស្វកម្ម ជាពិសេសអ្នកដែលពាក់ព័ន្ធនៅក្នុងការរចនាប្លង់រោងចក្រ ដែលប្រហែលជាឈប់ធ្វើការនៅកន្លែងនោះទៀតហើយ ។**
- **ទំនោររបស់ពួកគេក្លាយជាការស្វែងរកកំហុស និងការដាក់ទណ្ឌកម្ម ។**

គេពិបាកនឹងធានាថា កម្មវិធីឥរិយាបថនឹងត្រូវបានអនុវត្តដោយមានការប្ដេជ្ញាចិត្តដើម្បីរក្សាភាពសម្ងាត់យ៉ាងតឹងរឹង និងជៀសវាងការស្ដីបន្ទោសដែលកើតចេញពីការសង្កេតឃើញ ដូច្នេះជាការចាំបាច់ដែលត្រូវបង្កើត និងថែរក្សាការជឿទុកចិត្ត ។ ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះជឿថាកម្មវិធីឥរិយាបថអាចទទួលបានជោគជ័យក្នុងការប្រើប្រាស់ចំណេះដឹងរបស់កម្មករដើម្បីកំណត់ "ដំណោះស្រាយរបស់កម្មករ" ចំពោះមុខសញ្ញាគ្រោះថ្នាក់សុវត្ថិភាព ទន្ទឹមគ្នានោះ រក្សាបាននូវការចូលរួមយ៉ាងខ្លាំងពីនិយោជិត និងមតិត្រឡប់ជាវិជ្ជមានចំពោះការគ្រប់គ្រងគ្រោះថ្នាក់ ។

ការរិះគន់របស់យើងចំពោះកម្មវិធីផ្អែកលើឥរិយាបថ គឺថា “ឥរិយាបថរបស់មនុស្ស” ត្រូវបានគេបកស្រាយជាញឹកញាប់បំផុតថាជា "ឥរិយាបថរបស់កម្មករ" ។ ការសម្រេចចិត្ត និងសកម្មភាពរបស់អ្នកត្រួតពិនិត្យការងារ និងអ្នកគ្រប់គ្រង កម្រត្រូវបានគេពិនិត្យពិច័យណាស់ ។ អ្វីដែលកាន់តែពិបាកសង្កេតជាងនេះទៅទៀតនោះ គឺឥរិយាបថចម្បងដែលនាំទៅរកគ្រោះថ្នាក់ទាក់ទងនឹងការរៀបចំប្លង់កន្លែងធ្វើការ ឬសារធាតុគីមី ដែលអាចជាតួនាទីរបស់វិស្វករ គ្រូពេទ្យ ឬអ្នកជំនាញខាងជាតិពុល នៅក្នុងអំឡុងពេលរោងចក្រនេះត្រូវបានរចនាឡើង ។ អ្នកសង្កេត/សវនករនៅកន្លែងធ្វើការ មិនអាចជួបមនុស្សទាំងនេះបានទេ ជាពិសេសប្រសិនបើវាជាផ្នែកតែមួយគត់ដែលអាចមើលឃើញនៃកម្មវិធីផ្អែកលើឥរិយាបថ ។

អ្វីដែលគួរឱ្យស្ដាយគឺថា អ្នកគ្រប់គ្រងខ្លះបានបង្ហាញពីការប្ដេជ្ញាចិត្តក្នុងការអនុវត្តកម្មវិធីផ្អែកលើឥរិយាបថ ទោះបីជាមានការព្រួយបារម្ភទាំងនេះក៏ដោយ ។

បើដូច្នេះមែន ចូរជៀសវាងការស្ដីបន្ទោស និងវិធានការដាក់ទណ្ឌកម្មទោះក្នុងកាលៈទេសៈណាក៏ដោយ ។ ប្រើប្រាស់ការសង្កេតដោយអាកប្បកិរិយា "តើយើងអាចរៀនសូត្រអ្វីខ្លះ" ។ ត្រូវធានាថា ការចូលរួមរបស់អ្នកសង្កេតការណ៍ និងការសង្កេត គឺជាការស្ម័គ្រចិត្ត ។

ប្រសិនបើកម្មវិធីបង្ហាញពីសញ្ញានៃការដាក់ទណ្ឌកម្ម ឬបង្វែរការយកចិត្តទុកដាក់ចេញពីការយកចិត្តទុកដាក់អំពីបញ្ហាសុខភាព និងសុវត្ថិភាពដែលមានសារៈសំខាន់ចំពោះកម្មករ នោះការគាំទ្ររបស់កម្មករ និងកិច្ចសហប្រតិបត្តិការជាមួយកម្មវិធីត្រូវតែដកចេញ ។

### ការសន្និដ្ឋាន

សម្រាប់ IndustriALL Global Union, សុខភាព និងសុវត្ថិភាព មិនមែនគ្រាន់តែជាមុខងាររដ្ឋបាល ឬសេវាកម្មនោះទេ ។ វាលើសពីការដែលគ្រាន់តែគោរពតាមលិខិតបទដ្ឋានច្បាប់ ។ វាគឺជាអ្វីដែលជាមូលដ្ឋានគ្រឹះដែលយើងជឿលើ និងទាមទារឱ្យមាន ។ ចំណុចស្នូលនៃសុខភាព និងសុវត្ថិភាពការងារ គឺគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួម ។ សវនកម្មសុវត្ថិភាពគឺជាឧបករណ៍មួយដែលអាចត្រូវបានប្រើដោយគណៈកម្មាធិការសុខភាព និងសុវត្ថិភាពរួមគ្នា ដើម្បីវាយតម្លៃ និងកែលម្អប្រព័ន្ធសុវត្ថិភាពនៅកន្លែងធ្វើការ ។

# និយមន័យខ្លះ

**កំណត់សម្គាល់ ៖** និយមន័យទាំងឡាយខាងក្រោមនេះ អាចមិនដូចគ្នានឹងនិយមន័យនៅក្នុងវចនានុក្រមទេ ប៉ុន្តែឆ្លុះបញ្ចាំងពីរបៀបដែលពាក្យទាំងនេះត្រូវបានគេប្រើជាទូទៅ ។

### ការស្រូបចូល (ABSORPTION)

គឺជាដំណើរការដែលសារធាតុគីមីចូលទៅក្នុងខ្លួនដោយផ្ទាល់ តាមរយៈស្បែក ។ សារធាតុគីមីមួយចំនួនអាចចូលទៅក្នុងខ្លួនក្នុងបរិមាណដ៏ច្រើនតាមផ្លូវនេះ ។ ឧទាហរណ៍ រួមមាន benzidine, carbon disulphide, cyanide, phenol និងសារធាតុផ្សេងទៀត ។ ផ្លូវចូលផ្សេងទៀត រួមមានការលេបចូលតាមមាត់ និង ហឺតចូលតាមចម្រុះ ។

### ស្រួចស្រាវ (ACUTE)

គឺជាលក្ខខណ្ឌឬស្ថានភាពដែលកើតឡើងភ្លាមៗ ឬយ៉ាងរហ័សនៅពេលប៉ះពាល់នឹងមុខសញ្ញាគ្រោះថ្នាក់ ។ ឧទាហរណ៍ ការពុលពីកាបូនម៉ូណូអុកស៊ីត អ៊ីដ្រូសែនស៊ុលហ្វីត ឬស៊ីយ៉ានិត គឺជាផលប៉ះពាល់ស្រួចស្រាវ ។ ផលប៉ះពាល់ស្រួចស្រាវដែលមិនបង្កការស្លាប់ គឺអាចសះស្បើយពេញលេញឡើងវិញបាន ។ ចូរប្រៀបធៀបនិយមន័យនៃ រ៉ាំរ៉ៃ និង សម្ងំ ។

### តាមបណ្តោយផ្លូវ (ការតាមដាន) (ALONG PATH)

នៅក្នុងការពិភាក្សាអំពីកន្លែងដែលល្អបំផុតដើម្បីគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ឃ្លាដែលថា "តាមបណ្តោយផ្លូវ" (“along the path”) ឬ "តាមបណ្តោយផ្លូវប៉ះពាល់" ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាអំពីយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះថ្នាក់នៅកន្លែងណាមួយ រវាងប្រភពដើមរបស់វា និងចំណុចនៃអន្តរកម្មជាមួយកម្មករ ។ ចូរប្រៀបធៀបនិយមន័យនៃ AT SOURCE (នៅត្រង់ប្រភព) និង AT THE WORKER (នៅត្រង់កម្មករ) ។ ឧទាហរណ៍ដូចជា របាំងការពារម៉ាស៊ីន និងរនាំង ឧបករណ៍ស្រូបសំឡេងម៉ាស៊ីន ប្រព័ន្ធខ្យល់ចេញចូលក្នុងរោងចក្រ និងកន្លែងធ្វើការ ។

### សារធាតុស្រូបអុកស៊ីសែន (ASPHYXIANT)

ជាសារធាតុឧស្ម័នមួយដែលមិនទ្រទ្រង់ជីវិត ដែលមិនមែនជាសារធាតុពុលក្តី ។ ឧទាហរណ៍គឺ នីត្រូសែន និងកាបូនឌីអុកស៊ីត ។ យើងដកដង្ហើមចូលសារធាតុទាំងពីរនេះគ្រប់ពេលវេលា ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសារធាតុទាំងនេះលុបបំបាត់អុកស៊ីហ្សែននៅក្នុងខ្យល់ យើងនឹងស្លាប់ដោយសារតែវាមិនទ្រទ្រង់ជីវិតដូចជាអុកស៊ីសែនទេ ។

### នៅត្រង់ប្រភពផ្ទាល់ (AT THE SOURCE)

នៅក្នុងការពិភាក្សាអំពីកន្លែងដែលល្អបំផុតដើម្បីគ្រប់គ្រងគ្រោះថ្នាក់ ឃ្លា "នៅប្រភព" ត្រូវបានប្រើដើម្បីពិពណ៌នាអំពីយុទ្ធសាស្ត្រនៃការលុបបំបាត់មុខសញ្ញាគ្រោះថ្នាក់ទាំងស្រុង ឧទាហរណ៍ ដោយធ្វើការដកវាចេញ ឬជំនួសដោយសារធាតុគីមីដែលមានគ្រោះថ្នាក់តិចជាងមុន ។ នេះគឺជាយុទ្ធសាស្ត្រគ្រប់គ្រងដ៏ល្អបំផុតដែលអាចអនុវត្តបាន ពីព្រោះមិនចាំបាច់មានការត្រួតពិនិត្យតាមដាន ការថែទាំ កម្មវិធីគ្រប់គ្រង ឬការបណ្តុះបណ្តាលបន្ថែមទៀតទេ - មុខសញ្ញាគ្រោះថ្នាក់នោះនឹងបាត់ទៅវិញ ។ ប្រៀបធៀបនិយមន័យនៃ ALONG PATH និង AT THE WORKER ។

### នៅត្រង់កម្មករផ្ទាល់ (AT THE WORKER)

នៅក្នុងការពិភាក្សាអំពីទីកន្លែងដែលល្អបំផុតដើម្បីគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់មួយ ពាក្យថា "នៅត្រង់កម្មករ" ត្រូវបានប្រើដើម្បីពិពណ៌នាអំពីយុទ្ធសាស្ត្រនៃការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់នៅត្រង់កម្មករផ្ទាល់ ។ ឧទាហរណ៍ រួមមាននីតិវិធីការងារ ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) និងការគ្រប់គ្រងផ្នែករដ្ឋបាល ដូចជាការប្តូរវេនការងារជាដើម ។ នេះគឺជាចំណុចដែលមានប្រសិទ្ធភាពតិចបំផុតក្នុងការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ ព្រោះវាតម្រូវឱ្យមានការបង្កើតកម្មវិធីគ្រប់គ្រង និងការត្រួតពិនិត្យជាប្រចាំចំពោះការអនុលោមតាមគោលការណ៍ច្បាប់ ភាពសមស្របនៃការប្រើ PPE, ការប្រើប្រាស់ PPE, ការថែទាំ PPE, ការមាន PPE សម្រាប់ប្រើប្រាស់, ការបណ្តុះបណ្តាល ការពង្រឹងការអនុវត្តបទបញ្ជា ។ល។ ដោយសារតែហេតុផលនេះ ការត្រួតពិនិត្យនៅត្រង់កម្មករផ្ទាល់ កម្រមានប្រសិទ្ធភាព ១០០% ណាស់ ។

### គ្រោះថ្នាក់ជីវសាស្ត្រ

ពាក្យនេះជាពាក្យទូទៅ ដែលសំដៅលើភ្នាក់ងារបង្ករោគនានា ដូចជា បាក់តេរី វីរុស និងព្រីយ៉ុង និងរួមបញ្ចូលមុខសញ្ញាគ្រោះថ្នាក់ជីវសាស្ត្រផ្សេងៗទៀតផងដែរ ។ មុខសញ្ញាគ្រោះថ្នាក់ទាំងនេះ អាចជាពពួកស្លែនិងផ្សិត និងស្ព័ររបស់វា លំអង ឬអង្គែសត្វ ដែលអាចបង្កឱ្យមានប្រតិកម្មអាលែហ្ស៊ី សត្វល្អិតតូចៗបំផុត និងជួនកាល ជីវម៉ូលេគុលផ្សេងៗទៀត ដូចជាប្រូតេអ៊ីន អង់ហ្ស៊ីម អ័រម៉ូន ឬ DNA ។

### រលាក (BURN)

គឺជាការខូចខាតជាលិកាដែលបណ្តាលមកពីការប៉ះកម្តៅដោយផ្ទាល់ ។ ជួនកាល ឃ្លាថា "ការរលាកដោយសារធាតុគីមី" ត្រូវបានគេប្រើដើម្បីសំដៅទៅលើការខូចខាតជាលិកាដែលបណ្តាលមកពីសារធាតុគីមីដែលកាត់ ។

### សារធាតុបង្កមហារីក (CARCINOGEN)

គឺជាសារធាតុ ឬភ្នាក់ងារដែលអាចបង្កមហារីក ។ សារធាតុបង្កមហារីក អាចជាសារធាតុដែលចាប់ផ្តើមបង្កជាជំងឺមហារីក (មានន័យថា វាមានសមត្ថភាពបំផ្លាញ ឬបង្កឱ្យមានការផ្លាស់ប្តូរទៅលើ DNA របស់កោសិកា, បង្កើត ឬបើ DNA sequence ដែលសរសេរលេខកូដសម្រាប់មហារីក — "ហ្សែនមហារីក") ឬជាសារធាតុជំរុញមហារីក (មានសមត្ថភាពបង្ក ឬផ្តល់សញ្ញាព្រឹត្តិការណ៍ជីវគីមីមួយឬច្រើន ដែលតាងដោយ "ហ្សែនមហារីក") ។ សារធាតុបង្កមហារីកខ្លះ គឺជាភ្នាក់ងារផ្តួចផ្តើមផង និងភ្នាក់ងារជំរុញផង ។

### រ៉ាំរ៉ៃ (CHRONIC)

សំដៅលើដំណើរការនៃជំងឺមួយដែលមានរយៈពេលវែង និងធន់ទ្រាំនឹងការព្យាបាល ទោះជាមិនជានិច្ចជាកាលក្តី ។ ជារឿយៗ ជំងឺរ៉ាំរ៉ៃមិនអាចជាសះស្បើយពេញលេញបានទេ ពីព្រោះ (ជាធម្មតា) ការខូចខាតបានកើតឡើងក្នុងរយៈពេលជាច្រើនឆ្នាំ ហើយបណ្តាលឱ្យមានការខូចខាតដែលមិនអាចជាសះស្បើយឡើងវិញបានចំពោះសរីរាង្គ ឬប្រព័ន្ធ ។ ឧទាហរណ៍មនុស្សជាច្រើន មិនបានចាប់អារម្មណ៍នឹងជំងឺសួតទេ រហូតដល់ ៨៥% នៃសមត្ថភាពសួតត្រូវបានបំផ្លាញជាអចិន្ត្រៃយ៍ ហើយមិនអាចជាសះស្បើយវិញបាន ។ ជារឿយៗ នេះគឺដោយសារតែសកម្មភាពធម្មតាត្រូវការសមត្ថភាពមិនលើសពី ១៥% នៃសមត្ថភាពនៃសួតដែលមានសុខភាពល្អទាំងសងខាង ។

### វិធានការគ្រប់គ្រង (CONTROL MEASURE)

គឺជាយុទ្ធសាស្ត្រដែលគេប្រើដើម្បីទប់ស្កាត់មុខសញ្ញាគ្រោះថ្នាក់ពីការបង្ករបួស ឬជំងឺ ។ ការអនុវត្តអនាម័យឧស្សាហកម្មល្អទទួលស្គាល់ថា ទីកន្លែងល្អបំផុតដើម្បីគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់គឺនៅប្រភពផ្ទាល់ ហើយថា ចំណុចដែលមានប្រសិទ្ធភាពតិចបំផុតចំពោះការគ្រប់គ្រងមុខសញ្ញាគ្រោះថ្នាក់ គឺនៅត្រង់កម្មករផ្ទាល់ ។ វិធានការគ្រប់គ្រងដែលបានអនុវត្តឡើងនៅចំណុចណាមួយរវាងប្រភពនៃមុខសញ្ញាគ្រោះថ្នាក់ និងកម្មករ ត្រូវបានគេហៅថា ការគ្រប់គ្រង "តាមបណ្តោយផ្លូវ" (“along the path”) ដែលសំដៅទៅលើផ្លូវដែលប៉ះពាល់ (the exposure path) ។

### សារធាតុកាត់ (CORROSIVE)

គឺជាសារធាតុគីមីដែលអាចវាយប្រហារដោយផ្ទាល់ និងបំផ្លាញជាលិការស់ជាក់ស្តែង ។ ឧទាហរណ៍នៃសារធាតុកាត់ រួមមានអាស៊ីតខ្លាំង (ឧទា. អាស៊ីតស៊ុលហ្វួរិក អាស៊ីតក្លរីឌ្រិក) និងបាសខ្លាំង (ឧទា. សូដា) ។

### បូកយោង (CUMULATIVE)

សារធាតុពុល ឬជាតិពុល ដែលត្រូវបានបញ្ចេញចេញពីរាងកាយយឺតជាងការហឺតចូល លេបចូល ឬស្រូបចូល ។ សារធាតុបែបនេះនឹងមានកំហាប់កើនឡើងនៅក្នុងរាងកាយរហូតដល់ផលប៉ះពាល់សុខភាពលេចចេញឡើង ។

### ឌី.អិន.អេ (DNA)

អាស៊ីតឌីអុកស៊ីរីបូនិយក្លេអ៊ិក (deoxyribonucleic) ។ ជាម៉ូលេគុលដ៏ធំមួយដែលមាននៅក្នុងស្នូលនៃកោសិកា, នៅក្នុង DNA មានសេចក្តីណែនាំសម្រាប់សកម្មភាពកោសិកា ។ សេចក្តីណែនាំទាំងនេះត្រូវបានសរសេរកូដដោយលំដាប់នៃអាស៊ីតនុយក្លេអ៊ិកចំនួនបួនផ្សេងគ្នា ដែលត្រូវបានភ្ជាប់ជាគូរវាងឆ្អឹងខ្នងហេលិច (helix) ទ្វេវែងនៃម៉ូលេគុលនោះ ។

### ទំនាក់ទំនងដូស-ឆ្លើយតប (DOSE-RESPONSE RELATIONSHIP)

ទំនាក់ទំនងរវាងកម្រិតនៃការប៉ះពាល់ (ដូស) ទៅនឹងភ្នាក់ងារគីមី ជីវសាស្ត្រ ឬរូបវន្ត និងភាពធ្ងន់ធ្ងរ និងភាពញឹកញាប់នៃផលប៉ះពាល់លើសុខភាពអវិជ្ជមានដែលពាក់ព័ន្ធ (ការឆ្លើយតប) ។

### ធូលី (DUST)

ភាគល្អិតតូចៗនៃសារធាតុរឹងដែលហោះហើរក្នុងខ្យល់ ។ ទំហំភាគល្អិតមានសារៈសំខាន់ ហើយអ្នកជំនាញខាងអនាម័យឧស្សាហកម្មតែងតែស្វែងរក "ធូលីល្អិតបំផុតដែលអាចដកដង្ហើមចូលយ៉ាងជ្រៅទៅក្នុងសួត" (“respirable dust”) ។ ភាគល្អិតធូលីធំៗ ច្រើនតែជាប់ក្នុងច្រមុះ បំពង់ក និងផ្លូវដង្ហើមផ្នែកខាងលើ ។ ភាគល្អិតក្រោមទំហំជាក់លាក់មួយដែលទំនងជាជ្រាបចូលយ៉ាងជ្រៅទៅក្នុងសួត ត្រូវបានគេហៅថាជា "អាចដកដង្ហើមចូលយ៉ាងជ្រៅក្នុងសួត" (“respirable”) ។

### ដែនអេឡិចត្រូម៉ាញ៉េទិក (ELECTROMAGNETIC FIELD (EMF))

អគ្គិសនីតែងតែបង្កើតដែនអគ្គិសនី និងដែនម៉ាញេទិក ។ ទោះបីជាដែនអគ្គិសនីនិងម៉ាញេទិក មានលក្ខណៈ ខុសគ្នា និងអាចវាស់វែងដោយឡែកពីគ្នាក៏ដោយ ជារឿយៗ ដែនទាំងពីរនេះត្រូវបានគេដាក់ជាក្រុមជាមួយគ្នា ហើយត្រូវបានគេហៅថា ដែនអេឡិចត្រូម៉ាញេទិក ឬ EMFs ។ យើងទាំងអស់គ្នា ត្រូវបានហ៊ុំព័ទ្ធដោយ EMFs ទាំងនៅកន្លែងធ្វើការ និងនៅផ្ទះ ។ ប្រសិនបើដែនអេឡិចត្រូម៉ាញេទិកមានលទ្ធភាពតិចតួចបំផុតក្នុងការបង្កប៉ះពាល់ដល់សុខភាពមនុស្ស នោះ គេគួរតែយកចិត្តទុកដាក់ឱ្យបានខ្លាំងបំផុតទៅលើបញ្ហានេះ ដោយសារតែមានមនុស្សយ៉ាងច្រើនដែលប៉ះពាល់ដោយសារសារធាតុទាំងនេះ ។

### ថាមពល (ENERGY)

នៅក្នុងសុខភាពនិងសុវត្ថិភាពការងារ ថាមពលអាចត្រូវបានគេគិតថា ជាអ្វីៗដែលមានសមត្ថភាពបង្កើតចលនា ឬបណ្តាលឱ្យមានរបួស ។ នៅពេលរៀបចំឧបករណ៍បរិក្ខារសម្រាប់ការថែទាំ គេត្រូវតែពិចារណាប្រភពថាមពលជាសក្តានុពលទាំងអស់ ។ ប្រភពទាំងនេះអាចរួមមានថាមពលគីនេទិក (kinetic) (ផ្នែកដែលនៅតែមានចលនា), ថាមពលដែលអាចបញ្ចេញដោយសារតែទំនាញផែនដី, ថាមពលរក្សាទុកនៅក្នុងប្រព័ន្ធដែលមានសម្ពាធ ឬរឺស័រដែលត្រូវបានសង្កត់, ថាមពលអគ្គិសនី, ថាមពលគីមី, ថាមពលពន្លឺ; ថាមពលកម្តៅ, និងការបញ្ចេញវិទ្យុសកម្មអ៊ីយ៉ុង ។

### ការរៀបចំប្លង់កន្លែងធ្វើការ (ERGONOMICS)

គឺជាគោលការណ៍នៃការរចនាប្លង់ការងារដើម្បីឱ្យត្រូវគ្នានឹងលក្ខណៈពិតប្រាកដរបស់កម្មករ ។ អ្នកជំនាញខាងរចនាប្លង់កន្លែងធ្វើការ (Ergonomists) ពិចារណាពីទំហំ និងកម្លាំងរបស់កម្មករ ធៀបនឹងតម្រូវការរបស់ការងារ ជំហរ និងចលនាដែលពួកគេត្រូវមាន, ភាពញឹកញាប់នៃចលនាដដែលៗ ក៏ដូចជាទិដ្ឋភាពផ្សេងៗទៀតនៃប្រព័ន្ធមនុស្ស/ការងារ ។

### គ្រឿងផ្ទុះ (EXPLOSIVE)

ជាសារធាតុគីមីដែលឆេះ ឬមានប្រតិកម្មយ៉ាងរហ័ស និងដោយហិង្សា ដែលបង្កើតជារលកកន្ត្រាក់ ។ គ្រឿងផ្ទុះគឺជាវត្ថុធាតុមិនស្ថិតស្ថេរ ដែលជារឿយៗអាចត្រូវបានបំផ្ទុះដោយការកន្ត្រាក់ ឬសីតុណ្ហភាពកើនឡើង ទោះបីជាមិនមានប្រភពចំហេនៃការបញ្ឆេះក៏ដោយ ។

### ការប្រឈម/ការប៉ះពាល់ (EXPOSURE)

វិធីដែលមុខសញ្ញាគ្រោះថ្នាក់មានអន្តរកម្មជាមួយ ឬចូលទៅក្នុងខ្លួន, ថាតើដោយ ឧទា. ការស្រូប ការប៉ះផ្ទាល់ ការស្រូបចូល ឬការឆ្លងមេរោគ ។ ការប៉ាន់ស្មានបរិមាណនៃការប៉ះពាល់នឹងសារធាតុពុលមួយ គឺជាការវាស់បរិមាណ និងសារធាតុកំហាប់ លក្ខណៈនៃការងារដែលកំពុងធ្វើ និងទំហំនៃការប៉ះពាល់រវាងកម្មករ និងសារធាតុនោះ ចំនួនមនុស្សដែលប៉ះពាល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់នោះ និងរយៈពេលនៃការប៉ះពាល់ ។

### ការវាយតម្លៃការប្រឈម/ការប៉ះពាល់ (EXPOSURE ASSESSMENT)

គឺជាការវាយតម្លៃលើសក្តានុពល និងកម្រិតនៃការប៉ះពាល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដែលបានកំណត់ ។ នេះរួមបញ្ចូលទាំងការវាយតម្លៃលើភាពញឹកញាប់នៃការប៉ះពាល់ ចំនួនកម្មករដែលត្រូវបានប៉ះពាល់ និងភាពខ្លាំងក្លានៃការប៉ះពាល់ ។ សូមមើលការកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់ ។

### ផ្សែង (FUME)

គឺជាភាគល្អិតតូចៗដែលស្ថិតនៅក្នុងខ្យល់ដែលត្រូវបានបញ្ចេញជាវត្ថុរាវ ប៉ុន្តែបង្រួមយ៉ាងរហ័សទៅជារឹង ។ ឧទាហរណ៍ ផ្សែងពីការផ្សារដែក ត្រូវបានបញ្ចេញចេញពីចំណុចនៃការផ្សារទៅជាតំណក់តូចៗនៃលោហៈដែលរលាយ ប៉ុន្តែផ្លាស់ប្តូរស្ថានភាពទៅជាភាគល្អិតរឹងតូចៗភ្លាមៗ ។

### ប្រព័ន្ធសុខដុមនីយកម្មសកលនៃការចាត់ថ្នាក់ និងការដាក់ស្លាកសម្គាល់សារធាតុគីមី (GLOBALLY HARMONIZED SYSTEM OF CLASSIFICATION AND LABELLING OF CHEMICALS (GHS))

គឺជាប្រព័ន្ធអន្តរជាតិថ្មីសម្រាប់ប្រព័ន្ធព័ត៌មានអំពីសម្ភារៈគ្រោះថ្នាក់នៅកន្លែងធ្វើការរបស់ប្រទេសផ្សេងៗ ។ ដោយមានការព្រួយបារម្ភថា ការរីកសាយភាយនៃច្បាប់ជាតិស្តីពី “សិទ្ធិដើម្បីដឹង” កំពុងក្លាយជារបាំងពាណិជ្ជកម្ម ភ្នាក់ងារជាច្រើនរបស់អង្គការសហប្រជាជាតិ ត្រូវបានប្រគល់ភារកិច្ចឱ្យបង្កើតប្រព័ន្ធសុខដុមនីយកម្មអន្តរជាតិមួយនៃចំណាត់ថ្នាក់ និងការបង្ហាញព័ត៌មានអំពីសារធាតុគីមីគ្រោះថ្នាក់ ។

### មុខសញ្ញាគ្រោះថ្នាក់ (HAZARD)

មានសក្តានុពលបង្កគ្រោះថ្នាក់ ផ្អែកលើលក្ខណៈពីធម្មជាតិ ។ ចូរប្រៀបធៀបនិយមន័យនៃហានិភ័យ ។ ឧទាហរណ៍ សារធាតុពុលគឺជាមុខសញ្ញាគ្រោះថ្នាក់មួយ ទោះបីជាគ្មាននរណាម្នាក់ប៉ះពាល់វាក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើឱកាសនៃការប៉ះពាល់មានកម្រិតទាប ហានិភ័យប្រហែលជាមិនមានភាពធំដុំនោះទេ ។

### ការសម្គាល់លក្ខណៈនៃមុខសញ្ញាគ្រោះថ្នាក់ (HAZARD CHARACTERIZATION)

Eគឺជាការវាយតម្លៃប្រភេទនៃការរងរបួសដែលអាចកើតមាន និងផលប៉ះពាល់លើសុខភាពអវិជ្ជមាន ដែលទាក់ទងជាមួយមុខសញ្ញាគ្រោះថ្នាក់ដែលបានកំណត់ ។ សូមមើលការកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់ ។

### ការកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់ (HAZARD IDENTIFICATION)

គឺជាការកំណត់អត្តសញ្ញាណសម្ភារៈ ឧបករណ៍ បរិក្ខារ ភ្នាក់ងារជីវសាស្រ្ត សារធាតុគីមី ភ្នាក់ងាររូបវន្ត និងតម្រូវការការងារដែលមានសមត្ថភាពបង្ករបួស ឬផលប៉ះពាល់ដល់សុខភាពអវិជ្ជមាន ។

### ការលេបចូល (INGESTION)

គឺជាដំណើរការដែលអ្វីៗចូលទៅក្នុងរាងកាយតាមរយៈប្រព័ន្ធរំលាយអាហារ ។ ទោះបើជាជាធម្មតា ការលេបមិនត្រូវបានគេគិតថាជាបញ្ហានៅកន្លែងធ្វើការក៏ដោយ ប៉ុន្តែសារធាតុគីមីនៅកន្លែងធ្វើការក្នុងបរិមាណយ៉ាងច្រើនអាចត្រូវបានលេបចូលដោយការលេបទឹកមាត់ លិតបបូរមាត់ផងដែរ ។

### ការហឺតចូល (INHALATION)

គឺជាដំណើរការនៃអ្វីៗចូលក្នុងខ្លួនតាមប្រព័ន្ធផ្លូវដង្ហើម ។ ជាទូទៅ ការហឺតចូល ត្រូវបានចាត់ទុកថាជាផ្លូវចូលដែលធ្ងន់ធ្ងរបំផុតនៃសារធាតុពុលនៅកន្លែងធ្វើការ ទោះបីជាការលេបចូល និងការស្រូបចូល ក៏អាចមានសារៈសំខាន់ផងដែរនៅក្នុងករណីខ្លះដែរ ។

### សម្ងំ (LATENT)

គឺជារយៈពេលរវាងការប៉ះពាល់នឹងសម្ភារៈគ្រោះថ្នាក់ និងការលេចចេញឡើងនៃផលប៉ះពាល់សុខភាព ។ ការសម្ងំ ត្រូវបានគេលើកឡើងជាទូទៅបំផុតទាក់ទងនឹងជំងឺមហារីកការងារ ។ ឧទាហរណ៍ ពីរឬបីទសវត្សរ៍អាចកន្លងផុតទៅ រវាងការប៉ះពាល់នឹងសារធាតុអាបេស្តូសពីដំបូងរបស់កម្មករ និងការលេចចេញនៃជំងឺដែលទាក់ទងនឹងអាបេស្តូស ។

### ពន្លឺ (LIGHT)

ការបញ្ចេញវិទ្យុសកម្មអេឡិចត្រូម៉ាញេទិកដែលអាចមើលឃើញដោយភ្នែក ។

### បណ្ណទិន្នន័យសុវត្ថិភាពសម្ភារៈ (MATERIAL SAFETY DATA SHEET (MSDS)): សូមមើល បណ្ណទិន្នន័យសុវត្ថិភាព SAFETY DATA SHEETS (SDS)

គឺជាទម្រង់ដែលកំណត់ដោយច្បាប់សម្រាប់បង្ហាញព័ត៌មានអំពីសម្ភារៈ/សារធាតុគ្រោះថ្នាក់ ។

### មុខសញ្ញាគ្រោះថ្នាក់ដោយគ្រឿងម៉ាស៊ីន (MECHANICAL HAZARD)

គឺជាមុខសញ្ញាគ្រោះថ្នាក់ទូទៅ ដែលទាក់ទងនឹងយានយន្ត ឧបករណ៍ចល័ត គ្រឿងចក្រឧស្សាហកម្មដែលមានសក្តានុពលក្នុងការកាត់ ពុះ ឬកំទេចសរីរាង្គកាយ ។

### សំណើម (MIST)

គឺជាតំណក់តូចៗនៃវត្ថុរាវនៅក្នុងខ្យល់ ។

### សារធាតុមុយតាហ្សែន (MUTAGEN)

មានសមត្ថភាពធ្វើឱ្យមានការផ្លាស់ប្តូរហ្សែន (DNA) នៅក្នុងកោសិកាមេជីវិត (មេជីវិតឈ្មោលចំពោះបុរស, អូវែចំពោះស្ត្រី) ដែលអាចផ្ទេរបន្តទៅកូនចៅរបស់ពួកគេ ។ ការបំលែងអាចបណ្តាលឱ្យកើតស្លាប់ ឬបញ្ហាមិនគ្រប់លក្ខណៈពីកំណើត, មានទំនោរកើតមហារីកក្នុងពេលខាងមុខ និងការផ្លាស់ប្តូរផ្សេងទៀត ។ ចូរប្រៀបធៀបជាមួយនិយមន័យនៃ TERATOGEN ។

### សំឡេងរំខាន (NOISE)

ថាមពលក្នុងទម្រង់ជារំញ័រក្នុងខ្យល់ ដែលអាចរកឃើញដោយត្រចៀក ។

### សរីរាង្គ (ORGAN(S))

គឺជាផ្នែករចនាសម្ព័ន្ធនៃរាងកាយដែលមានមុខងារជាក់លាក់ ។ នៅក្នុងការពិភាក្សាអំពីផលប៉ះពាល់នៃសារធាតុគីមីពុល ជាការសំខាន់ដែលត្រូវកត់សម្គាល់ពីផលប៉ះពាល់របស់វាទៅលើសរីរាង្គជាក់លាក់ណាមួយ ឬសរីរាង្គជាច្រើន ។

### សារធាតុអុកស៊ីតកម្ម (OXIDIZER)

ទោះបីជាវាមិនមែនជាសារធាតុដែលមិនឆេះ ឬមិនផ្ទុះដោយខ្លួនឯងក្តី ក៏សារធាតុអុកស៊ីតកម្មជំរុញការឆេះ ឬប្រតិកម្មដ៏គ្រោះថ្នាក់ដែរ ។ ជាការពិតណាស់ អុកស៊ីសែនគឺជាសមាជិកនៃក្រុមនេះ ហើយឧទាហរណ៍ផ្សេងទៀតរួមមានពែរអុកស៊ីត (peroxides) សរីរាង្គ, សារធាតុពែរម៉ង់ហ្គាណាត (permanganates) និងសារធាតុណាក៏ដោយដែលរួមចំណែកដល់ការឆេះនៃសារធាតុផ្សេងទៀត ។

### ចំណុចប្រសព្វ (PINCH POINT)

គឺជាមុខសញ្ញាគ្រោះថ្នាក់មេកានិកទូទៅមួយដែលពិពណ៌នាអំពីចំណុចមួយដែលក្នុងនោះផ្នែកមានចលនាចំនួនពីរ ឬផ្នែកមានចលនាចំនួនមួយនិងផ្នែកមួយទៀតគ្មានចលនា អាចឆក់ចាប់កម្មករ ឬផ្នែកណាមួយនៃរាងកាយ ។ ចំណុចប្រសព្វ (Pinch Points) មានសក្តានុពលក្នុងការកាត់ បំបែក ឬកំទេចផ្នែកផ្សេងៗនៃរាងកាយ ។

### ជាតិពុល (POISON)

ជាសារធាតុគ្រោះថ្នាក់ដែលជ្រៀតជ្រែកដោយផ្ទាល់ទៅលើដំណើរការជីវគីមីនៃកោសិការបស់រាងកាយ ។ ឧទាហរណ៍ កាបូនម៉ូណូអុកស៊ីត រំខានដល់សមត្ថភាពរបស់គោលិកាក្រហម (អេម៉ូក្លូប៊ីន) នៅក្នុងគ្រាប់ឈាមក្នុងការដឹកជញ្ជូនអុកស៊ីសែនឆ្លងកាត់រាងកាយ ដោយភ្ជាប់ទៅនឹងម៉ូលេគុលអេម៉ូក្លូប៊ីនខ្លាំងជាងអុកស៊ីសែន ។ អ៊ីដ្រូសែនស៊ុលហ្វីត គឺជាសារធាតុពុលណឺត្រូតុកស៊ីន (neurotoxin) (ផ្នែកទីមួយនៃពាក្យផ្សំដែលមានពាក្យ "ជាតិពុល" (តុកស៊ីន) នៅខាងចុង ជាទូទៅសំដៅទៅលើសរីរាង្គ ឬប្រព័ន្ធដែលសារធាតុពុលវាយប្រហារ) ដែលរំខានដល់ដំណើរការជីវគីមី ដោយអនុញ្ញាតឱ្យកោសិកាខួរក្បាល និងសរសៃប្រសាទបញ្ជូនសញ្ញា ។ អ៊ីដ្រូសែនស៊ុលហ្វីត ទំនងជាសម្លាប់ដោយបញ្ឈប់សញ្ញាសរសៃប្រសាទដែលគ្រប់គ្រងការដកដង្ហើម ។ ស្ទួតឈប់ដំណើរការ ហើយធ្វើឱ្យស្លាប់ដោយសារថង់ដង្ហើម (asphyxiation) ។ ការពុល (TOXIC) គឺជាពាក្យមានន័យដូចនឹងជាតិពុល (poison) ។

### គោលការណ៍ប្រុងប្រយ័ត្ន (PRECAUTIONARY PRINCIPLE)

គឺជាដំណើរការធ្វើការសម្រេចចិត្តដែលសន្មតថា ទិន្នន័យដែលមានអំពីមុខសញ្ញាគ្រោះថ្នាក់គឺកម្រមានសុក្រឹតភាព និងមិនដែលមានភាពពេញលេញនោះទេ ។ នៅពេលដែលសកម្មភាពមួយ ធ្វើឱ្យមានការព្រួយបារម្ភថា សុខភាពកម្មករ ឬសុខភាពបរិស្ថានអាចត្រូវរងការគំរាមកំហែង វិធានការប្រុងប្រយ័ត្នគួរតែត្រូវបានអនុវត្ត ទោះបីជាគេមិនអាចបញ្ជាក់ច្បាស់តាមវិទ្យាសាស្ត្រពីទំនាក់ទំនងរវាងមូលហេតុ និងផលប៉ះពាល់ខ្លះក្តី ។ ដំណើរការនៃការអនុវត្តគោលការណ៍ប្រុងប្រយ័ត្នត្រូវតែបើកចំហ, ផ្តល់ព័ត៌មាន និងធ្វើឡើងដោយមានការចូលរួមពីភាគីដែលរងផលប៉ះពាល់ ។ ដំណើរការនេះក៏ត្រូវតែមានការពិនិត្យមើលទៅលើជម្រើសជំនួសពេញលេញ រួមទាំងការមិនធ្វើសកម្មភាពអ្វីសោះ ផងដែរ ។

### លក្ខណៈ (PROPERTIES)

គឺជាលក្ខណៈសម្គាល់ជាធម្មជាតិនៃអ្វីមួយ ។ លក្ខណៈនៃសារធាតុគ្រោះថ្នាក់គឺមិនប្រែប្រួលនោះទេ និងមិនអាស្រ័យលើបរិមាណ ឬលំហាប់ របៀបប្រើប្រាស់ ចំនួនកម្មករដែលប៉ះពាល់ ឬទំហំនៃការប៉ះពាល់របស់កម្មករនោះទេ ។

### ការបញ្ចេញវិទ្យុសកម្ម (RADIATION)

សំដៅលើថាមពលអេឡិចត្រូម៉ាញេទិកដែលអាចធ្វើដំណើរឆ្លងកាត់លំហ ។ កម្តៅ វិទ្យុ និងសញ្ញាទូរទស្សន៍ មីក្រូវ៉េវ និងពន្លឺគឺជាទម្រង់ទាំងអស់នៃវិទ្យុសកម្ម ប៉ុន្តែជាធម្មតា ពាក្យនេះត្រូវបានផ្សារភ្ជាប់ទៅនឹងសុខភាព និងសុវត្ថិភាពការងារ ដែលមានវិសាលគមអេឡិចត្រូម៉ាញ៉េទិកថាមពលខ្ពស់ និងប្រេកង់ខ្ពស់ ។ ការបញ្ចេញវិទ្យុសកម្មថាមពលខ្ពស់ (ឧទាហរណ៍ កាំរស្មីអ៊ិច និងការបញ្ចេញវិទ្យុសកម្មហ្គាម៉ា) អាចបញ្ចេញអេឡិចត្រុងពីអាតូមដើម្បីបង្កើតអ៊ីយ៉ុង ហើយដោយសារហេតុផលនេះ ជារឿយៗ ត្រូវបានគេហៅថា "ការបញ្ចេញវិទ្យុសកម្មអ៊ីយ៉ុង" ។ ការបញ្ចេញវិទ្យុសកម្មអ៊ីយ៉ុងគឺមានគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារវាជ្រៀតចូលទៅក្នុងខ្លួនយ៉ាងជ្រៅ ហើយអាចបំផ្លាញកោសិកាដោយមើលមិនឃើញ និងបំផ្លាញ DNA (ដែលជាហេតុបណ្តាលឱ្យកើតឡើងនូវដុំសាច់ ឬមហារីក) ។

### សារធាតុវិទ្យុសកម្ម (RADIOACTIVE)

គឺជាសារធាតុដែលបញ្ចេញវិទ្យុសកម្មអ៊ីយ៉ុងតាមរយៈដំណើរការធម្មជាតិនៃការពុកផុយអាតូម ។

### សារធាតុប្រតិកម្ម (REACTIVE)

ជាសម្ភារៈដែលមិនមានលក្ខណៈស្ថិតស្ថេរតែឯង ឬជាការរួមបញ្ចូលគ្នាជាមួយសម្ភារៈជាក់លាក់ផ្សេងទៀត ។ ជាធម្មតា សារធាតុនេះសំដៅទៅលើវត្ថុធាតុដែលងាយនឹងរលាយឆាប់រហ័ស, ប៉ូលីមែរនីយកម្ម (polymerization) ឬដែលមានប្រតិកម្មយ៉ាងខ្លាំងជាមួយវត្ថុធាតុទូទៅដូចជាទឹក ជាដើម ។

### ហានិភ័យ (RISK)

គឺជាឱកាសនៃការប៉ះពាល់នឹងមុខសញ្ញាគ្រោះថ្នាក់ ហើយបណ្តាលឱ្យមានលទ្ធផលដែលមិនចង់បាន ។ ឧទាហរណ៍ អ៊ីដ្រូសែនស៊ុលហ្វីត គឺជាមុខសញ្ញាគ្រោះថ្នាក់មួយ ពីព្រោះវាមានលក្ខណៈជាឧស្ម័នពុលមួយ ។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យនៃការពុលអ៊ីដ្រូសែនស៊ុលហ្វីតកើតឡើងនៅពេលដែលកម្មករប្រឈមនឹងវា ។ ប្រសិនបើកម្មករកាន់តែច្រើនប្រឈមនឹងអ៊ីដ្រូសែនស៊ុលហ្វីតក្នុងកំហាប់កាន់តែខ្ពស់ ហានិភ័យគឺកាន់តែធំ ទោះបីជាលក្ខណៈរបស់អ៊ីដ្រូសែនស៊ុលហ្វីតមិនមានការផ្លាស់ប្តូរក៏ដោយ ។ ចូរប្រៀបធៀបជាមួយនិយមន័យនៃមុខសញ្ញាគ្រោះថ្នាក់ (HAZARD) ។

### ការប៉ាន់ប្រមាណហានិភ័យ (RISK ASSESSMENT)

គឺជាដំណើរការមួយដែលរួមមានជំហានទាំងឡាយដូចខាងក្រោម ៖ (i) ការកំណត់អត្តសញ្ញាណមុខសញ្ញាគ្រោះថ្នាក់, (ii) ការកំណត់លក្ខណៈសម្គាល់មុខសញ្ញាគ្រោះថ្នាក់, (iii) ការប៉ាន់ប្រមាណការប៉ះពាល់, និង (iv) ការកំណត់លក្ខណៈសម្គាល់ហានិភ័យ ។

## ការកំណត់លក្ខណៈសម្គាល់ហានិភ័យ (RISK CHARACTERIZATION)

គឺជាការប៉ាន់ស្មានអំពីប្រូបាប៊ីលីតេ (លទ្ធភាពដែលអាចកើតឡើង) និងភាពធ្ងន់ធ្ងរនៃការកើតឡើងនូវរបួស/គ្រោះថ្នាក់ឬជំងឺនៅកន្លែងធ្វើការ ជាលទ្ធផលនៃការប៉ះពាល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដែលបានកំណត់ ។

## ការគ្រប់គ្រងហានិភ័យ (RISK MANAGEMENT)

គឺជាដំណើរការនៃការប្រើប្រាស់ការប៉ាន់ប្រមាណហានិភ័យ (q.v.) ដើម្បីធ្វើការសម្រេចចិត្តផ្នែកគោលនយោបាយអំពីការការពារសុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិត និងសម្រាប់ជ្រើសរើសយកជម្រើសបង្ការ និងគ្រប់គ្រងសមស្រប ។ ការប៉ាន់ប្រមាណហានិភ័យ/ការគ្រប់គ្រងហានិភ័យ ជាទូទៅ ត្រូវបានបង្ហាញជាប្រព័ន្ធធ្វើការសម្រេចចិត្តបែបវិទ្យាសាស្ត្រ មិនលំអៀង ដែលត្រូវបានធ្វើឡើងយ៉ាងល្អបំផុតជាសម្ងាត់ដោយ "អ្នកជំនាញ" ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធធ្វើការសម្រេចចិត្តផ្នែកលើហានិភ័យ ជាធម្មតា ពឹងផ្អែកយ៉ាងខ្លាំងលើការសន្មត - ជាពិសេសលើការសន្មតថា ទិន្នន័យដែលបានប្រើនៅក្នុងជំហានផ្សេងៗ គឺមានលក្ខណៈពេញលេញ និងមានភាពសុក្រឹត ។ ចូរប្រៀបធៀបជាមួយនិយមន័យនៃ "គោលការណ៍ប្រុងប្រយ័ត្ន" ។

## បណ្ណទិន្នន័យសុវត្ថិភាព (SAFETY DATA SHEET) (SDS)

គឺជាទម្រង់ដែលកំណត់ដោយច្បាប់សម្រាប់បង្ហាញព័ត៌មានអំពីសម្ភារៈដែលមានគ្រោះថ្នាក់ ។ វាគឺជាលក្ខខណ្ឌតម្រូវមួយនៃប្រព័ន្ធសុខដុមនីយកម្មជាសាកលនៃការចាត់ថ្នាក់ និងការដាក់ស្លាកសម្គាល់សារធាតុគីមី (GHS) ។

## សារធាតុភ្ញោច (SENSITIZER)

និយមន័យធម្មតានៃសារធាតុភ្ញោច (sensitizer) គឺជាសម្ភារៈដែលមានសមត្ថភាពធ្វើអន្តរកម្មជាមួយប្រព័ន្ធការពាររាងកាយដើម្បីបង្កើតប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរមួយ ។ ទោះជាយ៉ាងណាក៏ដោយ និយមន័យនេះមិនគ្រប់គ្រាន់ទាំងស្រុងនោះទេក្នុងន័យសុខភាព និងសុវត្ថិភាពការងារ ។

ឧទាហរណ៍ សារធាតុអ៊ីសូស្យាណាត (isocyanates) គឺជាសារធាតុភ្ញោចឧស្សាហកម្មដ៏ល្បី ពីព្រោះកម្មករកើតមានប្រតិកម្មដូចជាជំងឺហឺតធ្ងន់ធ្ងរនៅពេលពួកគេប៉ះពាល់ទៅនឹងសារធាតុ isocyanates ក្នុងបរិមាណតែបន្តិចបន្តួច ក្នុងខណៈពេលធ្វើការជាមួយសារធាតុនេះ ។ ទោះជាយ៉ាងណាក៏ដោយ យន្តការដែលអ៊ីសូស្យាណាត បង្កើតភាពរំញោច ហាក់ដូចជាមិនធ្វើតាមដំណើរការធម្មតាដែលមនុស្សមានអាឡែស៊ីទៅនឹង ឧទា. លំអង (pollens) និងមិនត្រូវបានគេយល់ច្បាស់លាស់នោះទេ ។ ជាងនេះទៅទៀត ការចាត់ថ្នាក់នៃសារធាតុណាមួយ ជាសារធាតុរំញោច គឺជាការពិបាក ពីព្រោះការឆ្លើយតបគឺអាស្រ័យទៅលើភាពខុសគ្នារបស់បុគ្គលម្នាក់ៗ ច្រើនជាងការឆ្លើយតបទៅនឹងសារធាតុពុលធម្មតា ។

## ស្តង់ដារ (STANDARDS)

គឺជាការបញ្ជាក់ដែលបានបង្កើតឡើង ឬកម្រិតនៃការអនុវត្តដែលរំពឹងទុកនៅក្នុងផ្នែកសុខភាព និងសុវត្ថិភាពការងារ ។

## ប្រសិទ្ធភាពឬកម្លាំងបន្ថែម (SYNERGISTIC)

មុខសញ្ញាគ្រោះថ្នាក់ពីរដែលមានអន្តរកម្មជាមួយគ្នាទៅវិញទៅមក ដោយសារធាតុនីមួយៗបង្កើនហានិភ័យដែលបង្កើតឡើងដោយសារធាតុមួយទៀត ។ ឧទាហរណ៍ដែលគេស្គាល់ច្បាស់ គឺ ៖ ការជក់បារី និងការប៉ះពាល់សារធាតុអាបស្តូស, ការប៉ះពាល់នឹងសារធាតុរំលាយក្លរីន និងការផឹកភេសជ្ជៈមានជាតិអាល់កុល ។ ប្រហែលជា មានអន្តរកម្មកម្លាំងបន្ថែមជាច្រើនទៀតលើសពីអ្វីដែលគេបានដឹង ព្រោះវាពិបាកក្នុងការស្រាវជ្រាវ ។

## ប្រព័ន្ធ (SYSTEM(S))

គឺជាក្រុមនៃសរីរាង្គនិងរចនាសម្ព័ន្ធនៅក្នុងរាងកាយដែលមានមុខងារពាក់ព័ន្ធគ្នា ។ ឧទាហរណ៍ ៖ ប្រព័ន្ធរំលាយអាហារ, ប្រព័ន្ធប្រសាទ, ប្រព័ន្ធបន្តពូជ, ប្រព័ន្ធឈាមរត់ ។

## តេរ៉ាតូហ្សែន (TERATOGEN)

គឺជាភ្នាក់ងារដែលមានសមត្ថភាពបង្កបញ្ហាមិនគ្រប់លក្ខណៈពីកំណើតដោយមិនចាំបាច់បំផ្លាញ DNA នៃកោសិកាមេជីវិត (ចូរប្រៀបធៀបនិយមន័យនៃមូតាហ្សែន MUTAGEN) ។ ឧទាហរណ៍ ថាលីដូមីត (thalidomide) ជាថ្នាំដែលធ្លាប់ត្រូវបានគេប្រើទៅលើម្តាយដែលមានផ្ទៃពោះមួយចំនួនដែលបានបង្កលទ្ធផលមហន្តរាយ ត្រូវបានគេជឿថា បានបង្កឱ្យមានបញ្ហាមិនគ្រប់លក្ខណៈពីកំណើត ដោយសារតែវារំខានទៅលើសញ្ញាជីវគីមី ដែលគ្រប់គ្រងការវិវឌ្ឍរបស់ទារកក្នុងផ្ទៃម្តាយ ។ ទោះជាយ៉ាងណាក៏ដោយ គេមិនជឿថា thalidomide មានសមត្ថភាពបំផ្លាញ DNA នោះទេ ។ ដូច្នេះ បុគ្គលដែលកើតមកមានបញ្ហាមិនគ្រប់លក្ខណៈពីកំណើតដែលបង្កឡើងដោយ thalidomide អាចត្រូវបានរំពឹងថា នឹងមានឱកាសដូចគ្នាក្នុងការមានកូនធម្មតាដោយខ្លួនឯង ដូចមនុស្សទូទៅ ដោយសារវាមិនពាក់ព័ន្ធនឹងការបំលែងខ្លួននោះទេ ។

## សារធាតុពុល (TOXIC)

គឺជាសារធាតុគ្រោះថ្នាក់ដែលរំខានដោយផ្ទាល់ដល់ដំណើរការជីវគីមីនៃកោសិការបស់រាងកាយ ។ ឧទាហរណ៍ កាបូនម៉ូណូអុកស៊ីតរំខានដល់សមត្ថភាពរបស់អេម៉ូក្លូប៊ីនក្នុងកោសិកាឈាម ក្នុងការដឹកជញ្ជូនអុកស៊ីសែននៅក្នុងរាងកាយ ដោយភ្ជាប់ខ្លួនវាទៅនឹងម៉ូលេគុលរបស់អេម៉ូក្លូប៊ីនខ្លាំងជាងអុកស៊ីសែនផ្ទាល់ ។ អ៊ីដ្រូសែនស៊ុលហ្វីត គឺជាសារធាតុពុលណឺត្រូតុកស៊ីន (neurotoxin) (ជាផ្នែកទីមួយនៃពាក្យផ្សំដែលមានពាក្យ “toxin” ( "ជាតិពុល") នៅខាងចុង ជាទូទៅ សំដៅទៅលើសរីរាង្គ ឬប្រព័ន្ធដែលសារធាតុពុលប៉ះពាល់ទៅលើ) ដែលរំខានដល់ដំណើរការជីវគីមីដែលអនុញ្ញាតឱ្យកោសិកាខួរក្បាល និងសរសៃប្រសាទបញ្ជូនសញ្ញា ។ អ៊ីដ្រូសែនស៊ុលហ្វីត ច្រើនតែសម្លាប់ដោយការបញ្ឈប់សញ្ញាសរសៃប្រសាទដែលគ្រប់គ្រងការដកដង្ហើម ។ ស្ទួតឈប់ដំណើរការ ហើយធ្វើឱ្យស្លាប់ដោយការថប់ដង្ហើម (asphyxiation) ។ ជាតិពុល (POISON) គឺជាពាក្យដែលមានន័យដូចគ្នាសម្រាប់សារធាតុពុល (toxic) ។

## ជាតិពុលវិទ្យា (TOXICOLOGY)

គឺជាវិទ្យាសាស្ត្រនៃសារធាតុពុល ជាតិពុល ។ ជាតិពុលវិទ្យា មានគោលដៅកំណត់អត្តសញ្ញាណសារធាតុពុលណាខ្លះមានជាតិពុល, ក្នុងកម្រិតណា ឬបរិមាណណាដែលវាអាចបង្កគ្រោះថ្នាក់ និងយន្តការរបស់វាក្នុងការប៉ះពាល់ទៅលើរាងកាយ ។ ការសិក្សាអំពីជាតិពុលវិទ្យាធម្មតា មានគោលដៅភ្ជាប់ទំនាក់ទំនងកម្រិតប្រើ (ដូស) ឬកំហាប់នៃសារធាតុគ្រោះថ្នាក់មួយ ជាមួយនឹងផលប៉ះពាល់សុខភាពដែលបានសង្កេតឃើញ ។ នៅក្នុងការសិក្សាដោយប្រើប្រាស់សត្វក្នុងមន្ទីរពិសោធន៍ ផលប៉ះពាល់លើសុខភាពដែលបានសង្កេតឃើញជាទូទៅគឺការស្លាប់ ហើយលទ្ធផលនៃការសិក្សាត្រូវបានតាងដោយ LC៥០ (ជាកំហាប់នៃសារធាតុដែលបានសម្លាប់សត្វសាកល្បងប្រមាណ ៥០%) ឬ LD៥០ (កម្រិតនៃសារធាតុដែលបានសម្លាប់ ៥០% នៃសត្វដែលបានសាកល្បង) ។ អ្នកឯកទេសខាងជាតិពុលវិទ្យា ក៏ប្រើការបណ្តុះកោសិកា គំរូកុំព្យូទ័រ និងវិធីសាស្ត្រផ្សេងទៀតដើម្បីទស្សន៍ទាយពីការពុល ។

# ទីស្នាក់ការកណ្តាល


**IndustriALL Global Union**

54 bis, route des Acacias
1227 Geneva Switzerland
Tel: +41 22 308 5050
Email: info@industriall-union.org


# ការិយាល័យប្រចាំតំបន់

## ការិយាល័យប្រចាំទ្វីបអាហ្វ្រិក


Physical address:
North City House
Office S០៨០៨ (៨th Floor)
២៨ Melle Street, Braamfontein
Johannesburg ២០០១ South Africa
Tel: +២៧ ១១ ២៤២ ៨៦៨០
Email: africa@industriall-union.org

Postal address:
P O Box ៣១០១៦
Braamfontein ២០១៧ South Africa


## ការិយាល័យប្រចាំតំបន់អាស៊ីខាងត្បូង


16-D, 16th Floor
Atma Ram House
No.1, Tolstoy Marg
New Delhi - 110 001 India
Tel: +91 11 4156 2566
Email: sao@industriall-union.org


## ការិយាល័យប្រចាំតំបន់អាស៊ីអាគ្នេយ៍


809 Block B, Phileo Damansara II
No 15, Jalan 16/11
46350 Petaling Jaya Selangor Darul
Ehsan, Malaysia
Email: seao@industriall-union.org


## ការិយាល័យ CIS


Str. 2, d.13, Grokholsky per., Room 203
12090 Moscow Russia
Tel: +7 495 974 6111
Email: cis@industriall-union.org


## ការិយាល័យអាមេរិកឡាទីន និងការ៉ាប៊ីន


Avenida 18 de Julio No 1528
Piso 12 unidad 1202
Montevideo Uruguay
Tel: +59 82 408 0813
Email: alc@industriall-union.org



បោះពុម្ពឆ្នាំ ២០២០


www.industriall-union.org

industriall global union